**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économoiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការបោះផ្សាយ និងជួញដូរភាគហ៊ុន នៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣  ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១  ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: កញ្ញា **ឋិន គីមហួយ**

កញ្ញា **ឈិន ស្រីពេជ្រ**

ណែនាំដោយ

លោកស្រី **ហេង ច័ន្ទបូលីន**


ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économoiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការបោះផ្សាយ និងជួញដូរភាគហ៊ុន នៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **ឌិន គីមហួយ**

កញ្ញា **ឈិន ស្រីពេជ្រ**

ណែនាំដោយ

លោកស្រី **ហេង ច័ន្ទបូលីន**

ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ខិន គីមហួយ** និង **ឈិន ស្រីពេជ្រ** ជានិស្សិតថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១៦ ក្រុមB4A1 ឆ្នាំសិក្សា២០២២-២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការសំដែងសេចក្តីដឹងគុណ និងការគោរពយ៉ាងជ្រាលជ្រៅចំពោះ ៖

**លោកឪពុក និងអ្នកម្តាយ** ដែលលោកទាំងពីរបានផ្តល់កំណើត ព្រមជាមួយនឹងការចិញ្ចឹមបីបាច់ថែរក្សាប្រកបដោយព្រហ្មវិហារធម៌។ លោកអ្នកមានគុណទាំងពីរ តែងតែផ្តល់ដំបូន្មានល្អៗជាច្រើន និងការផ្តល់ជាកម្លាំងចិត្តយ៉ាងធំធេងមួយចំពោះរូបកូន ជាពិសេសនោះលោកទាំងពីរ បានខិតខំប្រឹងប្រែងក្នុងការលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីផ្គត់ផ្គង់ការសិក្សារបស់យើងខ្ញុំ តាំងពីដើមរហូតមកដល់ពេលនេះផងដែរ។

ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរងគ្រប់មហាវិទ្យាល័យ លោក លោកស្រីប្រធាន អនុប្រធានគ្រប់ដេប៉ាតឺម៉ង់ លោក លោកស្រីប្រធានការិយាល័យ លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ជាដំបូន្មានល្អៗ និងការបង្ហាត់បង្រៀនយើងខ្ញុំប្រកបដោយការយកចិត្ត ទុកដាក់អស់ពីកម្លាំងកាយចិត្ត។

លោកស្រី **ហេង ច័ន្ទមូលីន** ដែលបានណែនាំនៅក្នុងការសរសេរសារណា បញ្ចប់ការសិក្សាសម្រាប់ប្រធានបទរបស់យើងខ្ញុំ ក៏ដូចជាធ្វើការចង្អុលបង្ហាញ និងការផ្តល់ជាមតិយោបល់ល្អៗ អំពីរបៀបរបបក្នុងការរៀបចំការស្រាវជ្រាវរកព័ត៌មានទាំងឡាយ ព្រមជាមួយការជួយក្នុងការកែលម្អកំហុសខុស ឆ្គងដែលកើតមានឡើងនៅក្នុងសារណារបស់យើងខ្ញុំ ដើម្បីឲ្យការសរសេរសារណាមួយនេះទទួលបានជោគជ័យ ផងដែរ។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីររូបសូមជូនពរដល់លោកអ្នកមានគុណទាំងអស់ សូមឲ្យលោកជួបតែសំណាងល្អ មានសុខភាពល្អ ការងារប្រកបដោយភាពជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សានេះ ត្រូវបានធ្វើការស្រាវជ្រាវ និងការចងក្រងឡើង ក្នុងគោលបំណង ដើម្បីពង្រីកនូវចំណេះដឹង ព្រមទាំងមូលដ្ឋានគ្រឹះសំខាន់ៗ ទាក់ទងវិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យមូលបត្រនៅប្រទេសកម្ពុជា ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងដែលបានឆ្លងកាត់តាមរយៈការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេល៤ឆ្នាំកន្លងមកនេះ។ ក្នុងការស្រាវជ្រាវទៅលើប្រធានបទស្តីពី "ការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា" គឺផ្តោតសំខាន់ទៅលើដំណើរការនៃការបោះផ្សាយភាគហ៊ុន និងដំណើរការជួញដូរភាគហ៊ុននៅកម្ពុជា។

នៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ នឹងធ្វើការឆ្លើយតបយ៉ាងសកម្មទៅនឹងតម្រូវការបច្ចុប្បន្នរបស់និស្សិតដែលកំពុងតែបន្តការសិក្សានៅក្នុងផ្នែកគណនេយ្យ ធនាគារ និងហិរញ្ញវត្ថុ សេដ្ឋកិច្ច និងគ្រប់សាធារណជនទាំងឡាយ។ ជាពិសេសនោះ គឺអ្នកវិនិយោគទាំងឡាយ ដែលលោកមានបំណង ឬចំណាប់អារម្មណ៍ទៅលើការការវិនិយោគក្នុងវិស័យមូលបត្រនេះផ្ទាល់។ យើងខ្ញុំនឹងធ្វើការបកស្រាយជូន ទៅតាមលទ្ធភាពដែលយើងខ្ញុំស្វែងរកបានដូចដែលបានធ្វើ ការចងក្រងនៅក្នុងអត្ថបទសារណាបញ្ចប់ការសិក្សាមួយនេះ។

យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះ នឹងផ្តល់ជាអត្ថប្រយោជន៍ច្រើនចំពោះមិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដែលមានគោលបំណងចង់សិក្សាស្វែងយល់ពីដំណើរការបោះផ្សាយ និងការជួញដូរភាគហ៊ុននៅកម្ពុជា និងទិន្នន័យពាក់ព័ន្ធការជួញដូរភាគហ៊ុន តាមត្រីមាសនីមួយៗនៅក្នុងឆ្នាំ២០២២ ក៏ដូចជាចំនួនក្រុមហ៊ុនដែលបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា។ យើងខ្ញុំសូមធ្វើការខន្តី អភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងទាំងអស់ដែលកើតមានឡើងដោយអចេតនា យើងខ្ញុំរីករាយក្នុង ការទទួលយកនូវរាល់បណ្តាមតិរិះគន់ទាំងអស់ ដើម្បីជាការស្តាបនាពីសំណាក់លោកអ្នកទាំងអស់គ្នា ជាពិសេសនោះ គឺមតិយោបល់ណែនាំពីសំណាក់លោកស្រី ហេង ច័ន្ទបូលីន ដើម្បីឲ្យសារណាបញ្ចប់ការសិក្សាមួយនេះ កាន់តែមានភាពល្អប្រសើរជាងមុន។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរអរគុណចំពោះមិត្តនិស្សិតអ្នកអាន និងសូមឲ្យមិត្តនិស្សិតទទួលបានជោគជ័យក្នុងការសិក្សាមានសុខភាពល្អ ដើម្បីបន្តជាសសរទ្រូងនៃប្រទេសជាតិយើង និងប្រើប្រាស់សារណាបញ្ចប់ការសិក្សាមួយនេះ ដើម្បីអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅប្រទេសកម្ពុជាយើង ឲ្យមានដំណើរការទៅមុខកាន់តែល្អថែមទៀត។

# មាតិកា

បញ្ជីអក្សរកាត់ ........ vi
បញ្ជីតារាង ........ vii
បញ្ជីរូបភាព ........ viii
បញ្ជីក្រាប ........ x

## សេចក្ដីផ្ដើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
៣. កម្មវត្ថុនៃការស្រាវជ្រាវ ........ ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១
## រំលឹកទ្រឹស្ដី

១.១. មូលបត្រ ........ ៦
១.១.១. និយមន័យមូលបត្រ ........ ៦
១.១.២. ប្រភេទនៃមូលបត្រ ........ ៦
១.១.២.១. មូលបត្រកម្មសិទ្ធិ ........ ៦
១.១.២.២. មូលបត្របំណុល ........ ៦
១.១.២.៣. ឧបករណ៍និស្សន្ទ ........ ៧
១.២. ប្រភេទនៃមូលបត្រកម្មសិទ្ធ ........ ៧
១.២.១. ភាគហ៊ុនធម្មតា ........ ៧
១.២.២. ភាគហ៊ុនបុរិមា ........ ៧
១.៣. ទីផ្សារមូលបត្រ ........ ៧
១.៣.១. និយមន័យនៃទីផ្សារមូលបត្រ ........ ៧

១.៣.២. ប្រវត្តិនៃទីផ្សារមូលបត្រ ....................................................................... ៨
១.៣.៣. ប្រភេទទីផ្សារមូលបត្រ ....................................................................... ១០
១.៣.៣.១. ទីផ្សារដំបូង ....................................................................... ១០
១.៣.៣.២. ទីផ្សារបន្ទាប់ ....................................................................... ១០
១.៤.២. គុណសម្បត្តិនៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ ....................................... ១២
១.៥. គុណវិបត្តិនៃទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច ....................................................... ១៣

## ជំពូកទី២

## ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

២.១. និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ....................................................................... ១៥
២.១.១. ប្រវត្តិសង្ខេបរបស់និយ័តករមូលបត្រកម្ពុជា ....................................................... ១៥
២.១.២. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា ....................................................... ១៥
២.១.៣. ចក្ខុវិស័យ និងបេសកកម្ម ....................................................................... ១៦
២.១.៤. រូបសញ្ញា អត្ថន័យនៃរូបសញ្ញា និងត្រារបស់និយ័តករមូលបត្រកម្ពុជា ..................... ១៧
២.១.៥. គោលដៅ និងគោលបំណងទូទៅនៃនិយ័តករមូលបត្រកម្ពុជា ................................ ១៩
២.១.៦. មុខងាររបស់និយ័តករមូលបត្រកម្ពុជា ....................................................... ២០
២.១.៧. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា ....................................................... ២០
២.១.៨. រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា ............................................ ២១
២.១.៩. ថ្នាក់ដឹកនាំបច្ចេកទេសរបស់និយ័តករមូលបត្រកម្ពុជា ........................................ ២១
២.១.១០ នាយកដ្ឋានរបស់និយ័តករមូលបត្រកម្ពុជា ....................................................... ២២
២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ....................................................................... ២៦
២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ............................................ ២៦
២.២.២. ចក្ខុវិស័យ និងបេសកកម្ម ....................................................................... ២៧
២.២.៣. បេសកម្ម ....................................................................... ២៨
២.២.៤. ទីតាំងរបស់ផ្សារមូលបត្រកម្ពុជា ....................................................................... ២៨
២.២.៥. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា ............................................ ២៩
២.២.៦. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ....................................................................... ២៩
២.២.៧. ក្រុមប្រឹក្សាភិបាល ....................................................................... ៣០

២.២.៨. ព័ត៌មានស្តីពីសមាជិកក្រុមប្រឹក្សាភិបាល ..................................................................... ៣០
២.៣.តួអង្គចូលរួមនៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើក ដំបូង ............. ៣១
២.៣.១. និយ័តករមូលបត្រកម្ពុជា ....................................................................................... ៣១
២.៣.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ................................................................................ ៣២
២.៣.៣. ក្រុមហ៊ុនមូលបត្រ ................................................................................................ ៣២
២.៣.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធ ...................................................................... ៣៤
២.៣.៤.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA) ................................................................ ៣៤
២.៣.៤.២. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (GTI) .................................................... ៣៥
២.៣.៤.៣. កំពង់ផែស្វយ័តក្រុងភ្នំពេញ (PPAP) ..................................................................... ៣៦
២.៣.៤.៤.ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិតភីអិលស៊ី (PPSP) ....................................................... ៣៧
២.៣.៤.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PASP) ............................................................... ៣៨
២.៣.៤.៦. ធនាគារអេស៊ីលីដា ភីអិលស៊ី (ABC) ..................................................................... ៣៩
២.៣.៤.៧. ក្រុមហ៊ុន ផេកចិក (ខេមបូឌា) ម.ក. (PEPC) ......................................................... ៤០
២.៣.៤.៨. ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក. (DBDE) ........................................................ ៤១
២.៣.៤.៩. ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី (JSL) ................................................................ ៤២
២.៣.៥. វិនិយោគិន ........................................................................................................... ៤២
២.៣.៦. តួអង្គចូលរួមដទៃទៀត .......................................................................................... ៤៣

## ជំពូកទី៣

## ការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា

៣.១. ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ (ភាគហ៊ុន) ជាសាធារណៈលើកដំបូង ........................ ៤៨
៣.១.១. លក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ......................................................................................................... ៤៨
៣.១.២. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ................................................... ៥០
៣.២. ដំណើរការជួញដូរភាគហ៊ុននៅក្នុងផ្សារមូលបត្រកម្ពុជា ........................................................ ៥៣
៣.២.១. ដំណាក់កាលដំបូងមុននឹងការចាប់ផ្តើមជួញដូរមូលបត្រ ................................................ ៥៣
៣.២.១.១. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ................................................................ ៥៤
៣.២.១.២. ការបើកគណនីជួញដូរ ........................................................................................ ៥៤

៣.២.១.៣. ការស្វែងយល់ពីច្បាប់ និងមូលដ្ឋានគ្រឹះក្នុងការជួញដូរ.................................................. ៥៥
៣.២.២. ប្រតិបត្តិការទីផ្សារ.......................................................................................................... ៥៥
៣.២.២.១. ថ្ងៃ និងម៉ោងជួញដូរ..................................................................................................... ៥៥
៣.២.២.២. ប្រភេទបញ្ជា ................................................................................................................ ៥៦
៣.២.២.៣. ការដាក់បញ្ជាទិញ និងលក់ ........................................................................................... ៥៨
៣.២.២.៤. ព័ត៌មានលម្អិតនៃបញ្ជា................................................................................................. ៥៩
៣.២.២.៥. ឯកតាបញ្ជា និង ឯកតាគម្លាតថ្លៃ ..................................................................................... ៥៩
៣.២.២.៦. ថ្លៃមូលដ្ឋាន ................................................................................................................. ៦០
៣.២.២.៧. ថ្លៃពិសេស .................................................................................................................. ៦១
៣.២.២.៨. វិធីសាស្ត្រជួញដូរភាគហ៊ុន ............................................................................................៦២
៣.២.២.៩.  នីតិវិធីក្នុងការបើកគណនី និងនីតិវិធីក្នុងការជួញដូរ........................................................៦៣
៣.២.៣. ប្រតិបត្តិការផាត់ទាត់ និងទូទាត់ ...................................................................................... ៦៥
៣.២.៣.១. ការផាត់ទាត់................................................................................................................ ៦៥
៣.២.៣.២. ការទូទាត់ ................................................................................................................... ៦៦
៣.២.៣.៣. តួអង្គសំខាន់ៗនៅក្នុងយន្តការនៃការផាត់ទាត់ និងទូទាត់ ..............................................៦៧
៣.២.៣.៤. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់...................................................... ៦៨
៣.២.៣.៥. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ......................................................... ៦៩
៣.២.៤. ប្រតិបត្តិការនៃការរក្សាទុកមូលបត្រ.................................................................................. ៦៩
៣.៣. ទិដ្ឋភាពទូទៅនៃការបោះផ្សាយ និងការជួញដូរភាគហ៊ុន ..............................................................៧០
៣.៣.១. ចំនួនក្រុមហ៊ុនបោះផ្សាយលក់ភាគហ៊ុន .............................................................................៧០
៣.៣.២. តម្លៃបោះផ្សាយលក់ភាគហ៊ុនជាសាធារណៈលើកដំបូង និងចំនួនភាគហ៊ុនដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈ......................................................................................................................៧២
៣.៣.៣. ចំនួនភាគហ៊ុនចុះបញ្ជីសរុប និងមូលធនូបនីយកម្មទីផ្សារ....................................................៧៤
៣.៣.៤. ទិន្នន័យសំខាន់ៗទាក់ទងការជួញដូរភាគហ៊ុន......................................................................៧៤
៣.៣.៤.១. បរិមាណបញ្ជាទិញ -  លក់...............................................................................................៧៥
៣.៣.៤.២. ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ....................................................៧៦
៣.៣.៤.៣. ចំនួនវិនិយោគិនសរុបប្រចាំត្រីមាសទី១ ដល់ត្រីមាសទី៤............................................... ៧៧

៣.៣.៤.៤. ការជួញដូរតាមប្រភេទវិនិយោគិន (សញ្ជាតិខ្មែរ និងសញ្ជាតិបរទេស).............................៧៨
៣.៣.៤.៥. ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល)....................................៧៩
៣.៣.៤.៦. ការជួញដូរតាមប្រភេទវិនិយោគិន (ភេទស្រី និងភេទប្រុស) ........................................ ៨០
៣.៣.៤.៧. ចំនួននៃការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ប្រចាំត្រីមាសទាំង៤ ក្នុងឆ្នាំ ២០២២....... ៨១

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................................................................................ ៨២
២. អនុសាសន៍........................................................................................................................៨៣
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ម.ក. ៖ គណៈកម្មការមូលបត្រកម្ពុជា

ន.ម.ក. ៖ និយ័តករមូលបត្រកម្ពុជា

ផ.ម.ក. ៖ ផ្សារមូលបត្រកម្ពុជា

NYSE ៖ New York Stock Exchange

NASDAQ ៖ National Association of Securities Dealers Automated Quotations

OTC ៖ Over the Counter

CSX ៖ Cambodia Securities Exchange

IPO ៖ Initial Public Offering

MTS ៖ Mobile Trading System

ATM ៖ Automated Teller Machine

NTM ៖ Negotiated Trading Method

CCP ៖ Central Counter Party

CSO ៖ Clearing and Settlement Operator

CSD ៖ Central Securities Depository

SF ៖ Securities Firm

CSA ៖ Cash Settlement Agent

NBC ៖ National Bank of Cambodia

# បញ្ជីតារាង

ទំព័រ

តារាង២.១៖ ថ្នាក់ដឹកនាំនៃបច្ចេកទេសរបស់និយ័តករមូលបត្រកម្ពុជា ២២
តារាង២.២៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PWSA ៣៤
តារាង២.៣៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង GTI ៣៥
តារាង២.៤៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPAP ៣៦
តារាង២.៥៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PPSP ៣៧
តារាង២.៦៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PAS ៣៨
តារាង២.៧៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ABC ៣៩
តារាង២.៨៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង PEPC ៤០
តារាង២.៩៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង DBDE ៤១
តារាង២.១០៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង JSL ៤២
តារាង៣.១៖ លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ៤៩
តារាង៣.២៖ លក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ៥០
តារាង៣.៣៖ ពេលវេលានៃការជួញដូរ ៥៦
តារាង៣.៤៖ ប្រភេទបញ្ជា ៥៨
តារាង៣.៥៖ ឯកតាបញ្ជា និង ឯកតាគម្លាតថ្លៃ ៦០
តារាង៣.៦៖ ថ្លៃពិសេស ៦១
តារាង៣.៧៖ វិធីសាស្ត្រដេញថ្លៃ ៦២
តារាង៣.៨៖ តម្លៃបោះផ្សាយលក់ភាគហ៊ុន និងចំនួនភាគហ៊ុនដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង ៧២

# បញ្ជីរូបភាព

ទំព័រ


រូបភាព២.១. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា........១៦
រូបភាព២.២. រូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជា........១៨
រូបភាព២.៣. ត្រារបស់និយ័តករមូលបត្រកម្ពុជា........១៩
រូបភាព២.៤. រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា........២១
រូបភាព២.៥. ទីតាំងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា........២៨
រូបភាព២.៦. ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា........២៩
រូបភាព២.៧. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា........២៩
រូបភាព២.៨. រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា........៣០
រូបភាព២.៩. ក្រុមប្រឹក្សារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា........៣១
រូបភាព២.១០. ស្លាកសញ្ញា PWAS........៣៤
រូបភាព២.១១. ស្លាកសញ្ញា GTI........៣៥
រូបភាព២.១២. ស្លាកសញ្ញា PPAP........៣៦
រូបភាព២.១៣. ស្លាកសញ្ញា PPSP........៣៧
រូបភាព២.១៤.ស្លាកសញ្ញា PASP........៣៨
រូបភាព២.១៥. ស្លាកសញ្ញា ABC........៣៩
រូបភាព២.១៦. ស្លាកសញ្ញា PEPC........៤០
រូបភាព២.១៧. ស្លាកសញ្ញា DBDE........៤១
រូបភាព២.១៨. ស្លាកសញ្ញា JSL........៤២
រូបភាព៣.១. យន្តការទីផ្សារដំបូង........៥២
រូបភាព៣.២. ដំណើរការជួញដូរភាគហ៊ុននៅក្នុងផ្សារមូលបត្រកម្ពុជា........៥៣
រូបភាព៣.៣. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ........៦៤
រូបភាព៣.៤. ការផាត់ទាត់........៦៥
រូបភាព៣.៥. Central Counter-Party(CCP)........៦៦
រូបភាព៣.៦. ការទូទាត់........៦៧
រូបភាព៣.៧. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់........៦៨

រូបភាព៣.៨. ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ......................................................................៦៨
រូបភាព៣.៩. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់.......................................................................៦៩
រូបភាព៣.១០. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ.......................................................................៦៩

# បញ្ជីក្រាប


ទំព័រ

ក្រាហ្វិចទី១៖ ចំនួនក្រុមហ៊ុនបោះផ្សាយភាគហ៊ុនពីឆ្នាំ២០១២ ដល់២០២២..........................................៧១

ក្រាហ្វិចទី២៖ តម្លៃបោះផ្សាយលក់ភាគហ៊ុន និងចំនួនភាគហ៊ុនបោះផ្សាយ..........................................៧៣

ក្រាហ្វិចទី៣៖ ចំនួនភាគហ៊ុនចុះបញ្ជីសរុប និងមូលធនរូបនីយកម្មទីផ្សារ (លានដុល្លារ)..........................៧៤

ក្រាហ្វិចទី៤ ៖ បរិមាណបញ្ជាទិញ–លក់..........................................................................................៧៥

ក្រាហ្វិចទី៥៖ ទំហំជួញដូរភាគហ៊ុន និងតម្លៃជួញដូរ(លានដុល្លារអាមេរិក) ឆ្នាំ២០២២..........................៧៦

ក្រាហ្វិចទី៦៖ ចំនួនវិនិយោគិនសរុបប្រចាំត្រីមាសទី១ ដល់ត្រីមាសទី៤..................................................៧៧

ក្រាហ្វិចទី៧៖ ការជួញដូរតាមប្រភេទវិនិយោគិន (សញ្ជាតិខ្មែរ និងសញ្ជាតិបរទេស) ឆ្នាំ២០២២................៧៨

ក្រាហ្វិចទី៨៖ ការជួញដូរតាមប្រភេទវិនិយោគិន(រូបវន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០២២.........................៧៩

ក្រាហ្វិចទី៩៖ ការជួញដូរតាមប្រភេទវិនិយោគិន(ភេទប្រុស និងភេទស្រី) ឆ្នាំ២០២២..............................៨០

ក្រាហ្វិចទី១០៖ ចំនួននៃការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ប្រចាំត្រីមាសទាំង៤ ក្នុងឆ្នាំ២០២២.........៨១

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីប្រទេសកម្ពុជាយើងបានឆ្លងកាត់សម័យកាលសង្គ្រាមរ៉ាំរ៉ៃជាច្រើនទសវត្សកន្លងរួចមក ប្រទេសកម្ពុជាបានកែប្រែខ្លួនក្លាយមកជាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងរយៈពេលខ្លី។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាល បានខិតខំស្វះស្វែង និងរិះរកវិធីសាស្ត្រក្នុងការវិវត្តន៍ខ្លួន ឲ្យចាកចេញពីសភាពជាប្រទេសក្រីក្រ។ វិស័យហិរញ្ញវត្ថុប្រៀបបានដូចទៅនឹងសរសៃឈាមនៃចរន្តសេដ្ឋកិច្ចជាតិ ហើយនៅក្នុងវិស័យហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា មានដូចជា វិស័យធនាគារ និងវិស័យមូលបត្រ ដែលវិស័យមូលបត្រនេះជាវិស័យមួយ ទើបតែមានដំណើរការរីកដុះដាលនាពេលបច្ចុប្បន្ន។ វិស័យមូលបត្រ ជាវិស័យមួយដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងតែមានការយកចិត្តទុកដាក់យ៉ាងខ្លាំងដោយហេតុថា វិស័យនេះនៅមានការខ្វះខាតធនធានបច្ចេកទេស និងធនធានមនុស្ស ជាដើម។ ដោយឡែក ការរីកចម្រើននៅក្នុងវិស័យមួយនេះ គឺជាការសរបញ្ជាក់អំពីភាពល្អប្រសើរឡើងនៃសេដ្ឋកិច្ចជាតិរបស់ប្រទេសមួយ ដែលជាកត្តានាំឲ្យមានវិនិយោគិន មកធ្វើការវិនិយោគនៅក្នុងស្រុក។ ហេតុដូចនេះហើយបានជារាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែង នៅក្នុងវិស័យនេះក៏ដូចជាបានអនុវត្តនូវប្រព័ន្ធទីផ្សារសេរីក្នុងការគៀរគរមូលធនពីបណ្តាអ្នកវិនិយោគិនមកពីបណ្តាប្រទេសទាំងក្នុង និងក្រៅអាស៊ាន។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតស្ថាប័នមួយដែលមានតួនាទីគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការគៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា គឺនិយ័តករមូលបត្រកម្ពុជា។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើង ដើម្បីដាក់ឲ្យដំណើរការប្រព័ន្ធជួញដូរមូលបត្រ ប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រព័ន្ធរក្សាទុកមូលបត្រ។

សរុបជារួមមកឃើញថា វិស័យមូលបត្រគឺជាកត្តាលីករមួយយ៉ាងសំខាន់ ក្នុងដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស។ វិស័យមូលបត្រនេះ ក៏បានចូលរួមចំណែកក្នុងការជួយស្ថានភាពហិរញ្ញវត្ថុរបស់ប្រទេស ដោយបានធ្វើឲ្យប្រជាពលរដ្ឋអាចរកចំណូលបន្ថែមក្រៅពីប្រាក់ចំណូលគោលរបស់ពួកគាត់ប្រចាំថ្ងៃ ហើយនៅពេលបច្ចុប្បន្ន យើងសង្កេតឃើញថាប្រជាពលរដ្ឋកម្ពុជា មានការចាប់អារម្មណ៍ និងយល់ដឹងអំពីវិស័យមូលបត្រនេះកាន់តែកើនឡើង ហើយក៏បានចូលប្រឡូកនៅក្នុងវិស័យមួយនេះផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រ គឺជាវិស័យដែលត្រូវបានគេចាត់ទុកថាជាកម្លាំងមួយ ក្នុងការជួយជ្រោមជ្រែងវិស័យសេដ្ឋកិច្ចជាតិឲ្យមានការរីកលូតលាស់យ៉ាងល្អ។ យើងសង្កេតឃើញថាចំនួនក្រុមហ៊ុនដែលបានចុះបញ្ជីនៅផ្សារ

មូលបត្រមានចំនួនតិចតួច ចំណែកឯវិនិយោគិន ដែលចូលរួមក្នុងសកម្មភាពជួញដូរនៅមានកម្រិតនៅឡើយ ទាំងនេះអាចបណ្តាលមកពីក្រុមហ៊ុន ឬសហគ្រាស មិនទាន់ស្វែងយល់ពីអត្ថប្រយោជន៍នៃទីផ្សារមូលបត្រ លក្ខខណ្ឌតម្រូវ ក៏ដូចជាដំណើរការនៃការបោះផ្សាយ ជាមួយគ្នានេះដែរ សាធារណជនដែលមានបំណងវិនិយោគ តាមរយៈការទិញមូលបត្ររបស់ក្រុមហ៊ុនចុះបញ្ជីនៅផ្សារមូលបត្រ នៅខ្វះខាតចំណេះដឹងពាក់ព័ន្ធការជួញដូរ ដើម្បីឲ្យស្រមនឹងវិធានទីផ្សារ។

ដោយមានការយល់ឃើញអំពីចំណុចខ្វះខាតទាំងអស់នេះហើយ ទើបយើងខ្ញុំជ្រើសរើសយកប្រធានបទ «ការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា» យកមកធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយទៅលើបញ្ហាទាំងអស់នេះ។ ដើម្បីសម្រេចបាននូវគោលបំណងរបស់សារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំនឹងធ្វើការឆ្លើយតបនូវសំណួរដូចខាងក្រោម៖

- តើមានអត្ថប្រយោជន៍អ្វីខ្លះដែលក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាវិនិយោគិន ទទួលបានពីទីផ្សារមូលបត្រ?
- តើក្រុមហ៊ុនត្រូវត្រៀមខ្លួន និងរៀបចំអ្វីខ្លះក្នុងការនៃការបោះផ្សាយភាគហ៊ុនជាសាធារណៈលើកដំបូង?
- តើការទិញ លក់ភាគហ៊ុននៅលើផ្សារមូលបត្រកម្ពុជាមានដំណើរការយ៉ាងដូចម្តេច?
- តើក្រុមហ៊ុនបោះផ្សាយលក់ភាគហ៊ុនមានចំនួនប៉ុន្មាន គិតចាប់ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០២២ និងសកម្មភាពជួញដូរភាគហ៊ុនមានស្ថានភាពយ៉ាងដូចម្តេចនៅឆ្នាំ ២០២២?

## ៣. កម្មវត្ថុនៃការស្រាវជ្រាវ

កម្មវត្ថុសម្រាប់ការស្រាវជ្រាវនេះ គឺធ្វើឡើងដើម្បីសិក្សាស្វែងយល់ និងផ្តោតសំខាន់ទៅលើប្រធានបទ «ការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា» ដោយមានគោលបំណងចម្បងៗសំខាន់មួយចំនួនដូចខាងក្រោមនេះ៖

- សិក្សាស្វែងយល់អំពីអត្ថប្រយោជន៍ ដែលក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាវិនិយោគិន ទទួលបានពីទីផ្សារមូលបត្រ
- សិក្សាស្វែងយល់អំពីការត្រៀមខ្លួន និងនីតិវិធីដែលក្រុមហ៊ុនត្រូវអនុវត្តនៅក្នុងការបោះផ្សាយភាគហ៊ុននៅកម្ពុជា
- សិក្សាស្វែងយល់អំពីដំណើរការទិញ និងលក់ភាគហ៊ុន ដំណើរការជាត់ទាត់ និងទូទាត់ និងរក្សាទុកមូលបត្រនៅផ្សារមូលបត្រកម្ពុជា
- សិក្សាស្វែងយល់អំពីចំនួនក្រុមហ៊ុនបោះផ្សាយលក់ភាគហ៊ុន គិតចាប់ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០២២ និងសកម្មភាពជួញដូរភាគហ៊ុននៅឆ្នាំ ២០២២។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ នៅផ្សារមូលបត្រកម្ពុជា មានផលិតផល២ គឺ មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) និងមូលបត្របំណុល (សញ្ញាបណ្ណ) ត្រូវបានជួញដូរនៅក្នុងផ្សារមូលបត្រ ប៉ុន្តែនៅក្នុងសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំគឺផ្តោតសំខាន់តែទៅលើ ការបោះផ្សាយ និង ការជួញដូរមូលបត្រកម្មសិទ្ធនៅផ្សារមូលបត្រកម្ពុជាតែប៉ុណ្ណោះ។ ម្យ៉ាងទៀត ការសិក្សានេះប្រើប្រាស់តែទិន្នន័យនៃការបោះផ្សាយលក់ភាគហ៊ុន ពីឆ្នាំ២០១២ ដល់ឆ្នាំ ២០២២ និងទិន្នន័យសំខាន់ៗពាក់ព័ន្ធនឹងការជួញដូរភាគហ៊ុន ចំនួន៤ត្រីមាសនៃឆ្នាំ២០២២។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៅក្នុងការសរសេរសារណានេះ គឺធ្វើទៅតាមវិធីសាស្ត្របែបពណ៌នា ដោយមានការរៀបរាប់អំពីនីតិវិធីនៃការបោះផ្សាយ ក៏ដូចជា ការជួញដូរភាគហ៊ុន ដំណើរការផាត់ទាត់ និងទូទាត់ និងរក្សាទុកមូលបត្រ ដែលទិន្នន័យលើកយកមកប្រើប្រាស់ជាទិន្នន័យដែលមានស្រាប់ និងមានប្រភពមកពី ៖

- ច្បាប់ អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំផ្សេងៗរបស់និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឯកសារមេរៀនដែលទាក់ទងនឹងការបោះផ្សាយ និងជួញដូរភាគហ៊ុន
- ឯកសារបោះពុម្ពជាភាសាខ្មែរ ដូចជា ពុទ្ធិមូលបត្រ ព្រឹត្តិបត្រទិន្នន័យនៃការជួញដូរ ដែលទាក់ទងទៅនឹងការបោះផ្សាយ និងការជួញដូរភាគហ៊ុននៅកម្ពុជា
- ទិន្នន័យផ្សេងៗដែលមាននៅក្នុងគេហទំព័រផ្លូវការរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។

## ៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវអំពីប្រធានបទដែលទាក់ទងទៅនឹងការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជាមានសារៈសំខាន់ និងបានផ្តល់ជាផលប្រយោជន៍ផ្សេងៗជាច្រើនដូចជា៖

- **សម្រាប់យើងខ្ញុំផ្ទាល់ដែលជាអ្នកសិក្សាស្រាវជ្រាវ៖**
  - ទទួលបានចំណេះដឹងបន្ថែមដែលទាក់ទងទៅនឹងវិស័យមូលបត្រ
  - ស្គាល់នូវពាក្យបច្ចេកទេសថ្មីៗដែលមាននៅក្នុងវិស័យមូលបត្រ
  - មានការយល់ដឹង បង្កើនសមត្ថភាពក្នុងស្វែងរកទិន្នន័យ ប្រភពឯកសារនានា និងចេះពីរបៀបរបបនៃការសរសេរសារណា និងការធ្វើការស្រាវជ្រាវផ្សេងៗ
  - អាចទុកជាស្នាដៃមួយសម្រាប់ឲ្យប្អូនៗនិស្សិតជំនាន់ក្រោយយកទៅមើល និងសិក្សាបាន។
- **សម្រាប់ក្រុមហ៊ុនដែលគាត់មានបំណងចង់ធ្វើការបោះផ្សាយភាគហ៊ុន៖**

- ➢ យល់ដឹងអំពីច្បាប់ លក្ខខណ្ឌ និងបទប្បញ្ញត្តិនានា ដែលទាក់ទងទៅនឹងការបោះផ្សាយភាគហ៊ុន នៅក្នុងប្រទេសកម្ពុជា
- ➢ យល់ដឹងអំពីឯកសារ និងព័ត៌មានសាជីវកម្មដែលក្រុមហ៊ុនត្រូវធ្វើការបង្ហាញ

❖ **សម្រាប់អ្នកសិក្សាស្រាវជ្រាវ វិនិយោគិន និងសាធារណជន ៖**

- ➢ ទុកជាឯកសារ និងព័ត៌មានជូនដល់អ្នកសិក្សាស្រាវជ្រាវ វិនិយោគិន និងសាធារណជន ដែលមានបំណងចង់ធ្វើការសិក្សាស្វែងយល់អំពី ការបោះផ្សាយ និង ជួញដូរភាគហ៊ុននៅកម្ពុជា
- ➢ ទទួលបានព័ត៌មានទាក់ទងនឹងទិដ្ឋភាពទូទៅនៃការបោះផ្សាយលក់ភាគហ៊ុនពី ឆ្នាំ២០១២ ដល់ឆ្នាំ ២០២២ និងទិន្នន័យសំខាន់ៗពាក់ព័ន្ធនឹងការជួញដូរភាគហ៊ុនចំនួន៤ត្រីមាសនៃឆ្នាំ ២០២២។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាការងាយស្រួលជូនចំពោះមិត្តអ្នកអាន និងបណ្ដាអ្នកស្រាវជ្រាវទាំងឡាយ សារណានេះត្រូវបានបែងចែកជាជំពូកដូចខាងក្រោម ៖

- **សេចក្ដីផ្ដើម៖**
  បង្ហាញអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ កម្មវត្ថុនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី១៖ រំលឹកទ្រឹស្ដី**
  នៅក្នុងជំពូកនេះ បង្ហាញអំពីការលើកឡើង និងរំលឹកនូវទ្រឹស្ដីផ្សេងៗដែលទាក់ទងទៅនឹងប្រធានបទរួមមានដូចជា និយមន័យមូលបត្រ ប្រភេទនៃមូលបត្រកម្មសិទ្ធិ ទីផ្សារមូលបត្រ គុណសម្បត្តិនៃទីផ្សារមូលបត្រ និងគុណវិបត្តិនៃទីផ្សារមូលបត្រ។
- **ជំពូកទី២៖ ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនមូលបត្រកម្ពុជា**
  នៅក្នុងជំពូកនេះ បង្ហាញអំពី ប្រវត្តិសង្ខេបនៃនិយ័តករមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា តួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ វិនិយោគិន និងតួអង្គចូលរួមទៃទៀត។
- **ជំពូកទី៣៖ ដំណើរការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា**

នៅក្នុងជំពូកនេះ បង្ហាញអំពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈលើកដំបូង ដំណើរការក្នុងការជួញដូរភាគហ៊ុននៅក្នុងផ្សារមូលបត្រ និងទិដ្ឋភាពទូទៅនៃការបោះផ្សាយ និងការជួញដូរភាគហ៊ុន។

- **សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍**

## រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. មូលបត្រ

### ១.១.១. និយមន័យមូលបត្រ

មូលបត្រ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលអាចធ្វើការជួញដូរ ឬទិញ-លក់នៅក្នុងទីផ្សារមូលបត្រ។ មូលបត្រត្រូវបានបែងចែកជាបីប្រភេទធំៗគឺ មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) មូលបត្របំណុល(សញ្ញាបណ្ណ) និងឧបករណ៍និស្សន្ទ។

❖ **ចំណុចពិសេសមូលបត្រនៅក្នុងទីផ្សារមូលបត្រ**

នៅក្នុងទីផ្សារមូលបត្រ មានចំណុចពិសេសមួយចំនួនដូចជា៖

- គឺជាបណ្ណាក្រដាសដែលបញ្ជាក់អំពីតម្លៃទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិ
- គឺជាឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី មធ្យម និងវែង
- ត្រូវបានការការពារពីច្បាប់មូលបត្រ
- ត្រូវបានអនុញ្ញាតឲ្យដោះដូរផ្ទេរកម្មសិទ្ធនៅលើទីផ្សារមូលបត្រ ដែលមានន័យថា Liquidity ខ្ពស់។[1]

### ១.១.២. ប្រភេទនៃមូលបត្រ

#### ១.១.២.១. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ គឺជាមូលបត្រដែលត្រូវបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីធ្វើការកៀរគរមូលនិធិពីសាធារណជន។ ភាពជាម្ចាស់កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិ នឹងផ្តល់សិទ្ធិទៅភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញនៃក្រុមហ៊ុនតាមរយៈភាគលាភ។[2]

#### ១.១.២.២. មូលបត្របំណុល

មូលបត្របំណុល ឬសញ្ញាបណ្ណ គឺជាមូលបត្រមួយប្រភេទដែលតំណាងឲ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។តាមរយៈកិច្ចសន្យានេះបុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឲ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើម នៅពេលដែលសញ្ញាបណ្ណនេះដល់កាលកំណត់សងដែលគេហៅថា"ឥណប្រតិទាន"។[3]

---

[1] សួន ចំរើន (២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ ទំព័រ ៣៥-៣៦

[2] http://csx.com.kh/kh/product/equities.jsp?MNCD=4020 (ចូលមើលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣)

[3] http://csx.com.kh/kh/product/bond.jsp?MNCD=4040 (ចូលមើលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣)

#### ១.១.២.៣. ឧបករណ៍និស្សន្ទ

ឧបករណ៍និស្សន្ទ សំដៅទៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឲ្យបុគ្គលណាមួយដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញ-លក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគតដោយមិនគិតថាបុគ្គលនោះមានបំណងប្រើសិទ្ធិ ឬមិនប្រើសិទ្ធិនោះក៏ដោយ។

### ១.២. ប្រភេទនៃមូលបត្រកម្មសិទ្ធ

មូលបត្រកម្មសិទ្ធិ គឺជាមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីកៀរគរមូលនិធិពីសាធារណជន។ មូលបត្រកម្មសិទ្ធិចែកចេញជាពីរប្រភេទគឺៈ

#### ១.២.១. ភាគហ៊ុនធម្មតា

ភាគហ៊ុនធម្មតា គឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចចិត្ត ក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។ មួយវិញទៀតម្ចាស់ភាគហ៊ុនធម្មតា មានសិទ្ធិក្នុងការចូលរួមបោះឆ្នោតផ្សេងៗក្នុងក្រុមហ៊ុនដូចជា ការបោះឆ្នោជ្រើសរើសគណៈគ្រប់គ្រងជាដើម។

#### ១.២.២. ភាគហ៊ុនបុរិមា

ភាគហ៊ុនបុរិមា គឺជាភាគហ៊ុនមួយប្រភេទ ដែលអ្នកកាន់កាប់ភាគហ៊ុនបុរិមា នឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនអ្នកកាន់កាប់ភាគហ៊ុនធម្មតា។ ក៏ប៉ុន្តែម្ចាស់ភាគហ៊ុនបុរិមាមិនមានសិទ្ធិ ចូលរួមក្នុងការបោះឆ្នោតក្នុងក្រុមហ៊ុនដូចទៅនឹងម្ចាស់ភាគហ៊ុនធម្មតាទេ។[4]

### ១.៣. ទីផ្សារមូលបត្រ

#### ១.៣.១. និយមន័យនៃទីផ្សារមូលបត្រ

ផ្សារមូលបត្រ ជាកន្លែងដែលមូលបត្រដូចជា ភាគហ៊ុន និងសញ្ញាបណ្ណ ត្រូវបានទិញ និងលក់។ យោងទៅតាមនិយមន័យបានចែងនៅក្នុងច្បាប់ស្តីអំពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ទីផ្សារមូលបត្រសំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ផ្ទេរ ឬធ្វើការទិញ-លក់មូលបត្រ ឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមាន មូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទ។[5]

---

[4] http://csx.com.kh/kh/product/equities.jsp?MNCD=4020 (ចូលមើលថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣)

[5] http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1 (ចូលទស្សនា ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣)

ទីផ្សារមូលបត្រដើរតួយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិរួមមាន៖

១. ទីផ្សារមូលបត្រ ជួញជម្រុញឲ្យមហាជនបង្កើនការសន្សំ និងកៀរគរនូវមូលនិធិនៅសេសសល់មិនទាន់មានតម្រូវការក្នុងការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។

២. ទីផ្សារមូលបត្រ គឺជាមធ្យោបាយក្នុងការប្រមូលកៀរគរប្រភពមូលធនដែលទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ពួនផ្តុំជាមូលធនធំមួយ ដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវ័ន្ត។

៣. ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ។

៤. ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស។

៥. ទីផ្សារមូលបត្រជួយជម្រុញឲ្យបណ្តាក្រុមហ៊ុននានាប្រកបអាជីវកម្មដោយប្រសិទ្ធិភាព និងមានតម្លាភាព។

៦. ទីផ្សារមូលបត្រជួយជម្រុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរណ៍ ឬចលនារស់រវើក។

៧. ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាប់នៃការវិនិយោគ។[6]

### ១.៣.២. ប្រវត្តិនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ត្រូវបានបង្កើតឡើងតាំងពីយូរលង់ណាស់មកហើយ ហើយត្រូវបានគេនិយមហៅថាជាទីផ្សារភាគហ៊ុន។ ទីផ្សារភាគហ៊ុន គឺជាផ្នែកមួយយ៉ាងសំខាន់នៃសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្ន។ មិនតែប៉ុណ្ណោះ វាក៏ជាកាតាលីករមួយក្នុងការជួយជម្រុញឲ្យមានកំណើនសេដ្ឋកិច្ចផងដែរ។ ទីផ្សារភាគហ៊ុន មិនមានរូបរាងពិតប្រាកដនោះទេគិតត្រឹមសតវត្សទី១៥ ប៉ុន្តែគេសង្កេតឃើញមានការជួញដូរឧបករណ៍មួយចំនួននៃទីផ្សារដំបូងដែលមានលក្ខណៈស្រដៀងនឹងភាគហ៊ុនដែរ។ នៅឆ្នាំ១១០០ ប្រទេសបារាំងមានប្រព័ន្ធមួយដែលគ្រប់គ្រងនូវរាល់បំណុលកសិកម្មទូទាំងប្រទេសជំនួសឲ្យធនាគារ។ ក្រោយមកពាណិជ្ជករនៅទីក្រុងវេណាយ (Venice) ត្រូវបានគេរកឃើញថា មានការជួញដូរមូលបត្ររដ្ឋាភិបាលតាំងពីដើមសតវត្សទី១៣។ មិនយូរប៉ុន្មានគេក៏បានឃើញថាមានការជួញដូរមូលបត្ររដ្ឋាភិបាលនៅទីប្រជុំជនជិតខាងប្រទេសអ៊ីតាលី។

ក្រុមហ៊ុន East India Company ត្រូវបានគេទទួលស្គាល់ទូទៅថា ជាក្រុមហ៊ុនពាណិជ្ជកម្មសាធារណៈដំបូងបង្អស់នៅលើពិភពលោក ដែលជាក្រុមហ៊ុនឯកជនមួយទទួលបានសិទ្ធិក្នុងការរកស៊ីពីព្រះមហាក្សត្រយានីអេលីសាប៉ែតទី១ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៦០០។ ក្រុមហ៊ុននេះកើតចេញពីអាជីវករមួយក្រុម នៅទីក្រុងដែលធ្វើជំនួញ ទិញគ្រឿងទេស តាមកោះនានានៅក្នុងប្រទេសឥណ្ឌូនេស៊ីសព្វថ្ងៃ។ ចំណែកឯមធ្យោបាយធ្វើដំណើរតាមផ្លូវទឹក នាពេលនោះមានហានិភ័យខ្ពស់ណាស់ មានកប៉ាល់ជាច្រើនដែលធ្វើដំណើរចេញទៅជួបគ្រោះថ្នាក់តាម

[6] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលមើលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣)

ផ្លូវ ដែលធ្វើឲ្យវិនិយោគិនខាតបង់ប្រាក់ទៅលើកប៉ាល់ទាំងអស់នោះ។ ក្រុមហ៊ុន EastIndiaCompany បានរកឃើញនូវ មធ្យោបាយមួយគឺ វិនិយោគិនអាចទិញភាគហ៊ុនពីម្ចាស់កប៉ាល់ជំនួសឲ្យការវិនិយោគលើកប៉ាល់មួយទាំងមូល។ ពោលគឺប្រសិនបើកប៉ាល់មួយ ត្រូវបានបាត់បង់ក្នុងចំណោមកប៉ាល់៣ ឬ៤ក៏វិនិយោគិននូវតែអាចរកប្រាក់ចំនេញបានដែរ។ និយាយជារួម វិនិយោគិនអាចទិញនូវភាគហ៊ុន ឬមូលបត្របំណុលពីក្រុមហ៊ុន East India Company ហើយវិនិយោគិនទទួលបាននូវភាគរយថេរនៃប្រាក់ចំនេញរបស់ក្រុមហ៊ុន East India Company។ រូបមន្តដំណោះស្រាយនេះទទួលជោគជ័យយ៉ាងខ្លាំង ហើយត្រូវបានបណ្តាក្រុមហ៊ុនតាមបណ្តាប្រទេសដូចជាប្រទេស អង់គ្លេស បារាំង ប៊ែលហ្សិក និងហូឡង់យកគំរូតាម។

ហាងកាហ្វេ គឺជាទីតាំងជួញដូរភាគហ៊ុននាពេលនោះ ដោយសារតែវិនិយោគិនមកពីគ្រប់ទិសទីមកហាងកាហ្វេនេះ ដើម្បីធ្វើការទិញ និងលក់ភាគហ៊ុន។ ក្រោយមកពិភពជំនួញនេះ កាន់តែមានប្រសិទ្ធិភាពជាងមុន បើមានទីតាំងទីផ្សារច្បាស់លាស់ នោះវិនិយោគិនមិនចាំបាច់មកហាងកាហ្វេ ដែលមានមនុស្សច្រើននេះទេ។ នាឆ្នាំ១៨០១ ផ្សារហ៊ុនក្រុងឡុងដ៍ (London Stock Exchange) ត្រូវបានបង្កើតឡើងជាផ្លូវការ។ ដោយឡែកមុនឆ្នាំ១៨២៥ ក្រុមហ៊ុននានាមិនត្រូវបានអនុញ្ញាតឲ្យដាក់លក់ ភាគហ៊ុននៅក្នុងផ្សារមូលបត្រក្រុងឡុងដ៍ទេ ដោយមានការលេចចេញ នូវការបង្កើតផ្សារហ៊ុនញូវយ៉ក (New York Stock Exchange) ក្នុងឆ្នាំ១៨១៧ ដែលផ្សារហ៊ុនក្រុងឡុងដ៍ គឺជាទីផ្សារភាគហ៊ុនសំខាន់សម្រាប់ទ្វីបអឺរ៉ុប ខណៈដែលផ្សារហ៊ុនញូវយ៉ក គឺជាទីផ្សារភាគហ៊ុន សំខាន់សម្រាប់ទ្វីបអាមេរិក និងពិភពលោក។

បន្ទាប់ពីបានគ្របដណ្តប់សេដ្ឋកិច្ចពិភពលោកអស់រយៈពេលច្រើនជាង១សតវត្ស ទីផ្សារភាគហ៊ុនញូវយ៉ក (NYSE) បានប្រឈមនឹងគូប្រកួតប្រជែងលើកដំបូងរបស់ខ្លួនក្នុងឆ្នាំ១៩៧០។ នៅឆ្នាំ១៩៧១ ស្ថាប័នធំ ចំនួន២ គឺជាសមាគមជាតិអ្នកចែកចាយមូលបត្រ និងអាជ្ញាធរនិយ័តករឧស្សាហកម្មហិរញ្ញវត្ថុ បានបង្កើតផ្សារហ៊ុន NASDAQ (National Association of Securities Dealers Automated Quotations) ដែលមានការរៀបចំខុសពីទីផ្សារហ៊ុនធម្មតា។ **ឧទាហរណ៍៖** ជំនួសឲ្យការមានទីតាំងជួញដូរ NASDAQ ធ្វើការទាំងស្រុង លើបណ្តាញកុំព្យូទ័រ ហើយរាល់ការជួញដូរទាំងអស់ ធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចបានផ្តល់ឲ្យ NASDAQ នូវគុណសម្បត្តិសំខាន់មួយចំនួនលើគូប្រកួតប្រជែង។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រកួតប្រជែងរវាង NASDAQ និង NYSE បានបង្កើតនូវការផ្លាស់ប្តូរកាន់តែប្រសើរ។ ជាក់ស្តែងនៅឆ្នាំ២០០៧ NYSE បានរួមបញ្ចូលជាមួយ Euronext ដើម្បីបង្កើតបានជា NYSE Euronext ដែលជាផ្សារភាគហ៊ុនមហាសមុទ្រអាត្លង់ទិកដំបូងគេនៅលើពិភពលោក។[7]

---

[7] https://economy.ams.com.kh/history-of-stock-market/ (ចូលទស្សនា ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣)

### ១.៣.៣. ប្រភេទទីផ្សារមូលបត្រ

ជាទូទៅ ទីផ្សារមូលបត្រត្រូវបានធ្វើការបែងចែកចេញជាពីរគឺ ទីផ្សារដំបូង និងទីផ្សារបន្ទាប់។[8]

#### ១.៣.៣.១. ទីផ្សារដំបូង

ទីផ្សារដំបូង គឺជាទីកន្លែងដែលមូលបត្រ ត្រូវបានបោះផ្សាយចេញដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (Issuer) លក់ទៅឲ្យសាធារណជន ដើម្បីទទួលបានហិរញ្ញប្បទាន ឬមូលធនយកទៅវិនិយោគ។ នៅក្នុងដំណាក់កាលផ្សារដំបូងនេះហើយ ដែលក្រុមហ៊ុន ឬសហគ្រាស ធ្វើការប្រមូលទុនពីសាធារណជន ឬវិនិយោគិនដែលបានចូលរួមទិញមូលបត្រដែលបោះចេញដោយក្រុមហ៊ុន។ នៅក្នុងដំណាក់កាលនៃទីផ្សារដំបូង វិនិយោគិនអាចធ្វើការទិញមូលបត្រ ដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយមូលបត្របាន។ ដោយរាល់ការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជា ត្រូវទទួលបានការអនុញ្ញាតជាមុនពីនិយ័តករមូលបត្រកម្ពុជា។

#### ១.៣.៣.២. ទីផ្សារបន្ទាប់

ទីផ្សារបន្ទាប់ គឺជាទីកន្លែងដែលមូលបត្រត្រូវបានជួញដូរបន្តរវាងអ្នកទិញ និងអ្នកលក់ដែលជាវិនិយោគិន មានន័យថាវិនិយោគិន ដែលបានទិញមូលបត្ររួចក្នុងនៅទីផ្សារដំបូង អាចលក់ចេញវិញបានទៅឲ្យវិនិយោគិនមួយផ្សេងទៀត។ ប្រាក់ដែលបានពីសកម្មភាពជួញដូរលើទីផ្សារបន្ទាប់ គឺបានទៅលើអ្នកកាន់កាប់មូលបត្រមិនមែនក្រុមហ៊ុនបោះផ្សាយមូលបត្រឡើយ។

នាពេលបច្ចុប្បន្ននេះ ទីផ្សារបន្ទាប់ត្រូវបែងចែកចេញជាពីរគឺ៖

- ទីផ្សារមូលបត្រ (Organized Exchange) ៖ សំដៅលើការជួញដូរមូលបត្រតាមរយៈទីផ្សារមូលបត្រដែលមានទីកន្លែងជួញដូរជាក់លាក់មួយមានវិធានទីផ្សារ និងមានប្រព័ន្ធជួញដូរ ដើម្បីគ្រប់គ្រងដំណើរការជួញដូរ។
- ទីផ្សារក្រៅប្រព័ន្ធ (Over-the-Counter-OTC) ៖ សំដៅលើការជួញដូរមូលបត្រក្រៅទីផ្សារមូលបត្រដែលពុំមានទីកន្លែងជួញដូរជាក់លាក់ និងមិនផ្លូវការនោះទេ។ វិនិយោគិន អាចធ្វើការជួញដូរមូលបត្រដោយការចរចារតាមរយៈទូរស័ព្ទ អ៊ីម៉ែល និងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនណាមួយ។ ភាគច្រើននៃទីផ្សារនេះក្រុមហ៊ុនពាណិជ្ជករមូលបត្រ គឺជាអ្នកដាក់នូវការកំណត់ថ្លៃទិញ-លក់មូលបត្រជូនទៅអតិថិជន និងក្រុមហ៊ុនពាណិជ្ជករមូលបត្រដទៃទៀត។

[8] ហេង ច័ន្ទបូលីន(២០២២) ទីផ្សារមូលបត្រកម្ពុជា ទំព័រទី៩២

## ១.៤. គុណសម្បត្តិនៃទីផ្សារមូលបត្រ

### ១.៤.១. គុណសម្បត្តិនៃទីផ្សារមូលបត្រចំពោះវិនិយោគិន

មាននមតិមួយចំនួនបានធ្វើការលើកឡើងថា ការជួញដូរមូលបត្រប្រៀបបានទៅនឹងការលេងល្បែងស៊ីសង។ ប៉ុន្តែបើយើងធ្វើការវិភាគឲ្យបានច្បាស់ និងស៊ីជម្រៅថែមទៀត ការវិនិយោគ និងការលេងល្បែងស៊ីសងវាមានលក្ខណៈខុសគ្នាទាំងស្រុង។ ដោយការលេងល្បែងស៊ីសង គឺជាការពឹងទៅលើព្រេងសំណាងដែលខ្លួនមាន ហើយវាក៏មិនមានអ្វីដែលជាអំណះអំណាងនៅក្នុងការឈ្នះនោះដែរ។ ចំណែកឯការវិនិយោគទៅលើវិស័យមូលបត្រវិញ គឺអាស្រ័យទៅលើសកម្មភាព និងដំណើរការរកស៊ីរបស់ក្រុមហ៊ុន ហើយមុនពេលជ្រើសរើសទិញមូលបត្ររបស់ក្រុមហ៊ុនណាមួយ គឺគេបានមើលពីស្ថានភាពហិរញ្ញវត្ថុ និងប្រវត្តិនៃការការគ្រប់គ្រងរបស់ក្រុមហ៊ុននោះរួចមកហើយ។ ចំពោះវិនិយោគិន នៅពេលដែលធ្វើការវិនិយោគិន ឬជួញដូរមូលបត្រ អាចនឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

**ក/. ទទួលបានភាគលាភ និងឱកាសក្នុងការវិនិយោគផ្សេងៗ (ប្រាក់ចំណេញអកម្ម)** ៖ នៅពេលក្រុមហ៊ុនបោះផ្សាយ គាត់ទទួលបានជោគជ័យនៅក្នុងការវិនិយោគ ម្ចាស់ភាគហ៊ុនគាត់នឹងទទួលបាននូវចំណែកភាគលាភមួយចំនួនទៅតាមចំណែកភាគហ៊ុនដែលខ្លួនមាននៅក្នុងក្រុមហ៊ុន និងទទួលបានការប្រាក់ថេរ ទោះបីជាក្រុមហ៊ុនបោះផ្សាយ ទទួលផលចំណេញ ឬខាតបង់ក៏ដោយចំពោះម្ចាស់កាន់កាប់មូលបត្របំណុល។

**ខ/. ប្រាក់ចំណេញពីការទិញ–លក់មូលបត្រ (ប្រាក់ចំណេញមូលធន)** ៖ វិនិយោគិននឹងទទួលបានផលចំណេញផ្នែកមូលធន នៅពេលដែលតម្លៃមូលបត្ររបស់ខ្លួនឡើងថ្លៃនៅក្នុងទីផ្សារមូលបត្រ។ ម៉្យាងវិញទៀតការវិនិយោគជាមួយភាគហ៊ុនជាច្រើនក្រុមហ៊ុនផ្សេងៗគ្នា នឹងជួយបង្កើនទ្រព្យសម្បត្តិរបស់អ្នកវិនិយោគិន តាមរយៈឥទ្ធិពលកំណើនវិស័យផ្សេងៗ ក្នុងសេដ្ឋកិច្ច បើទោះបីជាភាគហ៊ុនខ្លះដែលវិនិយោគបានធ្លាក់ចុះក៏ដោយ។

**គ/. ការធ្វើពិពិធកម្មការវិនិយោគ** (Diversification) ៖ វិនិយោគិនអាចប្រើប្រាស់សាច់ប្រាក់សន្សំច្បាស់លាស់ដោយតែងតែបម្រុងទុកពី ១៥% ទៅ ២០% ដើម្បីវិនិយោគលើមូលបត្រប្រៀបធៀបនឹងការវិនិយោគសរុប។ សម្រាប់វិនិយោគិនដាក់ប្រាក់វិនិយោគច្រើនប្រភេទផ្សេងៗគ្នា ការវិនិយោគក្នុងទីផ្សារមូលបត្រ បានផ្តល់នូវអត្ថប្រយោជន៍សំខាន់មួយគឺពិពិធកម្ម។ ការវិនិយោគក្នុងទីផ្សារមូលបត្រ ប្រែប្រួលថ្លៃដោយមិនជាប់ទាក់ទងជាមួយការវិនិយោគផ្សេងៗទៀតដូចជា អចលនទ្រព្យនោះទេ។ ការវិនិយោគនៅក្នុងទីផ្សារមូលបត្រ អាចជួយកាត់បន្ថយការខាតបង់បានខ្លះ ក្នុងករណីវិនិយោគិនមានការខាតបង់ជាមួយការវិនិយោគក្នុងគម្រោងផ្សេង។

**ឃ/. ភាពជាម្ចាស់កម្មសិទ្ធ** ៖ ការទិញភាគហ៊ុន គឺមានន័យថាលោកអ្នកទទួលយកចំណែកនៃភាពជាម្ចាស់កម្មសិទ្ធិពីក្រុមហ៊ុន ដែលបានលក់ភាគហ៊ុន ហើយលោកអ្នកក៏មានសិទ្ធទទួលបាននូវចំណែករបស់ប្រាក់ចំណេញ

ដែលក្រុមហ៊ុនទទួលបានផងដែរ។ ភាគហ៊ុនិក ដែលមានសិទ្ធិបោះឆ្នោត និងមានសិទ្ធចូលរួមប្រជុំសម្រេចចិត្តក្នុងអាជីវកម្មរបស់ក្រុមហ៊ុនតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់កាប់។

**ង/. ការលើកទឹកចិត្តទៅលើពន្ធកាត់ទុក និងពន្ធលើប្រាក់ចំណេញមូលធន ៖** អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយទៅលើការប្រាក់ ឬភាគលាភដែលបានមកពីការកាន់កាប់ ឬការទិញ- លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើប្រាក់ចំណេញមូលធន ចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល សម្រាប់រយៈពេល ៣ឆ្នាំ (បីឆ្នាំ) គិតចាប់ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។[9]

### ១.៤.២. គុណសម្បត្តិនៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ

**ក/. ការទទួលបានហិរញ្ញប្បទានរយៈពេលវែង ៖** ការចុះបញ្ជីលក់មូលបត្រជាសាធារណៈ បានផ្តល់ជាលទ្ធភាពឲ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ ទទួលបាននូវប្រភពហិរញ្ញប្បទានថ្មីមួយ ដែលអនុញ្ញាតឲ្យក្រុមហ៊ុននោះអាចប្រមូលមូលធនពីអ្នកវិនិយោគិនសាធារណៈសម្រាប់ពង្រីកការវិនិយោគ។ បន្ថែមពីនេះទៀតនៅពេលដែលក្រុមហ៊ុនបានចុះបញ្ជីបោះផ្សាយ និងលក់មូលបត្រ ក្រុមហ៊ុននឹងទទួលបានបានកេរ្តិ៍ឈ្មោះល្អ និងការគាំទ្រពីច្បាប់ដែលក្រុមហ៊ុនអាចពង្រឹងអំណាច ក្នុងការចរចារជាមួយធនាគារ ពីលទ្ធភាពក្នុងការទទួលឥណទាន រួមចំណែកក្នុងការអនុវត្តផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុនផងដែរ។

**ខ/. ទទួលបានការលើកទឹកចិត្តលើផ្នែកពន្ធ ៖** ក្រុមហ៊ុនទាំងអស់ដែលទទួលបានបានការអនុញ្ញាតពី ន.ម.ក បោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ ផ.ម.ក. នឹងទទួលបានការកាត់បន្ថយពន្ធលើប្រាក់ចំណូលទៅតាមទំហំនៃការបោះផ្សាយមូលបត្រដូចមានចែងនៅក្នុងអនុក្រឹត្រស្តីពីការលើកទឹកចិត្តពន្ធជាក្នុងវិស័យមូលបត្រលេខ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ចែកុម្ភៈ ឆ្នាំ២០២២ ក្នុងរយៈពេលបីឆ្នាំ ។ ស្របពេលជាមួយគ្នានេះដែរក្រុមហ៊ុនក៏ទទួលបានការអនុគ្រោះបំណុលពន្ធ ដែលរួមបញ្ចូល ពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករលើស្នាក់នៅ អាករបំភ្លឺសាធារណៈ។

**គ/. ទទួលបាននិរន្តរភាពអាជីវកម្មជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន៖** នៅក្នុងពេលដែលក្រុមហ៊ុនបានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងធ្វើឲ្យប្រសើរឡើងអភិបាលកិច្ចសាជីវកម្មតាមរយៈការរៀបចំឲ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ដែលនឹងមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ ជាលទ្ធផលអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុង នឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឲ្យមានការរីកចម្រើនប្រកបដោយនិរន្តរភាព។

[9] http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣)

**ឃ/. ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងការមើលឃើញរបស់ក្រុមហ៊ុន ៖** ក្រុមហ៊ុនចុះបញ្ជីមួយជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេសតាមរយៈប្រព័ន្ធព័ត៌មាន និងសាធារណជន ហើយកិច្ចប្រតិបត្តិការអាជីវកម្មហិរញ្ញវត្ថុ តែងតែត្រូវបានផ្សព្វផ្សាយ តាមរយៈកាសែត និងទូរទស្សន៍ព្រមទាំងត្រូវបានលើកឡើងទាំងក្នុង និងក្រៅប្រទេសផងដែរ។ ប្រការនេះអាចជួយកែលម្អនូវរូបភាព និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ដែលអាចឲ្យសាធារណជនស្គាល់កាន់តែច្រើនអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។[10]

## ១.៥. គុណវិបត្តិនៃទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច

ជាការពិតណាស់ បើទោះបីជាទីផ្សារមូលបត្រ មាននូវគុណសម្បត្តិជាច្រើនក៏ដោយ ក៏មិនអាចមិនមានគុណវិបត្តិនោះដែរ។ នៅក្នុងប្រទេសដែលមានភាពទន់ខ្សោយខាងផ្នែកច្បាប់ ការគ្រប់គ្រង និងសេដ្ឋកិច្ច ឬក៏ប្រទេសដែលមានការអភិវឌ្ឍន៍ខ្លាំងខ្លានោះទេ ពិតណាស់នឹងមានការប្រឈមជាមួយគុណវិបត្តិជាក់ជាពុំខានដូចខាងក្រោម៖

**ក/. ការឆក់ឱកាសកេងចំណេញក្នុងការជួញដូរ** ( Speculation ) ៖ ជាការទិញ-លក់មួយដែលមានការគិតគូរយ៉ាងហ្មត់ចត់ ដើម្បីទទួលបានផលចំណេញដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការជួញដូរនេះអាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្នបាន ដោយរំពឹងនាពេលអនាគតនឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេងចំណេញក្នុងការជួញដូររបៀបនេះវានឹងបង្កឲ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះ ធ្វើឲ្យមានភាពងាយស្រួល នៅពេលពួកគេព្រមព្រៀងគ្នាក្នុងការជួញដូរ ដែលនាំឲ្យមានចលនាឡើងចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។

**ខ/. ការជួញដូរផ្ទៃក្នុង ៖** មានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីបានឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីធ្វើការជួញដូរភាគហ៊ុនរបស់ទីផ្សារមូលបត្រ ដែលព័ត៌មាននោះមិនមែនជាព័ត៌មានសាធារណៈ ( ព័ត៌មានសម្ងាត់ )។

**គ/. ការជួញដូរក្លែងក្លាយ និងការប្រើប្រាស់ឧបាយកលផ្សេងៗនៅក្នុងទីផ្សារ ៖** គឺជាការធ្វើនូវសកម្មភាពណាមួយ ការគេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឲ្យមានលក្ខណៈក្លែងបន្លំ ការនាំឲ្យមានការយល់ខុស ចំពោះការជួញដូរមូលបត្រ ការធ្វើប្រតិបត្តិការ ការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។

[10] http://www.csx.com.kh/news/faq/listPosts.do?lang=kh&MNCD=7060&postId=6 (ចូលទស្សនា ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២៣)

**ឃ/. សេចក្តីថ្លែងការណ៍ ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ៖** នាំឲ្យមានការយល់ខុសធ្ងន់ធ្ងរ ដែលអាចបណ្តាលឲ្យមានសាធារណជនទិញមូលបត្រ ឬបណ្តាលឲ្យមានការកើនឡើង ការថយចុះ ឬនៅថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។

**ង/. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ៖** តម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចអាជីវកម្មល្អ ដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែង ក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។[11]

[11] https://khemsaritheducation.wordpress.com/ (ចូលទស្សនា ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣)

# ជំពូកទី២
# ស្ថានភាពទូទៅនៃនិយ័តករ
# មូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារ
# មូលបត្រកម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ២.១. និយ័តករមូលបត្រកម្ពុជា (ន.ម.ក.)

### ២.១.១. ប្រវត្តិសង្ខេបរបស់និយ័តករមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា ហៅកាត់ថា គ.ម.ក. ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក. ត្រូវបានធ្វើឡើងដោយអនុលោមទៅតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជាដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៣ ខែកក្កដាឆ្នាំ២០០៨។ [12] ជាចុងក្រោយគណៈកម្មការមូលបត្រកម្ពុជាត្រូវបានសម្ពោធជាផ្លូវការ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩។[13] គណៈកម្មការមូលបត្រកម្ពុជាត្រូវបានប្តូរឈ្មោះទៅជា និយ័តករមូលបត្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០១២១/00៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។[14] នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ និយ័តករមូលបត្រកម្ពុជាបានចេញសេចក្តីជូនដំណឹង ស្តីពីការផ្លាស់ប្តូរនិមិត្តសញ្ញា និងក្រោយធ្វើសមាហរណកម្មទៅក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។[15] និយ័តករមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រងត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបទៅដោយសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។[16]

### ២.១.២. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជាមានទីតាំងស្ថិតនៅ អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ និយ័តករមូលបត្រកម្ពុជា មានព័ត៌មានសម្រាប់ទំនាក់ទំនងដូចខាងក្រោម៖

- ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៨ ៥៦ ១១ / (៨៥៥) ១៦ ៨១៩ ៩៩១ (វិចិត្រ-admin) / (៨៥៥) ០១ ៧៧៦ ៧៨៥ (តី-webmaster)

---

[12] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[13] https://www.serc.gov.kh/khmer/m10.php?pn=1(ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[14] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ លេខ នស/រកម/០១២១/00៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ មាត្រា ១៦

[15] https://www.serc.gov.kh/khmer/m77.php?pn=8 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[16] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

- ទូរសារ: (៨៥៥) ២៣ ៨៨ ៥៦ ២២
- អ៊ីម៉ែល: INFO@SERC.GOV.KH ។[17]



រូបភាព ២.១៖ ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា

### ២.១.៣. ចក្ខុវិស័យ និងបេសកកម្ម

#### ក. ចក្ខុវិស័យ

និយ័តករមូលបត្រកម្ពុជាហៅកាត់ថា ន.ម.ក. ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ ន.ម.ក. មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រដើម្បីជាការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។[18]

[17] https://www.serc.gov.kh/khmer/m19.php?pn=1 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[18] https://www.serc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

**ខ. បេសកកម្ម**

និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងបំពេញនូវបេសកកម្មដូចខាងក្រោម៖[19]

- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- លើកកម្ពស់ទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព ជំរុញឲ្យមានការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**២.១.៤. រូបសញ្ញា អត្ថន័យនៃរូបសញ្ញា និងត្រារបស់និយ័តករមូលបត្រកម្ពុជា**

**ក. រូបសញ្ញារបស់និយ័តន័យមូលបត្រកម្ពុជា**

រូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជារួមមាន៖

- រូបហង្សពណ៌មាស
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលមានពណ៌ប្រផេះ
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើដោយអក្សរខ្មែរថា "**និយ័តករមូលបត្រកម្ពុជា**" និងព័ទ្ធរង្វង់នៅ ផ្នែកខាងក្រៅដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE REGULATOR OF CAMBODIA"។

[19] https://www.serc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

រូបភាព ២.២ ៖ រូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជា

**ខ. អត្ថន័យនៃរូបសញ្ញា**

- រូបហង្សមានពណ៌មាស តំណាងឲ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ ធានាឲ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធិភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលមានពណ៌ប្រផេះ ដែលតំណាងឲ្យភាពចំណេញ- ខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងជាន់លើផ្ទៃពណ៌ប្រផេះចង់បង្ហាញថាភាពចំណេញ- ខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធិភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើ តំណាងឲ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

**គ. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា**

- រូបហង្សមានពណ៌មាសជាប់បាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរដោយរូបនេះត្រូវបានប្រើប្រាស់ជាលើកដំបូងនៅលើប្រាក់ប្រាសាទនៅក្នុងរជ្ជកាលព្រះបាទអង្គឌួងដើម្បីរំលឹកដល់**លោក សំអាង ហង្ស** ដែលព្រះអង្គឌួងបញ្ជូនឲ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេសហើយលោកបានរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឲ្យរូបិយវត្ថុខ្មែរមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ឲ្យចរាចរណ៍ក្នុងសេដ្ឋកិច្ច។
- រូបហង្សមានពណ៌មាសនេះជារូបសញ្ញាតំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយមសម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ

កម្ពុជា ដែលការណ៍ត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយហើយមានប្រធានជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈុន** ។[20]

**ឃ. ត្រារបស់និយ័តករមូលបត្រកម្ពុជា**

ត្រារបស់និយ័តករមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្ដាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា "និយ័តករមូលបត្រកម្ពុជា" ។

រូបភាព ២.៣ ៖ ត្រារបស់និយ័តករមូលបត្រកម្ពុជា

**២.១.៥. គោលដៅ និងគោលបំណងទូទៅនៃនិយ័តករមូលបត្រកម្ពុជា**

និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) មានគោលដៅ និងគោលបំណងដូចខាងក្រោម៖[21]

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ រួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្ដល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្ដល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគព្រមទាំងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្ដាប់ធ្នាប់ និងត្រឹមត្រូវ។
- ជម្រុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រ
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ

[20] https://www.serc.gov.kh/khmer/m17.php?pn=1 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[21] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

### ២.១.៦. មុខងាររបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជាមានមុខងារដូចខាងក្រោម៖[22]

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ
- ដាក់ឲ្យអនុវត្តនូវគោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់
- ដើរតួនាទីជាស្ថាប័នត្រួតពិនិត្យនិងដោះស្រាយទៅលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណដែលប៉ះពាល់ដល់ប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ
- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្របដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

### ២.១.៧. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា

សមាជិករបស់ ន.ម.ក. មានអាណត្តិ ៥ ឆ្នាំ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួនសមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ច។ សមាជិក ន.ម.ក. អាចត្រូវបានតែងតាំងសារជាថ្មីទៀតបានទៅតាមសំណើររបស់ប្រធាន ន.ម.ក. នៅពេលផុតអាណត្តិ។[23] និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលមានប្រធាន ១ រូប (ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងសមាជិក ៨ រូប ដែលតែងតាំងដោយអនុក្រឹត្យ ដែលមានដូចខាងក្រោម៖

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប
- តំណាងធនាគារជាតិនៃកម្ពុជា ១ រូប
- តំណាងក្រសួងពាណិជ្ជកម្ម ១ រូប
- តំណាងក្រសួងយុត្តិធម៌ ១ រូប

[22]ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ មាត្រា៧
[23]ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ មាត្រា៥

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប
- អគ្គនាយកនៃ ន.ម.ក. ១ រូប
- អ្នកជំនាញដែលមានបទពិសោធន៍ក្នុងវិស័យមូលបត្រចំនួន ២ រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[24]

## ២.១.៨. រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា

[25]




រូបភាព ២.៤៖ រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា

## ២.១.៩. ថ្នាក់ដឹកនាំបច្ចេកទេសរបស់និយ័តករមូលបត្រកម្ពុជា

ថ្នាក់ដឹកនាំបច្ចេកទេសរបស់និយ័តករមូលបត្រកម្ពុជាមានដូចខាងក្រោម ៖[26]

| ឈ្មោះ | តួនាទី |
|---|---|
| ឯកឧត្តម ស៊ូ សុជាតិ | អគ្គនាយក |
| ឯកឧត្តម សៀង ធីរិទ្ធ | អគ្គនាយករង<br>ទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រនិងនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ |
| ឯកឧត្តមបណ្ឌិត រិន ភក្តី | អគ្គនាយករង |

[24]ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ មាត្រា៦

[25] https://www.serc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[26] https://www.serc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

| | |
|---|---|
| | ទទួលបន្ទុកនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ |
| លោកជំទាវ សុខ សុគន្ធជីវី | អគ្គនាយករង<br>ទទួលបន្ទុកនាយកដ្ឋានកិច្ចការគតិយុត្តិ និងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| លោក កែប សំភី | ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ |
| លោកស្រី ថៃ សុខជល្លីន | ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ |
| លោកស្រី ហ៊ា លីគា | ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ |
| លោក យុន គីមលៀង | ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ |
| លោក ណា ពៅបញ្ញារិទ្ធ | ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តិ |
| លោក លេខា វិចិត្រ | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |

តារាង ២.១. តារាងថ្នាក់ដឹកនៃបច្ចេកទេសរបស់និយ័តករមូលបត្រកម្ពុជា

### ២.១.១០ នាយកដ្ឋានរបស់និយ័តករមូលបត្រកម្ពុជា

ន.ម.ក មាននាយកដ្ឋានចំណុះចំនួន០៦ ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកនៃ ន.ម.ក មានដូចខាងក្រោម៖[27]

#### ក. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុមានមុខងារដូចជា៖

- រៀបចំផែនការ និងថវិការបស់ ន.ម.ក.
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គង់ផ្គង់ និងជួសជុលសំភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា

[27] https://www.serc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ ន.ម.ក.
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន

**ខ. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រមានមុខងារដូចជា៖

- រៀបចំលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ចនិងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ចនិងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យនិងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយមូលបត្រលក់ជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែមឯកសារ ផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិក ឬតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបតត្រលក់ជាសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងរបស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើមានការចាំបាច់ស្របតាមក្របខ័ណ្ឌការងារ
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ

- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈទៅនាយកដ្ឋានកិច្ចការគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត។

**គ. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រមានមុខងារដូចជា៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុមមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏នៃនៅក្នុងទីផ្សារដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ ន.ម.ក.
- ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រទីប្រឹក្សាវិនិយោគពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សា វិនិយោគពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រអ្ន កគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យជាក់ស្តែង ដល់ទីកន្លែងតាមការចាំបាច់នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រង មូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- បញ្ជូនសំណុំរឿងសង្ស័យថា មានការប្រព្រឹត្តល្មើស នឹងច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ

**ឃ. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមុខងារដូចជា៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការជាមួយ
- ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការ
- ពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ ន.ម.ក.

- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ
- ប្រតិបត្តិករប្រព័ន្ធទូទាត់ និងផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យដាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារ
- មូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រទៅនាយកដ្ឋានកិច្ចការគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត

**ង. នាយកដ្ឋានកិច្ចការគតិយុត្ត**

នាយកដ្ឋានកិច្ចការគតិយុត្តមានមុខងារដូចជា៖

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និងសម្រេចពីអគ្គនាយកនៃ ន.ម.ក.
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ
- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់និងបទបញ្ញត្តិផ្សេងៗដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍វិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទអ្នកចូលរួមក្នុងទីផ្សារមូលបត្រ

- ចាត់វិធានការផាកពិន័យអន្តរការណ៍ទៅលើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ពាព័ន្ធទៅនឹងវិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ ន.ម.ក.។

**ច. នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ ទំនងអន្តរជាតិ**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិមានមុខងារដូចជា៖

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានាដើម្បីអភិវឌ្ឍន៍វិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា សិក្សាស្រាវជ្រាវលើការអភិវឌ្ឍន៍
- គ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ សិក្សាវាយតម្លៃ និងផ្តល់យោបល់
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីមុននឹង អនុញ្ញាតឲ្យមានបោះផ្សាយនៅលើទីផ្សារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា។

## ២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)

### ២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធនការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានធ្វើការចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍន៍ផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសឲ្យបើកដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា

និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចម្រុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ផ្សារមូលបត្រកម្ពុជាកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចម្រុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់នូវភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាទទួល បានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជាធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ដែលជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក.) ស្របតាមច្បាប់អំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

ក្រោមដំណើរការជាច្រើនដំណាក់កាលនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ គឺជាថ្ងៃប្រវត្តិសាស្ត្រដ៏សំខាន់មួយនៃវិស័យហិរញ្ញវត្ថុ និងជាមោទនភាពជាតិមួយសម្រាប់កម្ពុជា ដែលនៅទីបំផុតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange) បានឈានដល់ដំណាក់កាលចុងក្រោយដែលត្រូវបានសម្ពោធដាក់ឲ្យដំណើរការនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានអនុវត្តការជួញដូរមូលបត្រកម្មសិទ្ធិជាលើកដំបូង។[28]

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជាធ្វើជា៖

- ប្រតិបត្តិករទីផ្សារមូលបត្រ ៖ ជាកន្លែងមូលបត្រត្រូវបានទិញ និងលក់ជាកន្លែងផ្តល់ប្រព័ន្ធជួញដូរ។
- ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ៖ ត្រួតពិនិត្យមូលបត្រខាងអ្នកលក់ និងសាច់ប្រាក់ខាងអ្នកទិញដើម្បីបញ្ចៀសហានិភ័យ។
- ប្រតិបត្តិកររក្សាទុកមូលបត្រ ៖ រក្សាទុកមូលបត្រធ្វើការផ្លាស់ប្តូរកម្មសិទ្ធិករ និងដកចេញមូលបត្រ។[29]

### ២.២.២. ចក្ខុវិស័យ និងបេសកកម្ម

វិស័យមូលបត្រកម្ពុជា ជាផ្នែកមួយក្នុងការធ្វើឲ្យវិស័យហិរញ្ញវត្ថុកាន់តែមានសន្ទុះកើនឡើងជាលំដាប់។ ហេតុនេះហើយដើម្បីឲ្យដំណើរការនៃវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាកាន់តែមានការរីកចម្រើនប្រកបដោយប្រសិទ្ធិភាពនិងប្រសិទ្ធិផលបានក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានធ្វើការកំណត់នូវចក្ខុវិស័យរបស់ខ្លួនមួយយ៉ាងច្បាស់លាស់ក្នុងការជួយគាំទ្រវិស័យហិរញ្ញវត្ថុកម្ពុជានោះគឺដើម្បីកសាងនូវ "**មហាវិថី**" ហិរញ្ញវត្ថុសម្រាប់កម្ពុជា។

[28] http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[29] ហេង ច័ន្ទបូលីន (២០២១) ទីផ្សារមូលបត្រកម្ពុជា ទំព័រទី ១៤០

### ២.២.៣. បេសកកម្ម

ដើម្បីជួយសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានដាក់ចេញនូវបេសកកម្មមួយចំនួនដូចខាងក្រោម ៖

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រ ដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- ដើម្បីបង្កើតនូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយ ដែលមានស្វ័យចីរភាពក្រោមមគ្គុទេសក៏ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ២.២.៤. ទីតាំងរបស់ផ្សារមូលបត្រកម្ពុជា

- **អាសយដ្ឋាន** ៖ អគារ ផ.ម.ក. វិថីព្រះមហាក្សត្រយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
- **ទូរស័ព្ទ** ៖ (៨៥៥) ២៣ ៩៥៨ ៨៨៨ / ២៣ ៩៥៨ ៨៨៨
- **ទូរសារ** ៖ (៨៥៥) ២៣ ៩៩៥ ៥៥៨
- **គេហទំព័រ** ៖ : www.csx.com.kh [30]




រូបភាព ២.៥ ៖ ទីតាំងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

[30] http://csx.com.kh/kh/about/contact.jsp?MNCD=10703 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

### ២.២.៥. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា

#### ក. នាមករណ៍

នាមករណ៍ក្រុមហ៊ុនមាននាមជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលហៅកាត់ថា (ផ.ម.ក.) និងជាភាសាអង់គ្លេសថា (Cambodia Securities Exchange) ហៅកាត់ថា (CSX)។

#### ខ. ផ្លាកសញ្ញា

រូបភាព ២.៦ ៖ ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានអត្ថសញ្ញាណដូចខាងក្រោម៖

- ផ្នែកខាងលើមានសរសេរអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ក្រោមអក្សរផ្នែកខាងស្តាំមានរូបហង្សពណ៌មាសមួយ ដែលឈរបែរមុខទៅខាងស្តាំ
- ក្រោមអក្សរផ្នែកខាងឆ្វេង មានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាអក្សរកាត់ភាសាអង់គ្លេសដែលមានពណ៌ខៀវ (CSX)។

### ២.២.៦. រចនាសម្ព័ន្ធនៃការគ្រប់គ្រង




រូបភាព ២.៧ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ២.២.៧. ក្រុមប្រឹក្សាភិបាល




រូបភាព ២.៨ ៖ រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

- ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក. រួមមានសមាជិក ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល(ដែលជាអគ្គនាយករងផងដែរ)និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- សមាជិកចំនួន ៤រូប ផ្សេងទៀត គឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះមាន២រូប ត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២ រូបទៀត ត្រូវបានតែងតាំងដោយ ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។[31]

### ២.២.៨. ព័ត៌មានស្តីពីសមាជិកក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃ ផ.ម.ក មានសមាជិកចំនួន៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ សមាជិកចំនួន ៤ រូបផ្សេងទៀត គឺជាអភិបាលមិនអចិន្ត្រៃយ៍ដោយក្នុងនោះ ២ រូប ដែលត្រូវបានតែងតាំងដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូប ទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។[32]

| | | | |
|---|---|---|---|
|  | ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប<br>ប្រធានក្រុមប្រឹក្សាភិបាល<br>រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |  | Mr. KIM KYEOUNGHACK<br>អនុប្រធានក្រុមប្រឹក្សាភិបាល<br>អគ្គនាយករងនៃផ្សារមូលបត្រកម្ពុជា |

[31] http://csx.com.kh/kh/about/director.jsp?MNCD=10303 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

[32] http://csx.com.kh/kh/about/director.jsp?MNCD=10303 (ចូលទស្សនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣)

| | | | |
|---|---|---|---|
|  | ឯកឧត្តម ហុង សុហួរ<br>សមាជិក<br>ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃផ្សារមូលបត្រ |  | ឯកឧត្តម អ៊ូ ចាន់តារា<br>សមាជិក<br>អគ្គលេខាធិការនៃធនាគារជាតិនៃកម្ពុជា |
|  | ឯកឧត្តម ហ៊ឹម ហ៊ាន<br>សមាជិក<br>ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម |  | Mr. YI BUYEON<br>សមាជិក |
|  | Mr. WE SAE YOUN<br>សមាជិក | | |

រូបភាព ២.៩៖ ក្រុមប្រឹក្សារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ២.៣.តួអង្គចូលរួមនៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

### ២.៣.១. និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជានិយ័តករមូលបត្រតែមួយគត់ ដែលគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណជន ឬវិនិយោគិនមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅក្នុងកម្ពុជា។ បេសកកម្មរបស់ **ន.ម.ក.** រួមមាន៖

១. បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់និងត្រឹមត្រូវ

២. លើកកម្ពស់ការគ្រប់គ្រងក្នុងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍន៍ទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ

៣. ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត

៤. ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេសការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ និងការ ចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[33]

[33] http://csx.com.kh/kh/about/chairman.jsp?MNCD=1000 (ចូលទស្សនាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រូវបានបង្កើតនិងដាក់ឲ្យដំណើរការទីផ្សារមូលបត្រប្រព័ន្ធជាត់ទាត់ទូទាត់មូលបត្រ និងប្រព័ន្ធរក្សាទុកមូលបត្រស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិដែលពាក់ពន្ធ័។ ក្នុងនាមជាសហគ្រាសសាធារណៈដែលរដ្ឋមានភាគហ៊ុនភាគច្រើនក្នុងផ្សារមូលបត្រកម្ពុជាបានទទួលភារកិច្ចបង្កើត និងដាក់ឲ្យមានដំណើរការទីផ្សារមូលបត្រដំបូងបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ **ផ.ម.ក.** ជាប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីចម្បងនៅក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសល្អប្រសើរដល់អ្នកចូលរួមនៅក្នុងទីផ្សារជាពិសេសការជំរុញ និងការលើកទឹកចិត្តដល់វិនិយោគិន និងក្រុមហ៊ុននៅក្នុងស្រុកតាមរយៈការបង្កើតឲ្យមានសន្ទនីយភាពទីផ្សារ និងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។

### ២.៣.៣. ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រ គឺជាតួអង្គសំខាន់មួយនៅក្នុងដំណើរការទីផ្សារព្រោះក្រុមហ៊ុនមូលបត្រត្រូវបានចាត់ទុកជាអ្នកជំនាញក្នុងវិស័យមូលបត្រដើម្បីជួយក្រុមហ៊ុនបោះផ្សាយក្នុងដំណើរការទិញ និងលក់មូលបត្រនៅលើទីផ្សារទទួលបានជោគជ័យតាមរយៈការដើរតួនាទីយ៉ាងសំខាន់ជាអន្តរការី ឬជាអ្នកសម្របសម្រួលប្រតិបត្តិការមូលបត្រនៅក្នុងទីផ្សារ។ បន្ថែមពីលើនេះទៅទៀត ក្រុមហ៊ុនមូលបត្រក៏មានតួនាទីក្នុងការជួយសម្រួលជូនដល់វិនិយោគិនមូលបត្រនៅក្នុងដំណើរការជួញដូរមូលបត្រ (ការទិញ- លក់មូលបត្រ) នៅក្នុងទីផ្សារព្រោះវិនិយោគិនគាត់មិនអាចធ្វើការជួញដូរដោយខ្លួនឯងនោះទេ ដោយគ្រប់រាល់ការជួញដូរទាំងអស់ត្រូវតែធ្វើឡើងតាមរយៈឈ្មួញជើងសារដែលជាក្រុមហ៊ុនមូលបត្រ។ នាពេលបច្ចុប្បន្ននេះមានក្រុមហ៊ុនមូលបត្រចំនួន១២ (ដប់ពីរ) ដែលមានសកម្មភាពអាជីវកម្មរួមមានដូចខាងក្រោម៖[34]

**ក. ក្រុមហ៊ុនធានាទិញមូលបត្រ** ( Securities Firms)

ក្រុមហ៊ុនធានាទិញមូលបត្រ គឺជាអ្នកផ្តល់ប្រឹក្សាសំខាន់លើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជា ៖

- ការដាក់តម្លៃមូលបត្រ (Pricing)
- ការកំណត់ទំហំទឹកប្រាក់ (Issue Amount) និងចំនួនមូលបត្រ (Number of Securities to be Issue) នៃសំណើរបោះផ្សាយលក់មូលបត្រ
- ការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ (Distribution Timely )

[34] ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ (ចូលទស្សនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣)

- ទិញមូលបត្រទាំងស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រក្នុងគោលដៅចែកចាយ ឬលក់បន្ត
- ទិញមូលបត្រដែលលក់មិនអស់ ឬ តាមការដែលព្រមព្រៀងនៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ឬ ចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក. មានចំនួនក្រុមហ៊ុន ៧ ក្រុមហ៊ុនគឺៈ[35]

១. យ៉ាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី / Yuanta Securities (Cambodia) Plc.

២. អ អេច ប៊ី ស៊ីយូរីធី (ខេមបូឌា) ម.ក / RHB Securities (Cambodia) PLC.

៣. កាណា ស៊ីយូរីធី អិលធីឌី / Cana Securities Ltd.

៤. កម្ពុ ស៊ីយូរីធី ភីអិលស៊ី / Campu Securities Plc.

៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី / SBI Royal Securities Plc.

៦. ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី / Phnom Penh Securities Plc.

៧. ខេមបូឌា ស៊ីយូរីធី ម.ក / Cambodia Securities PLC.[36]

**ខ. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ** (Securities Brokerage)

ក្រុមហ៊ុនមូលបត្រ ដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រមានតួនាទីជាអ្នកទទួលទិញ ឬលក់មូលបត្រតាមបញ្ជារបស់អតិថិជនរបស់ខ្លួនដោយទទួលបាននូវកម្រៃជើងសា។ [37] ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រទាំនោះរួមមានដូចជាៈ

១. អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី / ACLEDA Securities Plc.

២. ខេប ស៊ីយូរីធី លីមីធីត / CAB Securities Limited

៣. ខេមបូឌា-វៀតណាម ស៊ីយូរីធី ភីអិលស៊ី ឯ.ក / Cambodia-Vietnam Securities Co., Ltd.

៤. ក្រុមហ៊ុន ភីភី លីង ស៊ីយូរីធី ឯ.ក / PP Link Securities Co., Ltd.

៥. គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីយូរីធី ភីអិលស៊ី / Golden Fortune (Cambodia) Securities Plc. [38]

---

[35]ហេង ច័ន្ទបូលីន (២០២១) ទីផ្សារមូលបត្រកម្ពុជា ទីព័រទី ៧៤

[36] ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ (ចូលទស្សនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣)

[37] http://www.secc.gov.kh/khmer/m52.php?pn=6 (ចូលទស្សនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣)

[38] ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ (ចូលទស្សនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣)

## ២.៣.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធ

### ២.៣.៤.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA)

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើងជា គ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ នៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានចុះបញ្ជីជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង១៥% នៃចំនួនភាគហ៊ុនធម្មតាសរុប ។ រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សាជាអ្នកសម្របសម្រួលដើម្បីឲ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនខេត្តក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។[39]

រូបភាព ២.១០៖ ស្លាកសញ្ញា PWSA

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនធម្មតា |
| **ភាគហ៊ុនបោះផ្សាយ** | ១៣.០៤៥.៩៧៥ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១២ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ពី៤.០៥០រៀល ដល់៦.៣៥០រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១២ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៦.៣០០រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | តុងយ៉ាង ស៊ុយរ្យធី (ខេមបូឌា) ភីអិលស៊ី |

តារាង ២.២. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាអធារណៈលើកដំបូងPWSA

[39] http://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=84 (ចូលទស្សនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.២. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (GTI)

ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិតសម្លៀកបំពាក់ ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ ក្រុមហ៊ុនហ្គ្រេនធ្វីនបានទិញយកក្រុមហ៊ុនក្រុមហ៊ុនQMIIndustrialCo.,Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយ ក្នុងចំណោមរោងចក្រកាត់ដេរធំៗដំបូងបង្អស់ធ្វើ

រូបភាព២.១១៖ស្លាកសញ្ញាGTI

អាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃផលិតផលរបស់ក្រុមហ៊ុនហ្គ្រេនធ្វីនរួមមានម៉ាកសម្លៀកបំពាក់កីឡាល្បីៗ ដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohl's, Nautica, Nort Face, Russell Athletic។ល។ គោលដៅនាំចេញរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីន មានដូចជាបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប (៣៨% នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៩) សហរដ្ឋអាមេរិក (១៩%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៩) តំបន់អាស៊ី និងតាមបណ្តាប្រទេសដទៃទៀត (៤៣%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១៩) ។[40]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនធម្មតា |
| **ភាគហ៊ុនបោះផ្សាយ** | ៨.០០០.០០០ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៧ ដល់ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៤ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៧.៤០០ រៀល ដល់ ១៤.០០០ រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២ ដល់ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៩.៦៤០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី |

តារាង២.៣. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង GTI

[40] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000040001 (ចូលទស្សនាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.៣. កំពង់ផែស្វយ័តក្រុងភ្នំពេញ (PPAP)

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) គឺជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេ និងជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមប្រតិបត្តិករកំពង់ផែអន្តរជាតិទាំងពីរនៅព្រះរាជាណាចក្រកម្ពុជា ហើយជាអាជ្ញាធរគ្រប់គ្រងគ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ។ ក្នុងនាមជាប្រតិបត្តិករផែ (ក.ស.ភ.) ផ្តល់សេវាកម្ម លើកដាក់ក្រោមដងយោងលើកដាក់លើទីលានឃ្លាំងស្តុកទុកទំនិញកណ្តាលជាកិច្ចទីលាន ស្តុកទុកសំបកកុងតឺន័រ រៀបទំនិញទូកុងតឺន័រត្រជាក់វាស់ស្ទង់និងបូមស្តារ ជួសជុល និងថែទាំកុងតឺន័រប្រមូលផ្តុំចែកចាយទំនិញនិងសេវារថយន្តដឹកជញ្ជូនក្រៅចំណតផែ។ ក្នុងនាមជា អាជ្ញាធរផែ ក. ស. ភ. ទទួលបានសិទ្ធិគ្រប់គ្រងមណ្ឌលអាជីវកម្មផែដែលមានចំងាយ១៦៦គ.ម។ ក្នុងមណ្ឌលអាជីវកម្មផែនេះ ក.ស. ភ. ក្នុងមណ្ឌលអាជីវកម្មផែនេះ ក. ស. ភ. បាន និងកំពុងប្រតិបត្តិការនៅទីតាំងនៃចំណតផែចំនួន៥ គឺ: ចំណតផែកុងតឺន័រLM១៧ ចំណតផែពហុបំណងTS៣ ចំណតផែពហុបំណង KM៦ ចំណតផែទន្លេបិទ UM២ និងចំណតផែអ្នកដំណើរ និងទេសចរ TS១ ។[41]

រូបភាព ២.១២៖ ស្លាកសញ្ញា PPAP

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | កំពង់ផែស្វយ័តភ្នំពេញ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ៤.១៣៦.៨៧៣ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៩ ដល់ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៤.៤០៥ រៀល ដល់ ៦.៣២០ រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី១២ ដល់ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៥.១២០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

តារាង ២.៤. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងPPAP

[41] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.៤.ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិតភីអិលស៊ី (PPSP)

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍន៍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ("PPSEZ") និងប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ("Poipet PPSEZ") ។ នាថ្ងៃទី១៩ មេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទហើយបច្ចុប្បន្ននេះយើងខ្ញុំជាតំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា ដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍន៍ដីឧស្សាហកម្មសម្រាប់លក់ ឬជួល។ ក្រុមហ៊ុនក៏មានផ្តត់ផ្គង់សេវាកម្មដែលពាក់ព័ន្ធព្រមជាមួយបរិក្ខារចាំបាច់នានានៅក្នុងបរិវេណ PPSEZ ដែលរួមមាន ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាលប្រព្រឹត្តិកម្មទឹកសំអុយ និងសេវាកម្មដទៃទៀត។[42]

រូបភាព២.១៣៖ស្លាកសញ្ញា PPSP

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ១១.៥៧៥.000 |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៨ ដល់ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ២.៨00រៀល ដល់ ៤.000រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី៩ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ២.៨៦០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី កម្ពុ ស៊ីឃ្យួរីធី និងកាណា ស៊ីឃ្យួរីធី |

តារាង ២.៥. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង PPSP

[42] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000050000 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

កំពង់ផែស្វយ័តក្រុងព្រះសីហនុ(ក.ស.ស) ជាក្រុមហ៊ុនរដ្ឋដែលបានបង្កើតឡើង ដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋាន លើការងារៈ កណ្ដាលធារកិច្ចនាំនាវាចេញ-ចូលនិងផ្តល់ភស្តុភារដល់នាវា លើកដាក់ ផ្ទេរ ផ្ទុកទំនិញ ស្តុកទំនិញនៅឃ្លាំង និងទីលានព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស ក៏កំពុងផ្តល់សេវាកម្មផ្សេងទៀតៈ សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេស ដូចជាជួលឃ្លាំងនិងថែរក្សាទំនិញ លើកដាក់ និងដឹកជញ្ជូនទំនិញរួមទាំងសេវាសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ ក.ស.ស ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅកម្ពុជាដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ហិចតា នៅខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះរួមមានបណ្តាញផ្លូវគោក (ផ្លូវជាតិលេខ ៣ និងលេខ ៤), បណ្តាញផ្លូវរថភ្លើង (តភ្ជាប់ទៅរាជធានី ភ្នំពេញ និងខេត្តកំពត) និងបណ្តាញផ្លូវអាកាស (តភ្ជាប់ទៅខេត្តសៀមរាម និងរាជធានីភ្នំពេញ)។ ក.ស.ស ស្ថិតនៅឈូងសមុទ្រថៃដែលជាទីតាំងយុទ្ធសាស្ត្រងាយស្រួលដឹកជញ្ជូនទៅទីផ្សារក្នុងតំបន់អាស៊ាន និងតំបន់អាស៊ីប៉ាស៊ីហ្វិចដោយពុំចាំបាច់ឆ្លងកាត់កំពង់ផែក្នុងតំបន់។[43]

រូបភាព ២.១៤.៖ស្លាកសញ្ញា PASP

| តារាងសង្ខេបលទ្ធនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ២១.៤៤២.៩៩២ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី២៥ មេសា ដល់ ថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៧ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៣.៩២០រៀល ដល់ ៥.១៨០រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី១៧ ដល់ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៥.០៤០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី |

តារាង ២.៦. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង (PAS)

[43] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000060009 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.៦. ធនាគារអេស៊ីលីដា ភីអិលស៊ី ( ABC )

ធនាគារអេស៊ីលីដាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ដែលស្ថិតក្រោមគម្រោង អង្គការពលកម្មអន្តរជាតិក្នុងយុគសម័យក្រោយសង្គ្រាមនៅកម្ពុជា។ ជាច្រើនឆ្នាំមកនេះ ធនាគារអេស៊ីលីដាមានទីស្នាក់ការកណ្ដាលនៅរាជធានីភ្នំពេញ ហើយគឺជាធនាគារឈានមុខ

រូបភាព ២.១៥៖ ស្លាកសញ្ញា ABC

និងធំជាងគេផ្នែកឥណទានដុលនិងបណ្ដាញចែកចាញគ្រប់ខេត្ត-ក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារអេស៊ីលីដាក៏ជាធនាគារកម្ពុជាដំបូង ដែលបានពង្រីកប្រតិបត្តិការរបស់ខ្លួនទៅក្រៅប្រទេស ដែលរួមមានប្រទេសឡាវ និងមីយ៉ាន់ម៉ា។ ធនាគារអេស៊ីលីដាទទួលប្រាក់បញ្ញើពីអតិថិជននិងផ្តល់ដល់អតិថិជននូវផលិតផលឥណទានច្រើនប្រភេទ ព្រមទាំងសេវាហិរញ្ញវត្ថុផ្សេងៗទៀតដូចជា ការផ្ទេរប្រាក់ ការគ្រប់គ្រង សាច់ប្រាក់ ហិរញ្ញប្បទាន ពាណិជ្ជកម្ម ភតិសន្យាហិរញ្ញវត្ថុ និង សេវាកម្មធនាគារអេឡិចត្រូនិក។ ធនាគារអេស៊ីលីដាគឺជាធនាគារដំបូងគេនៅកម្ពុជា ដែលទទួលបានការផ្តល់ចំណាត់ថ្នាក់ដោយស្ថាប័នផ្តល់ចំណាត់ថ្នាក់ធនាគារអន្តរជាតិគឺ Standard & Poor's និងGIIRS។ បច្ចុប្បន្នធនាគារ អេស៊ីលីដា មានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤គឺ ធនាគារអេស៊ីលីដាឡាវ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី វិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា និងស្ថាប័នមីក្រូហិរញ្ញវត្ថុអេស៊ីលីដាមីយ៉ាន់ម៉ា និងការិយាល័យតំណាង១ នៅប្រទេសមីយ៉ាន់ម៉ា។[44]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះ ក្រុមហ៊ុន** | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ៤.៣៤៤.៨៦៥ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី ០៣ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០២០ |
| **ចន្លោះថ្ងៃក្នុងការធ្វើប៊ុកបៀលឌីង** | ១៥.០០០ រៀល ដល់ ១៧.០០០រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី ២៤ ខែមីនា ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ១៦.២០០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

តារាង ២.៧. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង ABC

[44] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000100003 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.៧. ក្រុមហ៊ុន ផេកថិក (ខេមបូឌា) ម.ក. (PEPC)

PEPC ចូលរួមជាចម្បងនៅក្នុងការផ្តល់ជូននូវដំណោះស្រាយផ្នែកវិស្វកម្មប្រព័ន្ធវិស្វកម្មសំណង់រចនា និងបច្ចេកទេសនៃប្រព័ន្ធអគ្គិសនីគ្រប់ជ្រុងជ្រោយសម្រាប់៖ ការរចនាប្លង់ ការធ្វើលទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ឲ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គិសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គិសនីផងដែរ ការដំណើរការ និងថែទាំ ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយ៍ និងការធ្វើជំនួញសមាសធាតុ និងបរិក្ខារប្រព័ន្ធអគ្គិសនីដែលមានពាណិជ្ជសញ្ញាជារបស់ខ្លួនឯង និងមិនមែនជារបស់ខ្លួនឯង។[45]

រូបភាព ២.១៦៖ ស្លាកសញ្ញា PEPC

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះ ក្រុមហ៊ុន** | ផេសថិក (ខេមបូឌា) ម.ក |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ៣.៩៤៥.000 |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី 0៤ ខែសីហា ឆ្នាំ២០២០ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៣.១២០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អ អេច ប៊ីស៊ីយូរីធី (ខេមបូឌា) ម.ក |

តារាង ២.៨. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង PEPC

[45] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000140009 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.៨. ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក. ( DBDE )

ក្រុមហ៊ុន ឌីប៊ីឌី អ៊ីនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1995 ជាក្រុមហ៊ុនពហុមុខងារផ្នែកវិស្វកម្ម និងសំណង់ដែលមានបទពិសោធន៍ជាច្រើនឆ្នាំ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌី ប៊ី ឌី ផ្តល់សេវាកម្មដូចជា សេវាកម្មគូរ ប្លង់ សាងសង់ តំឡើង និងថែទាំ ដែលសេវាកម្មទាំងអស់នេះធ្វើ

រូបភាព ២.១៧ ៖ស្លាកសញ្ញា DBDE

និងថែទាំដែលសេវាកម្មទាំងនេះធ្វើឲ្យក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ក្រៅពីកេរ្តិ៍ឈ្មោះក្នុងផ្នែកសំណង់ ការបំពាក់ឧបករណ៍ និងសេវាកម្មថែទាំដែលបានឈានមុខគេក្នុងការផ្គត់ផ្គង់ ផលិតផលម៉ាកល្បីៗជាច្រើនសម្រាប់គម្រោងនានាកន្លងមកដែលរួមមាន៖ ផលិតផលម៉ាកFranklin France, Daikin, Ginde, LG, Mitsubishi, Kumwell, និងខ្សែកាបម៉ាកYazaki។ ក្រុមហ៊ុន ឌីប៊ីឌី ទទួលបាននូវការកោតសរសើរ និងពេញចិត្តពីសំណាក់អតិថិជនចំពោះគម្រោងធំៗដែលល្បីជាច្រើនដូចជា៖គម្រោងLaboratoired′ analyse médicale de la Fondation Bio Mérieux (បារាំង), អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មជ្ឈមណ្ឌល Cardiologie រោងចក្រផលិតប៊ីចេង អាជីណូម៉ូតូ រោងចក្រ Minibea ក្រុមហ៊ុន Rhoto, B-Quick, Artnature, Hana រោងចក្រស្រាបៀរ ហ៊ិននីគែន គម្រោងខុនដូBodaiju រោងចក្រសហគ្រាសចំណីអាហារ Liwayway វិទ្យាស្ថានប៉ាស្ទ័រ សាលារៀនNorthbridge មជ្ឈមណ្ឌលកែសម្ផស្សមេហ្គាប៉ែល និងសាលាដុនបូស្កូជាដើម។[46]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ៦.៤៦១.៥៣៨ |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២៦ ខែកក្កដា ដល់ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ២.៣៨០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី |

តារាងទី ២.៩៖ ការសង្ខេបលទ្ធផលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ DBDE

[46] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000150008 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

### ២.៣.៤.៩. ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី (JSL)

ក្រុមហ៊ុនជេអេសលែនត្រូវបានបង្កើតឡើងនៅថ្ងៃទី១២ ខែធ្នូឆ្នាំ២០១៤ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុន ត្រូវបានបំលែងទៅជា ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងអនុម័តយកនាមករណ៍បច្ចុប្បន្ននេះកាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ដើម្បីសម្រួលដល់ការធ្វើសំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង។ ក្រុមហ៊ុន ជេអេស លែន ត្រូវបានបង្កើតឡើងដោយសហគ្រិនមួយក្រុមដែលមានសមាជិក ៥ រូបមកពីប្រទេស កម្ពុជា ម៉ាឡេស៊ី និងហុងកុង។[47]

រូបភាព ២.១៨ ៖ស្លាកសញ្ញា JSL

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ជេអេស លែន ភីអិលស៊ី |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ៥,៧១០,000 |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី០៥ ដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ១,៩០០រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ក្រុមហ៊ុន អ អេច ប៊ី ស៊ីយូរីធី (ខេមបូឌា) ម.ក |

តារាងទី២.១០ ៖ តារាងសង្ខេបអំពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ JSL

### ២.៣.៥. វិនិយោគិន

វិនិយោគិន គឺជាអ្នកដែលបានបែងចែកទុនរបស់ខ្លួនដោយរំពឹងថានឹងទទួលបានចំណូលហិរញ្ញវត្ថុនាថ្ងៃអនាគត។ នៅក្នុងវិស័យមូលបត្រ វិនិយោគិនសំដៅទៅដល់សាធារណជនជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី ន.ម.ក. មានសិទ្ធិទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ។[48]

[47] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000160007 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

[48] ហេង ច័ន្ទបូលីន (២០២២-២០២៣) ទីផ្សារមូលបត្រកម្ពុជា ទីព័រទី ៧៨

### ២.៣.៦. តួអង្គចូលរួមដទៃទៀត

ក្រៅពីបណ្តាតួអង្គសំខាន់ៗ ដែលបានធ្វើការរៀបរាប់នៅខាងលើរួចមកនៅក្នុងវិស័យមូលបត្រក៏នៅមានតួអង្គចូលរួមដទៃទៀតរួមមានដូចជា៖

**ក. ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ** (Cash Settlement Agent)

ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ ធ្វើការគ្រប់គ្រងគណនីសាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចជា៖ ការផ្ទេរ ឬការបង្វែរសាច់ប្រាក់រវាងគូភាគីជួញដូរ ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ប្រកបដោយសុវត្ថិភាពបំពេញប្រតិបត្តិការឲ្យដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ។ ភ្នាក់ងារទូទាត់សាច់ប្រាក់ដែលទទួលបានការទទួលស្គាល់ពី ន.ម.ក. មានចំនួន ៦ (ប្រាំមួយ) ធនាគារគឺ៖[49]

- ធនាគារ អេស៊ីលីដា ភីអិលស៊ី / Acleda Bank Plc.
- ធនាគារ កាណាឌីយ៉ា ក.អ / Canadia Bank Plc.
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី / Bank for Investment and Development of Cambodia Plc.
- ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី / Cambodian Public Bank Plc.
- ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក / B.I.C (Cambodia) Bank Plc.
- ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ / B.I.C (Cambodia) Bank Plc.[50]

**ខ. ភ្នាក់ងារបញ្ជិកាមូលបត្រ** (Securities Registar Agent)

ភ្នាក់ងារបញ្ជិកាមូលបត្រ រៀបចំឯកសារពាក់ព័ន្ធនឹងការធ្វើបរិវិសកម្ម ផ្ទៀងផ្ទាត់ទំហំនៃការធ្វើបរិវិសកម្ម បូកសរុបបញ្ជីឈ្មោះវិនិយោគិនដែលធ្វើបរិវិសកម្ម និងចំនួនមូលបត្រដែលបានធ្វើបរិវិសកម្មបញ្ជូនព័ត៌មានអំពីអ្នកធ្វើបរិវិសកម្មបានជោគជ័យទៅប្រតិបត្តិការរក្សាទុកមូលបត្រ (CSD) នៃផ.ម.ក. ធ្វើរបាយការណ៍ស្តីអំពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រនៅ CSD ទៅក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និង **ន.ម.ក.** ជូនដំណឹងអំពីភាពជាម្ចាស់លើមូលបត្រទៅដល់កម្មសិទ្ធិករមូលបត្រ។ ភ្នាក់ងារបញ្ជិកាមូលបត្រដែលទទួលបានទទួលស្គាល់ពី **ន.ម.ក.** មានចំនួន ០៣ (បី) ក្រុមហ៊ុនគឺ ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី / Acleda Bank Plc.
- ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី / Tricor Securities Services PLC.
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី / Phnom Penh Securities PLC.

---

[49] ហេង ច័ន្ទបូលីន (២០២២-២០២៣) ទីផ្សារមូលបត្រកម្ពុជា ទំព័រទី ៨៧

[50] https://www.serc.gov.kh/khmer/m59.php?pn=6 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

**គ. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ** (Transfer Agent)

ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្ររដ្ឋបាលកិច្ចពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មសិទ្ធិ ការធ្វើរបាយការណ៍ស្ថិតិ និងព័ត៌មានផ្សេងៗ រៀបចំការងារពាក់ព័ន្ធនឹងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្រដែលត្រូវផ្តល់ដោយក្រុមហ៊ុនបោះផ្សាយបញ្ជូនរបាយការណ៍ និងព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនបោះផ្សាយទៅដល់កម្មសិទ្ធិករមូលបត្រ និងដោះស្រាយបញ្ហាទាក់ទងនឹងភាពជាម្ចាស់លើមូលបត្រពាក់ព័ន្ធ នឹងសេវារបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររៀបចំ និងប្រមូលទិន្នន័យពីបញ្ជីកម្មសិទ្ធិករមូលបត្រ របស់ប្រតិបត្តិកររក្សាទុកមូលបត្រអនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ។ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រដែលបានទទួលស្គាល់ពី **ន.ម.ក.** មានចំនួន ០៣ (បី) ក្រុមហ៊ុនគឺ ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី / Acleda Bank Plc.
- ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី / Tricor Securities Services PLC.
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី / Phnom Penh Securities PLC.

**ឃ. ភ្នាក់ងារទូទាត់** ( Paying Agent)

ភ្នាក់ងារទូទាត់ គណនាភាគលាភ ការប្រាក់ ប្រាក់ដើម ឬការទូទាត់ផ្សេងទៀត ដែលត្រូវផ្តល់ឲ្យដល់កម្មសិទ្ធិករមូលបត្រធ្វើការទូទាត់ជូនកម្មសិទ្ធិករ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះផ្សាយបញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀត រៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការទូទាត់ជូនទៅក្រុមហ៊ុនបោះផ្សាយ និង ន.ម.ក. តាមការចាំបាច់រៀបចំ និងប្រមូលទិន្នន័យអំពីបញ្ជីកម្មសិទ្ធិករមូលបត្ររបស់ប្រតិបត្តិកររក្សាទុកមូលបត្រ។ ភ្នាក់ងារទូទាត់មានចំនួន ០៣ (បី) ក្រុមហ៊ុនគឺ ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី / Acleda Bank Plc.
- ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី សឺវីស ភីអិលស៊ី / Tricor Securities Services PLC.
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី / Phnom Penh Securities PLC.

**ង. ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល**

ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល ការពារផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុលតាមដានទ្រព្យធានា, តាមដានការអនុវត្តលក្ខខណ្ឌរបស់មូលបត្របំណុលដែលបានបោះផ្សាយលក់ (Terms and Conditions) និងកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់បំណុលធានាថាមូលបត្របំណុលដែលបានធ្វើបដិវត្ត ឬទូទាត់សងធ្វើឡើងដោយអនុលោមតាមលក្ខខណ្ឌរបស់មូលបត្របំណុលដែលបានបោះផ្សាយលក់។ ភ្នាក់ងារដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.** មាន៖

- អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី / ACLEDA Securities Plc.
- កាណា ស៊ីឃ្យួរីធី អិលធីឌី / Cana Securities Ltd.

**ឃ. ភ្នាក់ងារវាយតម្លៃលទ្ធភាពសង**

ភ្នាក់ងារវាយតម្លៃលទ្ធភាពសង វាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រវាយតម្លៃកម្រិតហានិភ័យឥណទានរបស់មូលបត្របំណុល ឬក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ រៀបចំរបាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសងអនុវត្តការងារដោយស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលស្គាល់ដោយ **ន.ម.ក.** គឺ៖

- ក្រុមហ៊ុន រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក / Rating Agency of (Cambodia) Plc.

**ង. ភ្នាក់ងាររក្សាសុវត្ថិភាព**

ភ្នាក់ងាររក្សាសុវត្ថិភាព ថែរក្សាសុវត្ថិភាពទ្រព្យរបស់អតិថិជនដូចជា: មូលបត្រ សាច់ប្រាក់ និងទ្រព្យដទៃទៀត ដាក់បញ្ជា ទិញ- លក់មូលបត្រតាមការបញ្ជាពីអតិថិជន គ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការសាច់ប្រាក់មូលបត្រ និងទ្រព្យដទៃទៀតដែលទទួលបានពីបុគ្គលពាក់ព័ន្ធអតិថិជនដើម្បីធានាថាប្រតិបត្តិការរបស់អតិថិជនត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវ និងមានបច្ចុប្បន្នភាពធ្វើការគណនាទ្រព្យសកម្មសុទ្ធ និងធ្វើការកត់ត្រាទ្រព្យរបស់អតិថិជនតាមតម្លៃទីផ្សារ ព្រមទាំងរាយការណ៍ជូនអតិថិជនការងារពាក់ព័ន្ធអត្ថប្រយោជន៍ និងសេវាផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.**។ ភ្នាក់ងាររក្សាសុវត្ថិភាពដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.**គឺ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី / Acleda Bank Plc.

**ច. ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់** (Law firms)

ក្រុមហ៊ុនមេធាវី ឬមេធាវីជាអ្នកផ្តល់ប្រឹក្សាយោបល់លើបញ្ហាផ្លូវច្បាប់ទាំងអស់ដែលទាក់ទងទៅនឹងពាក្យស្នើសុំ និងឯកសារផ្តល់ព័ត៌មាន ជាពិសេសទៅលើការពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់របស់ក្រុមហ៊ុនដែលចុះបញ្ជី និងធ្វើការផ្ទៀងផ្ទាត់ឯកសារផ្សេងៗឲ្យបានត្រឹមត្រូវតាមការតម្រូវរបស់ច្បាប់។[51] ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.** មានចំនួន ១៧ (ដប់ប្រាំពីរ) ក្រុមហ៊ុនគឺ៖

- ក្រុមហ៊ុនមេធាវី អេច ប៊ី អេស / HBS LAW FIRM
- ការិយាល័យមេធាវី អ អេន ធី សុខ អេន ហេង / R&T SOK & HENG LAW OFFICE
- ការិយាល័យមេធាវី សុក ស៊ីផាន់ណា និង សហការី ជាសមាជិក ZICOlaw SokSiphana & associates, a member of ZICOlaw

[51] ហេង ច័ន្ទបូលីន (២០២២-២០២៣) ទីផ្សារមូលបត្រកម្ពុជា ទីព័រទី ៨០

- ការិយាល័យមេធាវី សិទ្ធិស័ក្តិ / SITHISAK LAW OFFICE
- ក្រុមមេធាវី អាស៊ី កម្ពុជា / ASIA CAMBODIA LAW GROUP
- ការិយាល័យមេធាវី ប៊ុន និង សហការី / BUN & ASSOCATES
- ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី / PYT & Associates LAW OFFICE
- ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាគា / CSL & ASSOCIATES LAW OFFICE
- ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន / HML LAW GROUP & CONSULTANTS
- ការិយាល័យមេធាវី ស៊ិន & ផាតនើ / SIN & Partners Law Office
- ក្រុមមេធាវី កម្ពុជាបាយ័ន (ស៊ី ប៊ី អិល) / CAMBODIA BAYON LAW GROUP
- ក្រុមមេធាវី មេគង្គ / Mekong Law Group
- ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ / Cambodia International Cooperation law group
- ក្រុមមេធាវី ស៊ី អេស ភី និង សហការី / CSP & Associates Law Group
- ការិយាល័យមេធាវី សិដ្ឋាល័យ / SETHALAY Law Office
- ក្រុមមេធាវី ស្កាយ & សហការី / SKY & ASSOCIATES
- ក្រុមហ៊ុនមេធាវី កម្ពុជា កិច្ចការអន្តរជាតិ / Cambodia International Affair Law Firm[52]

**ឆ. ក្រុមហ៊ុនផ្តល់សេវាបកប្រែ** (Translation Service Company)

ក្រុមហ៊ុនផ្តល់សេវាបកប្រែមានតួនាទីបកប្រែឯកសារពាក់ព័ន្ធទៅនឹង IPO ឲ្យបានត្រឹមត្រូវតាមអត្ថន័យដើម។ ក្រុមហ៊ុនបកប្រែដែលទទួលបានការទទួលស្គាលើពី **ន.ម.ក.** មានចំនួន ១ (មួយ) ក្រុមហ៊ុនគឺ ៖

- មន្ទីរសារការី អេច ប៊ី អេស នៃព្រះរាជាណាចក្រកម្ពុជា / H.B.S NOTARY PUBLIC OF THE KINGDOM OF CAMBODIA

**ជ. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ** (Audit Firms)

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម នឹងជួយក្រុមហ៊ុនបោះផ្សាយ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានតាមលក្ខខណ្ឌហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងទៅនឹងហិរញ្ញវត្ថុអន្តជាតិនៃកម្ពុជា ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ។ ក្រុមហ៊ុនផ្តល់សេវាកម្មសវនកម្មក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.** មានចំនួន ០៩ (ប្រាំបួន) ក្រុមហ៊ុនគឺ៖

---

[52] https://www.serc.gov.kh/khmer/m58.php?pn=6 (ចូលទស្សនាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣)

- ក្រុមហ៊ុន ប្រាយវ៉តធ័រ ហាវខូភើស៍ (ខេមបូឌា) / PricewaterhouseCoopers (Cambodia) Ltd.
- ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា / KPMG CAMBODIA LTD
- ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត / BDO CAMBODIA LIMITED
- ក្រុមហ៊ុន អឺនស្ទ៍ អ៊ែន យ៉ាំង (ខេមបូឌា) / ERNST & YOUNG (CAMBODIA) LTD.
- ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត / Grant Thornton (Cambodia) Limited.
- ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក / Crowe(KH) Co.,Ltd.
- ក្រុមហ៊ុន ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី / DELOITTE (CAMBODIA) CO., LTD
- ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក / Baker Tilly (Cambodia) Co., Ltd
- ក្រុមហ៊ុន រីចន៍ & ផាតនើរ / REACHS & PARTNERS CO., LTD.

ឈ. **ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ** (Valuation Companies)

ក្រុមហ៊ុនបោះផ្សាយ ចាំបាច់ត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ ឬបុគ្គលវាយតម្លៃឯករាជ្យ ប្រសិនបើក្រុមហ៊ុនកាន់កាប់ទ្រព្យសម្បត្តិដីធ្លីឬបរិក្ខារត្រូវវាយតម្លៃឡើងវិញ។ ក្រុមហ៊ុនវាយតម្លៃត្រូវរៀបចំរបាយការណ៍វាយតម្លៃដែលជាផ្នែកមួយនៃដំណើរការចុះបញ្ជី។ ក្រុមហ៊ុនផ្តល់ដល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក.** មានចំនួន០៣ (បី) ក្រុមហ៊ុនគឺ៖

- ក្រុមហ៊ុន វីត្រាស់ អឺព្រេហ្សល / VTRUST APPRAISAL Co., Ltd.
- ក្រុមហ៊ុន ណាយ ហ្វ្រែង (ខេមបូឌា) / Knight Frank (Cambodia) Pte., Ltd
- ក្រុមហ៊ុន អ៊ែតវ៉ានថិច ប្រផឹធី សឺវីស ឯ.ក / Advantage Property Services Co., Ltd

# ជំពូកទី៣

# ការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា

# ជំពូកទី៣

# ការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា

## ៣.១. ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ (ភាគហ៊ុន) ជាសាធារណៈលើកដំបូង

### ៣.១.១. លក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) គឺសំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។[53]

ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ជាប្រតិបត្តិករទីផ្សារតែមួយគត់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានតួនាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសការងារ ដែលមានភាពល្អប្រសើរដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសក្រុមហ៊ុនក្នុងស្រុក ដែលត្រូវការមូលធនដើម្បីពង្រីកអាជីវកម្ម ព្រមជាមួយនឹងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។ ទីផ្សារមូលបត្រនៅកម្ពុជាបែងចែកជា២ គឺ ទីផ្សារគោល និងទីផ្សារកំណើន។ ទីផ្សារគោលគឺជាផ្សារដំបូងបង្អស់ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការសម្រាប់ការចុះបញ្ជីរបស់ក្រុមហ៊ុនចុះបញ្ជីសក្តានុពលដែលមានស្តង់ដារ និងទំហំធំ។ ទីផ្សារនេះ នឹងអនុញ្ញាតឱ្យក្រុមហ៊ុននាំយកភាគហ៊ុនទាំងអស់ក្រោយការបោះផ្សាយមកចុះបញ្ជី និងជួញដូរនៅក្នុងប្រព័ន្ធរបស់ ផមក ។[54] រីឯទីផ្សារកំណើនគឺជាទីផ្សារថ្មីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀត សម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះដែលមានផលរបរសុបប្រចាំឆ្នាំលើសពី ១០ពាន់លានដុល្លារអាមេរិក និងបង្កើតការងារចំនួន ១,៣ លានផងដែរ។[55]

ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ក្រុមហ៊ុនត្រូវគោរពតាមលក្ខខណ្ឌដូចជា៖

[53] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០៥/១៥ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ប្រការ ២

[54] http://csx.com.kh/kh/product/mainboard.jsp?MNCD=30102 (ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣)

[55] http://csx.com.kh/kh/product/growthboard.jsp?MNCD=30103 (ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣)

| សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារគោល | សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារកំណើន |
|---|---|
| ១- អភិបាលកិច្ចសាជីវកម្ម | |
| ២- សកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច | |
| ៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម រយៈពេល ២ឆ្នាំ | ៣- របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្ម រយៈពេល១ឆ្នាំ |
| ៤- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ | |
| ៥- ត្រូវមានឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ ន.ម.ក | |

តារាង ៣.១. ៖ លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ

| លក្ខខណ្ឌតម្រូវ | ទីផ្សារគោល | ទីផ្សារកំណើន |
|---|---|---|
| មូលធនភាគហ៊ុនិក | យ៉ាងតិច ៣០ពាន់លាន រៀល (៧.៥.លានដុល្លារ) | យ៉ាងតិច ២ពាន់លាន រៀល (៥០០.០០ដុល្លារ) |
| ចំណេញសុទ្ធ | យ៉ាងតិច២ពាន់លានរៀល (៥០០.០០០ដុល្លារ) នៃឆ្នាំសារពើពន្ធមុនការ ដាក់ពាក្យស្នើសុំ និង ៣ពាន់លានរៀល(៧៥០.០០០ ដុល្លារ)នៃប្រាក់ ចំណេញសរុប សម្រាប់ រយៈពេល២ឆ្នាំចុងក្រោយ | ត្រូវមានប្រាក់ចំណេញសុទ្ធ នៅឆ្នាំសារពើពន្ធចុងក្រោយ ឬត្រូវមានលំហូរសាច់ប្រាក់ពីសកម្មភាពអាជីវកម្មវិជ្ជមាន និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងតិច១០% |
| ភាគហ៊ុនិក កាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង១% | ត្រូវមានចំនួនយ៉ាងតិច ២០០នាក់ និង ៧%នៃចំនួន ភាគហ៊ុនមានសិទ្ធិបោះ ឆ្នោតសរុប | ត្រូវមានចំនួនយ៉ាងតិច ១០០ នាក់ និងយ៉ាងតិច ១០%នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប |
| របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម | ២ឆ្នាំ | ១ឆ្នាំ |

| | |
|---|---|
| មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ១ឆ្នាំចុងក្រោយរហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ។ | |
| មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើរនៅប្រតិបត្តិកររក្សារទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី ន.ម.ក. | |

តារាង ៣.២៖ លក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ៣.១.២. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ [56]

ការធ្វើហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈជាមធ្យោបាយមួយដែលអនុញ្ញាតឲ្យក្រុមហ៊ុនធានានូវនិរន្តរភាពអាជីវកម្មរបស់ខ្លួន។ ដើម្បីឲ្យដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈមានភាពរលូន ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាបុគ្គលពាក់ព័ន្ធគប្បីត្រូវស្វែងយល់ពី យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈដូចខាងក្រោម៖

**១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រជាសាធារណៈជូន ន.ម.ក.៖**

នៅក្នុងលិខិតសម្តែងឆន្ទៈ ក្រុមហ៊ុនត្រូវបង្ហាញឲ្យច្បាស់ពីគោលបំណងនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈគម្រោងពេលរំពឹងទុក និងក្រុមការងារបោះផ្សាយលក់មូលបត្រដែលរំពឹងទុក (ក្រុមការងារ IPO)។

**២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ៖**

ក្រុមហ៊ុនធានាទិញជាដៃគូមិនអាចខ្វះបាន របស់ក្រុមហ៊ុនបោះផ្សាយ ក្នុងការជួយសម្របសម្រួល ឲ្យដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងទទួលបានជោគជ័យ។ ក្រុមហ៊ុនបោះផ្សាយអាចស្វែងរកបញ្ជីឈ្មោះក្រុមហ៊ុនធានាទិញបានដែលមាននៅលើគេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ។

**៣. ការបង្កើតក្រុមការងារ IPO៖**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗ ពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជា ក្រុមហ៊ុនផ្តល់សេវាសវនកម្ម មេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ (ប្រសិនមាន) ជាដើម ដែលទទួលស្គាល់ពី ន.ម.ក. ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រជាសាធារណៈស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយ លើការជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្ម មេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ (ប្រសិនមាន)។

**៤. ត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់៖**

ក្រុមហ៊ុនបោះផ្សាយមូលបត្រចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតួកិច្ចតាមច្បាប់។ ការងារ

[56] ហេង ច័ន្ទបូលីន(២០២២-២០២៣) ទីផ្សារមូលបត្រកម្ពុជា ទំព័រ៩៥

នេះ ត្រូវធ្វើដោយក្រុមការងារ IPO។

**៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)៖**

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ផ.ម.ក. ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពី ផ.ម.ក. ។

**៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក.៖**

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈមក ន.ម.ក.។ ន.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយមូលបត្រ។

**៧. ការកំណត់ថ្លៃលក់មូលបត្រ៖**

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រ ពោលគឺការស្ទាបស្ទង់ថ្លៃលក់មូលបត្រជាមួយវិនិយោគិនសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**៨. ការស្នើសុំបញ្ជាក់ការដាក់ថ្លៃមូលបត្រពី ផ.ម.ក.៖**

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំសំណើសុំការបញ្ជាក់ការដាក់ថ្លៃមូលបត្រពី ផ.ម.ក.។ ផ.ម.ក. ត្រូវបញ្ជាក់ថ្លៃលក់មូលបត្រអាចដាក់លក់នៅទីផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ។

**៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបាននូវការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក.៖**

ក្រោយពីបញ្ចប់ការកំណត់ថ្លៃលក់មូលបត្ររួចហើយ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់ថ្លៃមូលបត្រពីផ.ម.ក. រួចដាក់ជូន ន.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**១០. ការធ្វើបរិវិសកម្មមូលបត្រ៖**

ការធ្វើបរិវិសកម្មមូលបត្រ សំដៅដល់ដំណើរការនៃការទិញមូលបត្រ ទៅតាមចំនួនដែលវិនិយោគិនបានព្រមព្រៀង ឬលើសពីចំនួនដែលបានព្រមព្រៀងក្នុងដំណាក់កាលប៊ុកបៀលឌីង។ ក្រោយទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ។

**១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ៖**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន ន.ម.ក.។

**១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា៖**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រ ទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីលក់មូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនមូលបត្រ នឹងជួយក្រុមហ៊ុនបោះផ្សាយនូវរាល់ដំណាក់កាលទាំងអស់នៃដំណើរការ IPO នេះ។

**៣.១.៣. យន្តការទីផ្សារដំបូង**




រូបភាព ៣.១៖ យន្តការទីផ្សារដំបូង

ទីផ្សារដំបូង គឺជាទីផ្សារសម្រាប់ការជួញដូរមូលបត្ររវាងវិនិយោគិន និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនអាចកៀរគរមូលធន ឬទទួលបានហិរញ្ញប្បទានបន្ថែម សម្រាប់បន្តការវិនិយោគ ឬពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន តាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈដល់វិនិយោគិន។

នៅក្នុងន័យនេះ ដើម្បីទិញមូលបត្រពីទីផ្សារដំបូង វិនិយោគិនត្រូវធ្វើការបញ្ជាទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយនៅក្នុងដំណាក់កាលប៊ុកបៀលឌីង (Book building) ឬការស្ទាបស្ទង់ថ្លៃ និង/ឬការធ្វើបរិវិសកម្ម (subscription) ឬការចុះឈ្មោះទិញ។ បន្ថែមពីនេះ លំហូរសាច់ប្រាក់នៅក្នុងទីផ្សារដំបូង គឺចេញពីវិនិយោគិនទៅកាន់ក្រុមហ៊ុនបោះផ្សាយ ហើយវិនិយោគិនដែលបានទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយនឹងក្លាយជាភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយនោះ។

## ៣.២. ដំណើរការជួញដូរភាគហ៊ុននៅក្នុងផ្សារមូលបត្រកម្ពុជា

បន្ទាប់ពីទីផ្សារដំបូងត្រូវបានបញ្ចប់ ការទិញ-លក់មូលបត្រ ត្រូវធ្វើឡើងនៅទីផ្សារបន្ទាប់រវាងវិនិយោគិន និងវិនិយោគិន។ វិនិយោគិនអាចធ្វើការទិញ-លក់មូលបត្រនៅ ផ.ម.ក. បានតាមរយៈក្រុមហ៊ុនមូលបត្រ ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ (លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ) និងចាប់ផ្តើមជួញដូរពីម៉ោង ៨:០០ ព្រឹក រហូតដល់ម៉ោង ៣:០០ រសៀល។ បច្ចុប្បន្ន សម្រាប់ការទិញ-លក់មូលបត្រកម្មសិទ្ធិវិនិយោគិនអាចធ្វើការដាក់បញ្ជាដោយខ្លួនឯងផ្ទាល់តាមរយៈកម្មវិធី (Applications) ក្នុងទូរស័ព្ទដៃឆ្លាតឈ្មោះថា « ស៊ី អេស អ៊ិកត្រេដ (CSX Trade) »។




រូបភាព ៣.២៖ ដំណើរការជួញដូរភាគហ៊ុននៅក្នុងផ្សារមូលបត្រកម្ពុជា

### ៣.២.១. ដំណាក់កាលដំបូងមុននឹងការចាប់ផ្តើមជួញដូរមូលបត្រ

បុគ្គលដែលមានបំណងធ្វើការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជាជាដំបូងត្រូវយល់ដឹង និងអនុវត្តតាមចំណុចគន្លឹះដូចខាងក្រោម៖[57]

[57] និយ័តករមូលបត្រកម្ពុជា ព្រឹត្តិបត្រមូលបត្រលេខ១៣ ២០២២ ទំព័រ៧-៩

### ៣.២.១.១. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន

ដើម្បីអាចធ្វើការជួញដូរមូលបត្រកម្មសិទ្ធ និងមូលបត្របំណុល នៅក្នុងទីផ្សារមូលបត្រកម្ពុជា បានជាដំបូងវិនិយោគិន ត្រូវស្នើសុំលេខអត្តសញ្ញានវិនិយោគិនដែលផ្តល់ដោយ **ន.ម.ក.**។ ការស្នើសុំអាចធ្វើឡើងតាមរយៈ **ន.ម.ក.** ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រណាមួយ ដើម្បីជួយធ្វើការស្នើសុំជំនួសឲ្យវិនិយោគិន។ បច្ចុប្បន្ននេះ ដើម្បីផ្តល់ភាពងាយស្រួល និងចំណេញពេលវេលា វិនិយោគិនអាចធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន តាមរយៈប្រព័ន្ធអនឡាញដោយខ្លួនឯងផ្ទាល់ផងដែរ ដោយគ្រាន់តែចូលទៅគេហទំព័រ id.serc.gov.kh ឬអាចចូលតាមរយៈគេហទំព័រ serc.gov.kh ហើយស្វែងរកពាក្យថា "**វិនិយោគិន**" បន្ទាប់មកធ្វើការចុចទៅលើពាក្យ "**លេខអត្តសញ្ញាណវិនិយោគិន**" នៅក្នុងនោះមានតំណភ្ជាប់ (Link: **ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ**)។ គួរបញ្ជាក់ផងដែរថាវិនិយោគិនម្នាក់អាចស្នើសុំលេខអត្តសញ្ញាណវិនិយោគិនបានតែមួយប៉ុណ្ណោះ ហើយលេខអត្តសញ្ញាណវិនិយោគិនមានសុពលភាពរយៈពេល ១០ឆ្នាំ។

### ៣.២.១.២. ការបើកគណនីជួញដូរ

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី **ន.ម.ក.** វិនិយោគិនត្រូវធ្វើការទាក់ទងទៅក្រុមហ៊ុនមូលបត្រណាមួយដែលទទួលបានអាជ្ញាបណ្ណពី **ន.ម.ក.** ដើម្បីធ្វើការបើកគណនីជួញដូរ។ មុនពេលជ្រើសរើសប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនមូលបត្រណាមួយ វិនិយោគិនគួរតែធ្វើការពិចារណា ទៅលើកត្តាមួយចំនួនដូចជា៖ សេវាកម្ម កម្រៃជើងសារ សិទ្ធិ និងកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងអតិថិជនជាដើម។

វិនិយោគិនអាចបើកគណនីជួញដូរតែមួយប៉ុណ្ណោះនៅក្រុមហ៊ុនមូលបត្រមួយ មានន័យថា វិនិយោគិនអាចបើកគណនីជួញដូរលើសពីមួយបាននៅក្រុមហ៊ុនមូលបត្រផ្សេងៗគ្នា។

ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **ន.ម.ក.** មានចំនួន ១២ ក្រុមហ៊ុន រួមមានដូចខាងក្រោម៖[58]

១. យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី / Yuanta Securities (Cambodia) Plc.

២. អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក / RHB Securities (Cambodia) PLC.

៣. កាណា ស៊ីឃ្យូរីធី អិលធីឌី / Cana Securities Ltd.

៤. កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី / Campu Securities Plc.

៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី / SBI Royal Securities Plc.

៦. ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី / Phnom Penh Securities Plc.

[58] https://www.serc.gov.kh/khmer/m45.php?pn=5 (ចូលទស្សនាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣)

៧. ខេមបូឌា ស៊ីឃ្យូរីធី ម.ក / Cambodia Securities PLC.

៨. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី / ACLEDA Securities Plc.

៩. ខេប ស៊ីឃ្យូរីធី លីមីធីត / CAB Securities Limited

១០. ខេមបូឌា- វៀតណាម ស៊ីឃ្យូរីធី ឯ.ក. / Cambodia-Vietnam Securities Co., Ltd

១១. ក្រុមហ៊ុន ភីភី លីង ស៊ីឃ្យូរីធី ឯ.ក. / PP Link Securities Co., Ltd

១២. គោលដេន ហ្វ៍រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី / Golden Fortune (Cambodia) Securities Plc.

#### ៣.២.១.៣. ការស្វែងយល់ពីច្បាប់ និងមូលដ្ឋានគ្រឹះក្នុងការជួញដូរ

ដើម្បីចៀសវាងហានិភ័យ និងទោសទណ្ឌនានា វិនិយោគិនត្រូវយល់ដឹងអំពីច្បាប់បទប្បញ្ញត្តិ និង គោលនយោបាយណែនាំពាក់ព័ន្ធមួយចំនួន មុនពេលធ្វើការសម្រេចចិត្តវិនិយោគនៅលើទីផ្សារមូលបត្រកម្ពុជា៖

- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- អនុក្រឹត្រស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- វិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ **ផ.ម.ក.**
- វិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្ររបស់ **ផ.ម.ក.**
- វិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ **ផ.ម.ក.**
- បទប្បញ្ញត្តិ និងគោលការណ៍ណែនាំពាក់ព័ន្ធផ្សេងៗទៀត។

***<u>សូមបញ្ជាក់៖</u>*** វិនិយោគិនអាចស្វែងរកឯកសារពាក់ព័ន្ធនឹងកម្រងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រ ដោយចូលទៅក្នុងគេហទំព័រ https://www.serc.gov.kh/khmer/m23.pkp?pn=3 ដើម្បីទទួលបាននូវឯកសារលម្អិតបន្ថែមទៀត។

### ៣.២.២. ប្រតិបត្តិការទីផ្សារ

#### ៣.២.២.១. ថ្ងៃ និងម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពី ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។ ចំណែកឯម៉ោងជួញដូរចាប់ផ្តើមម៉ោង ៨:០០ព្រឹក ដល់ម៉ោង០៣:០០រសៀល ដែលបែងចែកទៅតាមវគ្គដូចខាងក្រោម៖

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងអនុវត្តការជួញដូរ | វិធីសាស្ត្រ |
|---|---|---|---|
| វគ្គបើក | ៨:00 - ៩:00 | ៩:00 | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:00 - ១៤:៥0 | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១៤:៥0 - ១៥:00 | ១៥:00 | ដេញថ្លៃដោយយកថ្លៃតែមួយ |

តារាង ៣.៣៖ ពេលវេលានៃការជួញដូរ

ប្រសិនបើគ្មានការផ្គូផ្គងបញ្ជានៅម៉ោង ៩:00 នាទីព្រឹកទេ នោះវគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។ ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា ម៉ោងជួញដូរ គឺចាប់ពីម៉ោង៩:00នាទីព្រឹកដល់ម៉ោង0៣:00នាទីរសៀល ។[59]

### ៣.២.២.២. ប្រភេទបញ្ជា

នាពេលបច្ចុប្បន្ន មានបញ្ជាចំនួន៣ប្រភេទសំខាន់ៗដែលត្រូវដាក់ឱ្យដំណើរការនៅ ផ.ម.ក. មានដូចខាងក្រោម៖

**ក. បញ្ជាដែនកំណត់** (Limit Order)

ជាបញ្ជាដែលថ្លៃបញ្ជាទិញ គឺជាថ្លៃដែលហ៊ានទិញខ្ពស់បំផុត ហើយថ្លៃបញ្ជាលក់គឺជាថ្លៃដែលហ៊ានលក់ទាបបំផុត។

**ឧទាហរណ៍៖** បញ្ជាដែនកំណត់ទិញដែលមានថ្លៃ៤.000រៀល អាចជួញដូរបាន នៅថ្លៃ៤.000រៀល ឬទាបជាងនេះ ចំណែកបញ្ជាដែនកំណត់លក់ដែលមានថ្លៃ៤.000រៀល អាចជួញដូរបាន នៅថ្លៃ៤.000រៀល ឬខ្ពស់ជាងនេះ។

**ខ. បញ្ជាទីផ្សារ** (Market Order)

ជាបញ្ជាដើម្បីទិញ ឬលក់មូលបត្រកម្មសិទ្ធិមួយភ្លាមៗនៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ និងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូងឡើយ។ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌ២គឺ លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល និងលក្ខខណ្ឌជួញដូរហើយលុបចោល។ លក្ខខណ្ឌទាំងពីរនេះអាចប្រើប្រាស់បានតែក្នុងវិធីសាស្ត្រដេញថ្លៃដោយការយកថ្លៃច្រើន និងនៅពេលដែលមានបញ្ជាផ្ទុយគ្នានៅផ្នែកម្ខាងទៀត។

- **លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល** (Fill or Kill) ៖ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាមៗ ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងភ្លាមៗ។

[59] http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២0២៣)

**ឧទាហរណ៍៖** បញ្ជាទិញភាគហ៊ុន **ក** នៃបញ្ជាទីផ្សារ តាមលក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោលដែលមានបរិមាណចំនួន ២០០ អាចផ្គូផ្គងបានលុះត្រាតែបរិមាណនៃបញ្ជាលក់ម្ខាងទៀតមានចំនួនច្រើនជាងឬស្មើ ២០០។

- **លក្ខខណ្ឌជួញដូរ ហើយលុបចោល** (Fill and Kill)៖ ជាលក្ខខណ្ឌដែលកំណត់ថា បញ្ជានឹងត្រូវលុបចោលភ្លាមៗ ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុង ឬមួយផ្នែកភ្លាមៗ។ ក្នុងករណីដែលបរិមាណនៃបញ្ជានោះ ត្រូវបានផ្គូផ្គងមួយផ្នែក បញ្ជាដែលមានបរិមាណនៅសល់នោះនឹងត្រូវលុបចោលភ្លាម។

**ឧទាហរណ៍៖** បញ្ជាទិញភាគហ៊ុន ខ នៃបញ្ជាទីផ្សារតាមលក្ខខណ្ឌជួញដូរ ហើយលុបចោល ដែលមានបរិមាណចំនួន ២០០ ត្រូវបានផ្គូផ្គងជាមួយបញ្ជាលក់នៃគ្រប់បរិមាណមូលបត្រ (ឧទាហរណ៍ចំនួន៥០)។ បរិមាណភាគហ៊ុនដែលនៅសល់បន្ទាប់ពីការផ្គូផ្គងចំនួន ១៥០ នឹងត្រូវលុបចោលភ្លាមដោយស្វ័យប្រវត្តិ។

| លក្ខណៈ | បញ្ជាដែនកំណត់ | បញ្ជាទីផ្សារ |
|---|---|---|
| **អាទិភាព** | ជាទូទៅ មានអាទិភាពថ្លៃទាបជាងបញ្ជាទីផ្សារ លើកលែងនៅដែន កំណត់ថ្លៃខាងលើ ឬខាងក្រោមដែល អាទិភាពពេលវេលាត្រូវបានអនុវត្ត។ | ជាទូទៅ មានអាទិភាពថ្លៃខ្ពស់ជាងទីផ្សារ លើកលែងនៅដែនកំណត់ថ្លៃខាងលើ ឬខាងក្រោម ដែលអាទិភាពពេលវេលា ត្រូវបាន អនុវត្ត។ |
| **គោលការណ៍ផ្គូផ្គង** | អាទិភាពថ្លៃ និងអាទិភាពពេលវេលា ត្រូវបានអនុវត្ត | អាទិភាពថ្លៃ និងអាទិភាពពេលវេលាត្រូវបាន អនុវត្ត |
| **លក្ខខណ្ឌភ្ជាប់ជាមួយ** | គ្មាន | លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល និងលក្ខខណ្ឌជួញដូរហើយលុបចោល ត្រូវបានអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន |
| **ការបង្ហាញថ្លៃក្នុងប្រព័ន្ធទទួលបញ្ជា** | នៅថ្លៃដែលបានកំណត់ | • នៅថ្លៃល្អបំផុតនៃបញ្ជាដែនកំណត់±១ ឯកតាគម្លាតថ្លៃ នៅពេលមានបញ្ជាដែនកំណត់<br>• ថ្លៃចុងក្រោយ ករណីគ្មានបញ្ជាដែនកំណត់ |
| **ការកែប្រែបញ្ជា** | អនុញ្ញាត | មិនអនុញ្ញាត |
| **ការលុបបញ្ជា** | អនុញ្ញាត | អនុញ្ញាត |

| | | |
|---|---|---|
| **ការបង្កកសាច់ប្រាក់** | សាច់ប្រាក់បង្កក ស្មើនឹងថ្លៃគុណនឹងបរិមាណបញ្ជាបូក បន្ថែមថ្លៃសេវាឈ្នួញជើងសារមូលបត្រ | សាច់ប្រាក់បង្កក ស្មើនឹងថ្លៃដែនកំណត់ខាងលើគុណនឹងបរិមាណបញ្ជា បូកបន្ថែមថ្លៃសេវាឈ្នួញជើងសារមូលបត្រ |
| **បំរាម** | គ្មាន | • ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ<br>• ការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង |

តារាង ៣.៤៖ ប្រភេទបញ្ជា

**គ. បញ្ជាតាមការចរចា**

ជាបញ្ជាដើម្បីទិញ ឬលក់មូលបត្រតាមវិធីសាស្ត្រជួញដូរតាមការចរចា។ បញ្ជាប្រភេទនេះធានាដល់ការជួញដូររបស់វិនិយោគិននៅក្នុងតែមួយប្រតិបត្តិការធំប៉ុណ្ណោះ និងផ្តល់ភាពសម្ងាត់ដល់បញ្ជា និងការជួញដូររបស់វិនិយោគិនក្នុងអំឡុងម៉ោងជួញដូរ។

ការកែតម្រូវ ឬការលុបបញ្ជាអាចធ្វើទៅបានដរាបណាបញ្ជានោះមិនទាន់ត្រូវបានអនុវត្តការជួញដូរទេ។ ពេលវេលាបញ្ជាក់ពីការទទួលបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ត្រូវបានកំណត់សាជាថ្មី នៅពេលដែលមានការកែប្រែថ្លៃ ឬការបង្កើនបរិមាណនៃបញ្ជា។[60]

**៣.២.២.៣. ការដាក់បញ្ជាទិញ និងលក់**

ក្នុងរយៈពេលយ៉ាងហោចណាស់មួយថ្ងៃ បន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់**ផ.ម.ក.** ដើម្បីធ្វើការជួញដូរបាន។ វិនិយោគិនអាចធ្វើការដាក់បញ្ជាទិញ ឬលក់មូលបត្រទៅកាន់ក្រុមហ៊ុនមូលបត្រ ដែលខ្លួនបានជ្រើសរើស តាមរយៈការអញ្ជើញទៅក្រុមហ៊ុនមូលបត្រនោះដោយផ្ទាល់ ជាឯកសារជាលាយលក្ខណ៍អក្សរ ការហៅទូរស័ព្ទ សារជាសំឡេង អ៊ីម៉ែល ឬវិធីសាស្ត្រអេឡិចត្រូនិចផ្សេងៗទៀត ហើយជាពិសេសវិនិយោគិនអាចប្រើប្រាស់នូវប្រព័ន្ធជួញដូរចល័ត (MTS Mobile Trading System) របស់ ផ.ម.ក. បានផងដែរ។ ដើម្បីធ្វើការដាក់បញ្ជាបានសម្រេច វិនិយោគិនត្រូវភ្ជាប់មកជាមួយនូវ ព័ត៌មានលម្អិតនៃការដាក់បញ្ជា និងត្រូវមានសាច់ប្រាក់យ៉ាងហោចណាស់ ១០០% សម្រាប់បញ្ជាទិញ ឬមានមូលបត្រយ៉ាងហោចណាស់ ១០០% សម្រាប់ការដាក់បញ្ជាលក់។[61]

---

[60] http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣)

[61] http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)

### ៣.២.២.៤. ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលបានដាក់ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ត្រូវមានព័ត៌មានលម្អិតដូចជា៖

១. ឈ្មោះមូលបត្រ

២. បរិមាណ

៣. ថ្លៃករណីក្រៅពីបញ្ជាទីផ្សារ

៤. លេខកូដជួញដូរតាមការចរចា ចំពោះបញ្ជាតាមការចរចា

៥. ការបញ្ជាក់ពីបញ្ជា៖ បញ្ជាទិញ ឬបញ្ជាលក់

៦. ប្រភេទនៃប្រតិបត្តិករ៖ ប្រតិបត្តិករគណនីអតិថិជន ឬប្រតិបត្តិករគណនីសមាជិក

៧. លេខអត្តសញ្ញាណសមាជិក

៨. លេខអត្តសញ្ញាណវិនិយោគិន

៩. លេខបញ្ជា

១០. លេខគណនីជួញដូរ

១១. ក្នុងករណីលុប ឬកែប្រែបញ្ជាត្រូវបញ្ជាក់ថាជាការលុប ឬជាការកែប្រែហើយត្រូវបញ្ជាក់ លេខបញ្ជាដើមផងដែរ

១២. លេខកូដវិនិយោគិន៖ ជារូបវន្តបុគ្គល ឬនីតិបុគ្គល

១៣. លេខកូដប្រទេសរបស់វិនិយោគិន។

### ៣.២.២.៥. ឯកតាបញ្ជា និង ឯកតាគម្លាតថ្លៃ

ឯកតាបញ្ជានៃមូលបត្រកម្មសិទ្ធិនៅ **ផ.ម.ក.** គឺ ០១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។ ថ្លៃភាគហ៊ុននៅ **ផ.ម.ក.** អាស្រ័យលើឯកតាគម្លាតថ្លៃដែលបានកំណត់ដូចខាងក្រោម៖[62]

[62] http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)

| ថ្លៃមូលដ្ឋាន (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាដែលខុស | ឧទាហរណ៍ថ្លៃបញ្ជាដែលត្រឹមត្រូវ |
|---|---|---|---|
| P < ៥.000 | ១០ | ២.៥៥៥, ៣.០១២, ៣.៩៩៩ | ២.៥៥០, ២.៥៦០, ៣.០១០, ៣.០២០, ៣.៩៩០ |
| ៥.000 ≤ P < ២០.000 | ២០ | ៥.២១០, ១៩.៥២៥ | ៥.២០០, ៥.២២០, ១៩.៥២០, ១៩.៥៤០ |
| ២០.000 ≤ P < ៥០.000 | ៥០ | ២០.១១០, ៣៥.៥៣០ | ២០.១០០, ២០.១៥០, ៣៥.៥០០, ៣៥.៥៥០ |
| ៥០.000 ≤ P< ១០០.000 | ១០០ | ៥០.៧២០, ៩០.៤៥០ | ៥០.៧០០, ៥០.៨០០, ៩០.៤០០, ៩០.៥០០ |
| ១០០.000 ≤ P< ២០០.000 | ២០០ | ១៥០.៥០០, ១២៥.៣០០ | ១៥០.៤០០, ១៥០.៦០០, ១២៥.២០០ , ១២៥.៤០០ |
| ២០០.000 ≤ P< ៥០០.000 | ៥០០ | ៣០០.១០០; ៣៥០.២០០ | ៣០០.000; ៣០០.៥០០; ៣៥០.000; ៣៥០.៥០០ |
| P ≥ ៥០០.000 | ១.000 | ៦២០.500; ៨៥២.១០០ | ៦២០.000; ៦២១.000; ៨៥២.00; ៨៥៣.000 |

តារាង៣.៥៖ ឯកតាបញ្ជា និងឯកតាគម្លាតថ្លៃ

### ៣.២.២.៦. ថ្លៃមូលដ្ឋាន

ថ្លៃមូលដ្ឋាន ជាថ្លៃគោលដែលប្រើប្រាស់សម្រាប់គណនាដែនកំណត់ថ្លៃប្រចាំថ្ងៃ។ ជាទូទៅថ្លៃមូលដ្ឋានគឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។ ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់លើកដំបូងត្រូវស្ថិតនៅចន្លោះ ៩០% ទៅ ១៥០% នៃថ្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង។

ក្នុងករណីដែលមានសិទ្ធិកម្មសិទ្ធិករមូលបត្រដូចជា ការបង្កើន ឬបន្ថយមូលធន ការបែងចែកភាគលាភជាភាគហ៊ុនការបំបែកភាគហ៊ុន ។ល។ នោះថ្លៃមូលដ្ឋាននឹងត្រូវបានគណនាដោយផ្អែកលើរូបមន្ត ដូចបានចែងនៅក្នុងវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។[63]

[63] http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)

**ឧទាហរណ៍៖** ករណីចែកភាគលាភជាភាគហ៊ុន

ថ្លៃមូលដ្ឋាន = មូលធនូបនីយកម្មទីផ្សារសរុបមុនបែងចែកភាគលាភ / ចំនួនភាគហ៊ុនបន្ទាប់ពីទទួលបានភាគលាភ

មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភ = ថ្លៃបិទ x ចំនួនភាគហ៊ុនមុនទទួលបានភាគលាភ

ក្នុងករណីថ្លៃមូលបត្រទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវបង្គត់ទៅលើឲ្យស្មើនឹងឯកតាគម្លាតថ្លៃ។

#### ៣.២.២.៧. ថ្លៃពិសេស

ទោះបីជាគ្មានប្រតិបត្តិការជួញដូរពេញមួយថ្ងៃក៏ដោយ ថ្លៃភាគហ៊ុនក៏អាចប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងអំពីទំនោរទីផ្សារដែលកើតចេញពីភាពលើសនៃផ្គត់ផ្គង់ ឬតម្រូវការនៃភាគហ៊ុននៅលើទីផ្សារ។ ក្នុងករណីនេះថ្លៃពិសេសត្រូវបានយកមកប្រើប្រាស់។

ថ្លៃពិសេស សំដៅលើថ្លៃបិទនៃភាគហ៊ុនមួយដែលគ្មានការជួញដូររហូតដល់ម៉ោងបិទទីផ្សារ។ ថ្លៃពិសេសអាចជាថ្លៃល្អបំផុតនៃសំណើលក់ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងសម្រាប់ថ្ងៃជួញដូរលើកដំបូង (សម្រាប់ថ្ងៃជួញដូរលើកដំបូង) ឬជាថ្លៃល្អបំផុតនៃសំណើទិញ ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (សម្រាប់ថ្ងៃជួញដូរលើកដំបូង)។[64]

- ថ្លៃល្អបំផុតនៃសំណើលក់ (Best Ask) ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងសម្រាប់ថ្ងៃជួញដូរលើកដំបូង
- ថ្លៃល្អបំផុតនៃសំណើទិញ (Best Bid) ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងសម្រាប់ថ្ងៃជួញដូរលើកដំបូង។

**ឧទាហរណ៍៖**

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | ៦.០៨០ | ③១០០ |
| | ៦.០៤០ | ①៣០០ ②២០០ |
| **ថ្លៃមូលដ្ឋាន** | **៦.០២០** | |

តារាង៣.៦៖ ថ្លៃពិសេស

[64] http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)

នៅពេលដែលគ្មានការជួញដូររហូតដល់ពេលបិទផ្សារថ្លៃបិទនៃទីផ្សារដែលមានស្ថានភាពបញ្ជាដូចក្នុងតារាងខាងលើគឺ ៦.០៨០ រៀល (ថ្លៃពិសេស)។

### ៣.២.២.៨. វិធីសាស្ត្រជួញដូរភាគហ៊ុន

វិធីសាស្ត្រជួញដូរភាគហ៊ុន ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រ ចំនួនពីរគឺ វិធីសាស្ត្រដេញថ្លៃ (ATM) និង វិធីសាស្ត្រជួញដូរតាមការចរចា (NTM)។

**ក. វិធីសាស្ត្រដេញថ្លៃ**

**១. គោលការណ៍ដេញថ្លៃ៖**

រាល់ការជួញដូរត្រូវបានអនុវត្តតាមវិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន យោងទៅតាមអាទិភាពថ្លៃ និងអាទិភាពពេលវេលាដូចមានខាងក្រោម៖

- អាទិភាពថ្លៃ

បញ្ជាលក់ដែលមានថ្លៃទាបជាងមានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង និងបញ្ជាទិញដែលមានថ្លៃខ្ពស់ជាងមានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

- អាទិភាពពេលវេលា

ក្នុងករណីបញ្ជាមានថ្លៃដូចគ្នាបញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

**ឧទាហរណ៍៖**

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | : | |
| | ៦.៥០០ | ①៥០០ (បញ្ជាទិញដែលមានថ្លៃ ខ្ពស់ជាង) |
| | ៦.៤៨០ | ②១០០ ③២០០ |
| | ៦.៤៦០ | |
| | ៦.៤២០ | |
| ③៣០០ ②២០០ | ៦.៤០០ | |
| (បញ្ជាលក់ដែលមានថ្លៃទាបជាង)①៤៥០ | | |
| | : | |

តារាង៣.៧៖ វិធីសាស្ត្រដេញថ្លៃ

- ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើបញ្ជាទិញ①និងបញ្ជាលក់① ត្រូវអនុវត្តការជួញដូរមុនយោងទៅតាមអាទិភាពថ្លៃ។

- ក្នុងចំណោមបញ្ជាដែលមានថ្លៃដូចគ្នាបញ្ជា②ដែលទទួលបានមុននឹងត្រូវអនុវត្តការជួញដូរមុនបញ្ជា③

**២. វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ៖**

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ ត្រូវអនុវត្តតាមថ្លៃកំណត់មួយដែលហៅថា ថ្លៃជួញដូរ។

**៣. វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ៖**

តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន បញ្ជាមួយអាចជួញដូរបាននៅថ្លៃច្រើនខុសពីគ្នា។ នៅពេលបញ្ជាទិញដែលមានថ្លៃខ្ពស់ជាងគេ ផ្គូផ្គងជាមួយបញ្ជាលក់ដែលមានថ្លៃទាបជាងគេ ថ្លៃជួញដូរ គឺជាថ្លៃនៃបញ្ជាដែលទទួលបានមុន។

**ខ. វិធីសាស្ត្រជួញដូរតាមការចរចា**

វិធីសាស្ត្រជួញដូរតាមការចរចា ជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចា ទិញ និងលក់មួយគូរ បន្ទាប់ពីអ្នកទិញ និងអ្នកលក់បានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ ដើម្បីផ្គូផ្គងបញ្ជាទិញ និងលក់តាមការចរចារមួយគូបាន ចាំបាច់ត្រូវតែមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងចំនួន៤ គឺ ឈ្មោះមូលបត្រ ថ្លៃ បរិមាណ និងលេខកូដជួញដូរតាមការចរចា។ លក្ខណៈសំខាន់ៗ នៃវិធីសាស្ត្រជួញដូរតាមការចរចារៈ

- បញ្ជាអប្បបរមាៈ បញ្ជាតាមការចរចា ត្រូវមានបរិមាណយ៉ាងហោច ៥០.០០០ ភាគហ៊ុន ឬតម្លៃជួញដូរ ២០០.០០០.០០០រៀល (យកមួយណាដែលតូចជាង)។
- ឯកតាគម្លាតថ្លៃៈ១រៀល ។
- ដែនកំណត់ថ្លៃប្រចាំថ្ងៃៈ មិនអនុវត្តចំពោះការជួញដូរតាមវិធីសាស្ត្រជួញដូរតាមការចរចា។
- ការលុបចោលបញ្ជាៈ ដរាបណាបញ្ជាមិនទាន់អនុវត្តការជួញដូរ នោះបញ្ជាតាមការចរចាអាចលុបបាន តែពុំអាចកែប្រែបានឡើយ។[65]

### ៣.២.២.៩. នីតិវិធីក្នុងការបើកគណនី និងនីតិវិធីក្នុងការជួញដូរ

**១. នីតិវិធីក្នុងការបើកគណនី**

– វិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រមួយ ក្នុងចំណោមក្រុមហ៊ុនមូលបត្រទាំង១២ ដែលជាសមាជិករបស់ ផ.ម.ក. ហើយក្រុមហ៊ុនមូលបត្រនោះ នឹងជួយវិនិយោគិនក្នុងការបើកគណនីជួញដូរ។

– បើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រដែលបានជ្រើសរើស ចំពោះឯកសារតម្រូវដើម្បីបើកគណនីជួញដូរ រួមមានៈ

[65] http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស) ភ្ជាប់ជាមួយរូបថត ៤×៦ មួយសន្លឹក
- លេខអត្តសញ្ញាណវិនិយោគិន (ក្រុមហ៊ុនមូលបត្រអាចជួយធ្វើការស្នើសុំពីនិយ័តករមូលបត្រកម្ពុជា)

– យ៉ាងហោចណាស់មួយថ្ងៃបន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. បាន។

### ២. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ

វិនិយោគិនអាចដាក់បញ្ជាបាន លុះត្រាតែមានសាច់ប្រាក់យ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាទិញ) ដែលរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសារមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាលក់)។ ពេលបញ្ជាត្រូវបានបញ្ជូនចេញទៅសាច់ប្រាក់ និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយសមាជិកក្នុងគោលបំណងដើម្បីទូទាត់ ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់សុពលភាព។[66]




រូបភាព ៣.៣៖ ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ

(១) វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រនៅថ្ងៃT-1។ ក្រុមហ៊ុនមូលបត្រនឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីនិយ័តករមូលបត្រកម្ពុជា។

66 http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣)

(២) វិនិយោគិនដាក់បញ្ជាទិញឬលក់នៅថ្ងៃ T+0 តាមប្រព័ន្ធជួញដូរចល័ត (MTS) ឬក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរជាពាក្យសម្តី (ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) ឬតាមមធ្យោបាយអេឡិចត្រូនិចនានា។

(៣) បន្ទាប់ពីដាក់បញ្ជាមកក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. នៅថ្ងៃ T+0 បានជោគជ័យដោយមានមូលបត្រនិងសាច់ប្រាក់គ្រប់គ្រាន់នៅក្នុងគណនីរបស់វិនិយោគិន (សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ)សាច់ប្រាក់ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ T+2។

(៤) ការបញ្ជាទាំងឡាយត្រូវបានផ្គូផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន T+0។

(៥) **ផ.ម.ក.** ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+0។

(៦) ក្រុមហ៊ុនមូលបត្របញ្ជាក់អំពីលទ្ធផលនៃការជួញដូរជាមួយអតិថិជននីមួយៗរបស់ខ្លួននៅថ្ងៃ T+0។

(៧) ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់កាន់ ផ.ម.ក. ដើម្បីធ្វើការកែតម្រូវអោយបានមុនពេលថ្ងៃត្រង់នៃថ្ងៃT+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំណុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ **ផ.ម.ក.** នៅថ្ងៃ T+2។

### ៣.២.៣. ប្រតិបត្តិការផាត់ទាត់ និងទូទាត់

#### ៣.២.៣.១. ការផាត់ទាត់

ការផាត់ទាត់ គឺជាលំដាប់នៃដំណើរការដែល Central Counter-Party (CCP) ចាត់ចែងធានាលើការទូទាត់ដោយការបន្សុទ្ធ ឬកាត់កង netting ឥណទាន និងបំណុលទាំងឡាយរវាងអ្នកលក់ និងអ្នកទិញ។




រូបភាព ៣.៤៖ ការផាត់ទាត់

**ក.** Central Counter- party (CCP)

សំដៅទៅលើអង្គភាពដែលទទួលយកកាតព្វកិច្ចជាអ្នកទិញ ចំពោះអ្នកលក់ទាំងអស់ និងជាអ្នកលក់ចំពោះអ្នកទិញទាំងអស់។ តាមវិធីនេះអ្នកទិញ និងអ្នកលក់មិនមាន កាតព្វកិច្ចហិរញ្ញវត្ថុ ចំពោះគ្នាទៅវិញទៅមកទេ ផ្ទុយទៅវិញត្រូវមានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះ CCP។ ក្នុងករណីនេះ ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានតួនាទីជា CCP នៅក្នុងផ្សារមូលបត្រកម្ពុជា។




រូបភាព ៣.៥. Central Counter- Party (CCP)

**ខ. ការបន្សុទ្ធ ឬការកាត់កង** (Netting)

គឺជាដំណើរការនៃការកាត់បន្ថយកាតព្វកិច្ចឥណទាន ឬឥណពន្ធរបស់អ្នកជួញដូរជាច្រើនពីចំនួនច្រើនទៅចំនួនតិច។ តាមរយៈការបន្សុទ្ធ ផ.ម.ក គណនាទំហំដែលត្រូវទូទាត់ចុងក្រោយ។ បន្ទាប់ពីការបន្សុទ្ធ កាតព្វកិច្ចឥណទាន ឬឥណពន្ធដើមត្រូវបានជំនួសដោយកាតព្វកិច្ចឥណទាន ឬឥណពន្ធតែមួយ។ ទំហំដែលត្រូវទូទាត់ចុងក្រោយត្រូវបានគណនាតាមរបៀបដូចខាងក្រោម៖

- ករណីមូលបត្រ៖ ទទួលបានដោយធ្វើការបន្សុទ្ធបរិមាណបានលក់សរុប និងបរិមាណបានទិញសរុបចំពោះប្រភេទមូលបត្រមួយ និងចំពោះសមាជិកនីមួយៗ។
- ករណីសាច់ប្រាក់៖ ទទួលបានដោយធ្វើការផាត់ទាត់តម្លៃបានទិញសរុប និងតម្លៃបានលក់សរុបចំពោះសមាជិកនីមួយៗ។

**៣.២.៣.២. ការទូទាត់**

ការទូទាត់ គឺជាការបញ្ចប់ប្រតិបត្តិការ ដែលអ្នកលក់ផ្ទេរមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុទៅឲ្យអ្នកទិញ ហើយអ្នកទិញផ្ទេរសាច់ប្រាក់ទៅឲ្យអ្នកលក់។




រូបភាព ៣.៦៖ ការទូទាត់

➢ លក្ខណៈនៃការទូទាត់របស់ ផ.ម.ក.:

- វិធីសាស្ត្រនៃការទូទាត់៖ DVP3 (ការប្រគល់មូលបត្រ ថ្នូរនឹងសាច់ប្រាក់គំរូទី៣) DVP3 ជាដំណើរការនៃការប្រគល់មូលបត្រ ដែលត្រូវបានធ្វើឡើងនៅក្នុងពេលដំណាលគ្នានៃការប្រគល់សាច់ប្រាក់ ដោយផ្អែកលើមូលដ្ឋានបន្សុទ្ធ (បន្សុទ្ធមូលបត្រ និងបន្សុទ្ធសាច់ប្រាក់)។ វាត្រូវបានកើតឡើងនៅចុងគ្រានៃវដ្តដំណើរការប្រតិបត្តិការ។
- ពេលវេលានៃការទូទាត់៖ ម៉ោង៨ និង៣០ នាទីព្រឹក (T+2) សមាជិកត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ទៅគណនីរបស់ ផ.ម.ក. នៅមុនម៉ោង ៨:៣០ព្រឹក នៅកាលបរិច្ឆេទទូទាត់រួចហើយ ផ.ម.ក. ធ្វើការទូទាត់មូលបត្រ និងសាច់ប្រាក់បន្តទៅឲ្យសមាជិកដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ព្រឹក នៅថ្ងៃដដែលនៃកាលបរិច្ឆេទទូទាត់។[67]

### ៣.២.៣.៣. តួអង្គសំខាន់ៗនៅក្នុងយន្តការនៃការផាត់ទាត់ និងទូទាត់

ការផាត់ទាត់ និងទូទាត់មូលបត្រមានការចូលរួមពីភាគីពាក់ព័ន្ធមួយចំនួនដូចជា៖

- CSX: ប្រតិបត្តិករទីផ្សារមូលបត្រ
- CSO: ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
- CSD: ប្រតិបត្តិកររក្សាទុកមូលបត្រ
- SFs: ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក.
- CSAs: ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- NBC: ធនាគារជាតិនៃកម្ពុជា ។

[67] http://csx.com.kh/operation/clearing/listPosts.do?MNCD=3030 (ចូលទស្សនាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)

### ៣.២.៣.៤. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់




រូបភាព ៣.៧៖ ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់

(១). ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវបញ្ជូនព័ត៌មានអំពីការជួញដូរដែលបានបញ្ជាក់ច្បាស់ (Confirmed Trade) ទៅ CSO

- CSO ត្រូវធ្វើការបន្សុទ្ធ (Netting) សាច់ប្រាក់ និងមូលបត្រ

+បន្សុទ្ធសាច់ប្រាក់ = ផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សម្រាប់សមាជិកនីមួយៗ

+បន្សុទ្ធមូលបត្រ = ផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ

(២). CSO បញ្ជូនព័ត៌មាននៃកាលបរិច្ឆេទផាត់ទាត់ និងទូទាត់ទឹកប្រាក់ និងបរិមាណនៃមូលបត្រនីមួយៗដែលត្រូវធ្វើការទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជនទៅ SF(s)

(៣). SF(s) ត្រូវដាក់ការបញ្ជាទូទាត់សាច់ប្រាក់ទៅ CSA ដែលពាក់ព័ន្ធ

(៤). SF(s) ត្រូវដាក់ការបញ្ជាទូទាត់មូលបត្រទៅ CSD

**១. ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ**

(១) SF (អ្នកទិញ) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ទៅគណនីទូទាត់សាច់ប្រាក់របស់ CSO

(២) បន្ទាប់មក CSO ត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួនទៅគណនីសាច់ប្រាក់របស់ SF (អ្នកលក់)




រូបភាព ៣.៨៖ ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ

**២. ការទូទាត់សាច់ប្រាក់អន្តរធនាគារ**

(១). SF (អ្នកទិញ) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ទៅគណនីទូទាត់សាច់ប្រាក់របស់ CSO

(២). បន្ទាប់មក CSO ត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួនចូលទៅគណនីសាច់ប្រាក់របស់ SF (អ្នកលក់) ដែលបើកនៅក្នុង CSA2 តាមរយៈសភាផាត់ទាត់នៃ NBC ។




រូបភាព ៣.៩៖ ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់

**៣.២.៣.៥. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ**

(១). SF (អ្នកលក់) ត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅគណនីទូទាត់មូលបត្ររបស់ CSO។

(២). CSO ត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួនទៅគណនីមូលបត្ររបស់ SF (អ្នកទិញ)។




រូបភាព ៣.១០ ៖ ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ

**៣.២.៤. ប្រតិបត្តិការនៃការរក្សាទុកមូលបត្រ**

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ ហើយការដាក់ផ្ញើមូលបត្រគឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន / ឥណពន្ធក្នុងសៀវភៅគណនីរបស់សមាជិកនិងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវ័ន្ត។ ប្រតិបត្តិការរក្សាទុកមូលបត្រ គឺត្រូវចាប់ដំណើរការផ្ទេរមូលបត្រ (Book Entry Transfer) នៅថ្ងៃទីពីរនៃការជួញដូរ (T+២)

បន្ទាប់ពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវបានអនុវត្តចប់រវាង ក្រុមហ៊ុនមូលបត្រ និងអតិថិជន ដោយការផ្ទេរមូលបត្រត្រូវបានផ្ទេរតាមប្រព័ន្ធ Ledger System។

សមាជិក អ្នកចូលរួម និងអតិថិជនដែលបានដាក់ផ្ញើរមូលបត្រនៅ **ផ.ម.ក.** មិនចាំបាច់ដកមូលបត្រទៅវិញនៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។ បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ រួមមានក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រ ត្រូវបំពេញសំណុំបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់រួមមាន៖ គណនីមូលបត្ររបស់សមាជិក ឬអតិថិជនត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធLedger (ledger system) របស់ **ផ.ម.ក.** ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។[68]

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** បុគ្គលដែលដាក់ផ្ញើរត្រូវផ្តល់ព័ត៌មានដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារបញ្ជិកាមូលបត្រដូចខាងក្រោម៖

- ឈ្មោះមូលបត្រដែលដាក់ផ្ញើ
- ប្រភេទមូលបត្រដែលដាក់ផ្ញើ
- ថ្លៃមូលបត្រដែលដាក់ផ្ញើ
- ចំនួនមូលបត្រដែលដាក់ផ្ញើ
- ចំនួនមូលបត្រដែលបានបោះផ្សាយ
- អក្សរកូដមូលបត្រដែលដាក់ផ្ញើ
- លេខកូដមូលបត្រដែលដាក់ផ្ញើ
- កាលបរិច្ឆេទបោះផ្សាយមូលបត្រដែលដាក់ផ្ញើ
- កាលបរិច្ឆេទចុះបញ្ជីមូលបត្រដែលដាក់ផ្ញើ
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពលើមូលបត្រដែលដាក់ផ្ញើ។

## ៣.៣. និន្នាការទូទៅនៃការបោះផ្សាយ និងការជួញដូរភាគហ៊ុន

### ៣.៣.១. ចំនួនក្រុមហ៊ុនបោះផ្សាយលក់ភាគហ៊ុន

ចាប់តាំងពីឆ្នាំ២០១២រហូតមកដល់ឆ្នាំ២០២២ សង្កេតឃើញថាមានក្រុមហ៊ុនបោះផ្សាយលក់ភាគហ៊ុននៅ ផ.ម.ក. ចំនួន ៩ ក្រុមហ៊ុន ដែលរួមមានដូចខាងក្រោម៖

[68] http://csx.com.kh/operation/depository/listPosts.do?MNCD=3040 (ចូលទស្សនា ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣)

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ - PWSA (ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២)
- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី - GTI (ចុះបញ្ជីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤)
- កំពង់ផែស្វយ័តភ្នំពេញ - PPAP (ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥)
- ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី - PPSP (ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ - PAS (ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧)
- ធនាគារ អេស៊ីលីដា ភីអិលស៊ី - ABC (ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០)
- ក្រុមហ៊ុនផេសថិក (ខេមបូឌា) ម.ក - PEPC (ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០)
- ក្រុមហ៊ុនឌី ប៊ី ឌី អ៊ិនជីនារីង ម.ក - DBDE (ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១)
- ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី - JSL (ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២២)[69]

**ប្រភព៖ គេហទំព័រផ្សារមូលបត្រកម្ពុជា ( ឧបសម្ព័ន្ធទី៦ )**




ក្រាហ្វិចទី ១៖ ចំនួនក្រុមហ៊ុនបោះផ្សាយភាគហ៊ុនពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២២

យោងតាមក្រាបខាងលើ យើងឃើញថាចំនួនក្រុមហ៊ុនចាប់ពីឆ្នាំ២០១២ដល់ឆ្នាំ២០២២៖

- នៅក្នុងឆ្នាំ២០១២៖ មានក្រុមហ៊ុនចំនួន មួយ(០១) បានបោះផ្សាយភាគហ៊ុន
- នៅក្នុងឆ្នាំ២០១៤៖ មានក្រុមហ៊ុនចំនួន មួយ(០១) បានបោះផ្សាយភាគហ៊ុន

[69] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000160007 (ចូលទស្សនា ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២៣)

- នៅក្នុងឆ្នាំ២០១៥៖ មានក្រុមហ៊ុនចំនួន មួយ(០១) បានបោះផ្សាយភាគហ៊ុន
- នៅក្នុងឆ្នាំ២០១៦៖ មានក្រុមហ៊ុនចំនួន មួយ(០១) បានបោះផ្សាយភាគហ៊ុន
- នៅក្នុងឆ្នាំ២០១៧៖ មានក្រុមហ៊ុនចំនួន មួយ(០១) បានបោះផ្សាយភាគហ៊ុន
- នៅក្នុងឆ្នាំ២០២០៖ មានក្រុមហ៊ុនចំនួន ពីរ(០២) បានបោះផ្សាយភាគហ៊ុន
- នៅក្នុងឆ្នាំ២០២១៖ មានក្រុមហ៊ុនចំនួន មួយ(០១) បានបោះផ្សាយភាគហ៊ុន
- នៅក្នុងឆ្នាំ២០២២៖ មានក្រុមហ៊ុនចំនួន មួយ(០១) បានបោះផ្សាយភាគហ៊ុន

### ៣.៣.២. តម្លៃបោះផ្សាយលក់ភាគហ៊ុនជាសាធារណៈលើកដំបូង និងចំនួនភាគហ៊ុនដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈ

ប្រភព៖ គេហទំព័រផ្សារមូលបត្រកម្ពុជា (ឧបសម្ព័ន្ធទី៦)

| និមិត្តសញ្ញាហ៊ុន | តម្លៃបោះផ្សាយលក់ភាគហ៊ុន | ចំនួនហ៊ុនដែលបោះផ្សាយ |
|---|---|---|
| PWSA | ៦.៣០០រៀល | ១៣.០៤៥.៩៧៥ |
| GTI | ៩.៦៤០ រៀល | ៨.០០០.០០០ |
| PPAP | ៥.១២០ រៀល | ៤.១៣៦.៨៧៣ |
| PPSP | ២.៨៦០ រៀល | ១១.៥៧៥.០០០ |
| PAS | ៥.០៤០ រៀល | ២១.៤៤២.៩៩២ |
| ABC | ១៦.២០០ រៀល | ៤.៣៤៤.៨៦៥ |
| PEPC | ៣.១២០ រៀល | ៣.៩៤៥.០០០ |
| DBDE | ២.៣៨០ រៀល | ៦.៤៦១.៥៣៨ |
| JSL | ១.៩០០ រៀល | ៨.២៨១.០០០ |

តារាង ៣.៨ ៖ តម្លៃបោះផ្សាយលក់ភាគហ៊ុន និងចំនួនភាគហ៊ុនដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង




ក្រាហ្វិចទី ២៖ តម្លៃបោះផ្សាយលក់ភាគហ៊ុន និងចំនួនភាគហ៊ុនបោះផ្សាយ

យោងតាមក្រាបខាងលើ យើងឃើញថា៖

- PWSA បានបោះផ្សាយភាគហ៊ុនសរុបចំនួន១៣.០៤៥.៩៧៥ហ៊ុន ក្នុងតម្លៃ ៦.៣០០រៀលក្នុងមួយហ៊ុន
- GTI បានបោះផ្សាយភាគហ៊ុនសរុបចំនួន ៨.០០០.០០០ ហ៊ុន ក្នុងតម្លៃ ៩.៦៤០ រៀលក្នុងមួយហ៊ុន
- PPAP បានបោះផ្សាយភាគហ៊ុនសរុបចំនួន ៤.១៣៦.៨៧៣ ហ៊ុន ក្នុងតម្លៃ ៥.១២០ រៀលក្នុងមួយហ៊ុន
- PPSP បានបោះផ្សាយភាគហ៊ុនសរុបចំនួន ១១.៥៧៥.០០ ហ៊ុន ក្នុងតម្លៃ ២.៨៦០ រៀលក្នុងមួយហ៊ុន
- PAS បានបោះផ្សាយភាគហ៊ុនសរុបចំនួន ២១.៤៤២.៩៩២ ហ៊ុន ក្នុងតម្លៃ ៥.០៤០ រៀលក្នុងមួយហ៊ុន
- ABC បានបោះផ្សាយភាគហ៊ុនសរុបចំនួន ៤.៣៤៤.៨៦៥ ហ៊ុន ក្នុងតម្លៃ ១៦.២០០ រៀលក្នុងមួយហ៊ុន
- PEPC បានបោះផ្សាយភាគហ៊ុនសរុបចំនួន ៣.៩៤៥.០០០ ហ៊ុន ក្នុងតម្លៃ ៣.១២០ រៀលក្នុងមួយហ៊ុន
- DBDE បានបោះផ្សាយភាគហ៊ុនសរុបចំនួន ៦.៤៦១.៥៣៨ ហ៊ុន ក្នុងតម្លៃ ២.៣៨០ រៀលក្នុងមួយហ៊ុន
- JSL បានបោះផ្សាយភាគហ៊ុនសរុបចំនួន ៨.២៨១.០០០ ហ៊ុន ក្នុងតម្លៃ ១.៩០០ រៀលក្នុងមួយហ៊ុន

### ៣.៣.៣. ចំនួនភាគហ៊ុនចុះបញ្ជីសរុប និងមូលធនូបនីយកម្មទីផ្សារ

**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១-៤ ឆ្នាំ២០២២ ( ឧបសម្ព័ន្ធទី៦ )**




ក្រាហ្វិចទី៣ ៖ ចំនួនភាគហ៊ុនចុះបញ្ជីសរុប និងមូលធនូបនីយកម្មទីផ្សារ (លានដុល្លារ)

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ ចំនួនភាគហ៊ុនចុះបញ្ជីសរុបមានចំនួន ៨៤៥,៥៨ លានភាគហ៊ុន ចំណែកឯមូលធនូបនីយកម្មទីផ្សារមានចំនួន ២.១៣៥,០៦ លានដុល្លារអាមេរិក
- នៅត្រីមាសទី២៖ ចំនួនភាគហ៊ុនចុះបញ្ជីសរុបមានចំនួន ៨៤៥,៥៨ លានភាគហ៊ុន ចំណែកឯមូលធនូបនីយកម្មទីផ្សារមានចំនួន ១.៨៦៣,៨៣ លានដុល្លារអាមេរិក
- នៅត្រីមាសទី៣៖ ចំនួនភាគហ៊ុនចុះបញ្ជីសរុបមានចំនួន ៨៤៥,៥៨ លានភាគហ៊ុន ចំណែកឯមូលធនូបនីយកម្មទីផ្សារមានចំនួន ១.៧៤៦,២៣ លានដុល្លារអាមេរិក
- នៅត្រីមាសទី៤៖ ចំនួនភាគហ៊ុនចុះបញ្ជីសរុបមានចំនួន ៨៤៥,៥៨ លានភាគហ៊ុន ចំណែកឯមូលធនូបនីយកម្មទីផ្សារមានចំនួន ១.៨១៦,៦៧ លានដុល្លារអាមេរិក

### ៣.៣.៤. ទិន្នន័យសំខាន់ៗទាក់ទងការជួញដូរភាគហ៊ុន

ទិន្នន័យសំខាន់ៗនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានដកស្រង់មកតាមត្រីមាសនីមួយៗ ក្នុងឆ្នាំ ២០២២។ ទិន្នន័យទាំងនោះរួមមាន៖

- បរិមាណបញ្ជាទិញ- លក់

- ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ
- ការជួញដូរតាមប្រភេទវិនិយោគិន (ក្នុងស្រុក និងបរទេស)
- ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល)
- ចំនួនវិនិយោគិនមានសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ។

### ៣.៣.៤.១. បរិមាណបញ្ជាទិញ លក់

**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១-៤ ឆ្នាំ២០២២ ( ឧបសម្ព័ន្ធទី៦ )**




ក្រាហ្វិកទី៤៖ បរិមាណបញ្ជាទិញ- លក់

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ បរិមាណបញ្ជាទិញមានចំនួន ២៨,៦៧ លានភាគហ៊ុន ចំណែកបរិមាណបញ្ជាលក់មានចំនួន ៣៥,០៣ លានភាគហ៊ុន
- នៅត្រីមាសទី២៖ បរិមាណបញ្ជាទិញមានចំនួន ៤៤,០១ លានភាគហ៊ុន ចំណែកបរិមាណបញ្ជាលក់មានចំនួន ៤៣,៥១ លានភាគហ៊ុន
- នៅត្រីមាសទី៣៖ បរិមាណបញ្ជាទិញមានចំនួន ២៣,៣០ លានភាគហ៊ុន ចំណែកបរិមាណបញ្ជាលក់មានចំនួន ២២,៧៤ លានភាគហ៊ុន
- នៅត្រីមាសទី៤៖ បរិមាណបញ្ជាទិញមានចំនួន ២២,៧៧ លានភាគហ៊ុន ចំណែកបរិមាណបញ្ជាលក់មានចំនួន ២២,៦៨ លានភាគហ៊ុន

### ៣.៣.៤.២. ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ

**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១-៤ ឆ្នាំ២០២២ ( ឧបសម្ព័ន្ធទី៦ )**




ក្រាហ្វិចទី៥ ៖ ទំហំជួញដូរភាគហ៊ុន និងតម្លៃជួញដូរ(លានដុល្លារអាមេរិក) ឆ្នាំ២០២២

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ១៣,៤០ លានភាគហ៊ុន ដែលមានតម្លៃជួញដូរ ២៧,៦៨ លានដុល្លារសហរដ្ឋអាមេរិច។
- នៅត្រីមាសទី២៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៣០,១៩ លានភាគហ៊ុន ដែលមានតម្លៃជួញដូរ ៧៧,៩៩ លានដុល្លារសហរដ្ឋអាមេរិច។
- នៅត្រីមាសទី៣៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៦.៤៧ លានភាគហ៊ុន ដែលមានតម្លៃជួញដូរ ១៥,៤៩ លានដុល្លារសហរដ្ឋអាមេរិច។
- នៅត្រីមាសទី៤៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៥,៩២ លានភាគហ៊ុន ដែលមានតម្លៃជួញដូរ ១២,៥៦ លានដុល្លារសហរដ្ឋអាមេរិច។

### ៣.៣.៤.៣. ចំនួនវិនិយោគិនសរុបប្រចាំត្រីមាសទី១ ដល់ត្រីមាសទី៤

ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១-៤ ឆ្នាំ២០២២ ( ឧបសម្ព័ន្ធទី៦ )




ក្រាហ្វិចទី៦ ៖ ចំនួនវិនិយោគិនសរុបប្រចាំត្រីមាសទី១ ដល់ត្រីមាសទី៤

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ មានចំនួនវិនិយោគិនសរុបចំនួន ៥.៧៨៦ នាក់
- នៅត្រីមាសទី២៖ មានចំនួនវិនិយោគិនសរុបចំនួន ៧.១៨៧ នាក់
- នៅត្រីមាសទី៣៖ មានចំនួនវិនិយោគិនសរុបចំនួន ៥.៧៥៥ នាក់
- នៅត្រីមាសទី៤៖ មានចំនួនវិនិយោគិនសរុបចំនួន ៥.១៤២ នាក់

### ៣.៣.៤.៤. ការជួញដូរតាមប្រភេទវិនិយោគិន (សញ្ជាតិខ្មែរ និងសញ្ជាតិបរទេស)

**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ លេខ១២ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ ទំព័រទី២១**

**(ឧបសម្ព័ន្ធទី៦)**




ក្រាហ្វិចទី៧ ៖ ការជួញដូរតាមប្រភេទវិនិយោគិន(សញ្ជាតិខ្មែរ និងសញ្ជាតិបរទេស) ឆ្នាំ២០២២

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ វិនិយោគិនដែលមានសញ្ជាតិខ្មែរមានចំនួន ៧៨៩ នាក់ ចំណែកឯវិនិយោគិនដែលមានសញ្ជាតិបរទេសមានចំនួន ៤៤ នាក់
- នៅត្រីមាសទី២៖ វិនិយោគិនដែលមានសញ្ជាតិខ្មែរមានចំនួន ៧០៣ នាក់ ចំណែកឯវិនិយោគិនដែលមានសញ្ជាតិបរទេសមានចំនួន ៣១ នាក់
- នៅត្រីមាសទី៣៖ វិនិយោគិនដែលមានសញ្ជាតិខ្មែរមានចំនួន ៧៣៦ នាក់ ចំណែកឯវិនិយោគិនដែលមានសញ្ជាតិបរទេសមានចំនួន ៧៦ នាក់
- នៅត្រីមាសទី៤៖ វិនិយោគិនដែលមានសញ្ជាតិខ្មែរមានចំនួន ២.៦៦០ នាក់ ចំណែកឯវិនិយោគិនដែលមានសញ្ជាតិបរទេសមានចំនួន ១២២ នាក់

### ៣.៣.៤.៥. ការជួញដូរតាមប្រភេទវិនិយោគិន (រូបវ័ន្តបុគ្គល និងនីតិបុគ្គល)

ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ លេខ១២ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ ទំព័រទី១៧ (ឧបសម្ព័ន្ធទី៦)




ក្រាហ្វិចទី៨ ៖ការជួញដូរតាមប្រភេទវិនិយោគិន (រូបវ័ន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០២២

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ វិនិយោគិនជានីតិបុគ្គលមានចំនួន ៤ ចំណែកឯវិនិយោគិនជារូបវ័ន្តបុគ្គលមានចំនួន ៨៣៨ នាក់
- នៅត្រីមាសទី២៖ វិនិយោគិនជានីតិបុគ្គលមានចំនួន ៣ ចំណែកឯវិនិយោគិនជារូបវ័ន្តបុគ្គលមានចំនួន ៧៣១ នាក់
- នៅត្រីមាសទី៣៖ វិនិយោគិនជានីតិបុគ្គលមានចំនួន ៣ ចំណែកឯវិនិយោគិនជារូបវ័ន្តបុគ្គលមានចំនួន ៨០៩ នាក់
- នៅត្រីមាសទី៤៖ វិនិយោគិនជានីតិបុគ្គលមានចំនួន ១ ចំណែកឯវិនិយោគិនជារូបវ័ន្តបុគ្គលមានចំនួន ២.៧៨១ នាក់

**៣.៣.៤.៦. ការជួញដូរតាមប្រភេទវិនិយោគិន (ភេទស្រី និងភេទប្រុស)**

**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ លេខ១២ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ ទំព័រទី១៩**

**(ឧបសម្ព័ន្ធទី៦)**




ក្រាហ្វិកទី៩ ៖ ការជួញដូរតាមប្រភេទវិនិយោគិន (ភេទប្រុស និងភេទស្រី) ឆ្នាំ២០២២

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ វិនិយោគិនភេទស្រីមានចំនួន ៣៣៦ នាក់ ចំណែកឯវិនិយោគិនភេទប្រុសមានចំនួន ៥០៦ នាក់
- នៅត្រីមាសទី២៖ វិនិយោគិនភេទស្រីមានចំនួន ២៤៦ នាក់ ចំណែកឯវិនិយោគិនភេទប្រុសមានចំនួន ៤៨៨ នាក់
- នៅត្រីមាសទី៣៖ វិនិយោគិនភេទស្រីមានចំនួន ៤៩១ នាក់ ចំណែកឯវិនិយោគិនភេទប្រុសមានចំនួន ៣២១ នាក់
- នៅត្រីមាសទី៤៖ វិនិយោគិនភេទស្រីមានចំនួន ៩២៨ នាក់ ចំណែកឯវិនិយោគិនភេទប្រុសមានចំនួន ១.៨៥៤ នាក់

### ៣.៣.៤.៧. ចំនួននៃការផ្តល់លេខអត្តសញ្ញាណវិនិយោគិនប្រចាំត្រីមាសទាំង៤ ក្នុងឆ្នាំ ២០២២

ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ លេខ១២ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ ទំព័រទី១៩

(ឧបសម្ព័ន្ធទី៦)




ក្រាហ្វិកទី១០ ៖ ចំនួននៃការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ប្រចាំត្រីមាសទាំង៤ ក្នុងឆ្នាំ២០២២

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ២០២២៖

- នៅត្រីមាសទី១៖ ការផ្តល់នូវលេខអត្តសញ្ញាណវិនិយោគិនមានចំនួន ៨៤២ នាក់
- នៅត្រីមាសទី២៖ ការផ្តល់នូវលេខអត្តសញ្ញាណវិនិយោគិនមានចំនួន ៧៣៤ នាក់
- នៅត្រីមាសទី៣៖ ការផ្តល់នូវលេខអត្តសញ្ញាណវិនិយោគិនមានចំនួន ៨១២ នាក់
- នៅត្រីមាសទី៤៖ ការផ្តល់នូវលេខអត្តសញ្ញាណវិនិយោគិនមានចំនួន ២.៧៨២ នាក់

# សេចក្តីសន្និដ្ឋាន
# និង
# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅ ទៅលើប្រធានបទនៃ និក្ខេបបទបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រ ស្តីអំពីការបោះផ្សាយ និងជួញដូរភាគហ៊ុននៅកម្ពុជា រួចមក យើងខ្ញុំទាំងពីរនាក់ ទទួលបាននូវពុទ្ធិយ៉ាងច្រើនទៅលើវិស័យមូលបត្រ ដែលជាវិស័យមួយកំពុងតែទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងនាពេលបច្ចុប្បន្ន។ ដើម្បីធ្វើឲ្យវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា ដំណើរការ និងមានការអភិវឌ្ឍន៍រីកចម្រើន រដ្ឋាភិបាលកម្ពុជាបានបង្កើតនូវនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ដែលជាស្ថាប័នមួយទទួលបន្ទុកគ្រប់ គ្រង និងត្រួតពិនិត្យលើទីផ្សារមូលបត្រ ប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងអ្នកពាក់ព័ន្ធដទៃទៀត។ ម៉្យាងវិញទៀត ន.ម.ក. គឺជាចំណែកនៃការចូលរួមក្នុងការធ្វើឲ្យសេដ្ឋកិច្ចជាតិ និងសង្គមមានភាពរីកចម្រើន តាមរយៈការកៀរគរវិនិយោគិន និងមូលធន ដើម្បីធ្វើការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ ហើយក៏មានតួនាទីក្នុងការធ្វើឲ្យប្រតិបត្តិការនៃការជួញដូរមូលបត្រប្រកបដោយប្រសិទ្ធិភាព និងមានសណ្តាប់ធ្នាប់ផងដែរ។ រីឯផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) គឺជាប្រតិបត្តិករទីផ្សារនៅប្រទេសកម្ពុជា និងតែមួយគត់នាពេលបច្ចុប្បន្ន ដែលតួនាទីចម្បងរបស់ផ.ម.ក. គឺធានានូវតម្លាភាព និងបង្កើតនូវបរិយាកាសជួញដូរមូលបត្រដូចជា ការបង្កើតនូវផលិតផល ក៏ដូចជាការផ្តល់សេវាកម្ម និងការពារផលប្រយោជន៍ជូនដល់វិនិយោគិនជាតិ និងអន្តរជាតិ។

ក្រុមហ៊ុនដែលមានគម្រោងក្នុងការបោះផ្សាយ នូវមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង(IPO) ត្រូវតែត្រៀមលក្ខណៈជាមុនសិនដែលមានដូចជា៖ អភិបាលកិច្ចសាជីវកម្ម សកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបានផ្តល់ជាផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានាបាននិរន្តរ៍ភាពប្រតិបត្តិការធុរកិច្ច របាយការហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ការទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពដែលអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ ន.ម.ក.។ ក្រៅពីការត្រៀមខ្លួនទៅតាមតម្រូវការរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) រួចហើយក្រុមហ៊ុនដែលមានបំណងក្នុងការបោះផ្សាយនូវមូលបត្រកម្មសិទ្ធិ ត្រូវធ្វើការសិក្សាស្វែងយល់បន្ថែមពីដំណើរការ និងយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ក៏ដូចជាការសិក្សាបន្ថែមនូវស្ថានភាពនៃការជួញដូរមូលបត្រ និងប្រវត្តិទីផ្សារកន្លងមក។

ចំណែកឯ វិនិយោគិនដែលមានបំណងចង់ធ្វើការវិនិយោគ ក្នុងទីផ្សារមូលបត្រកម្ពុជាវិញ ជាបឋម គឺត្រូវការលេខអត្តសញ្ញាណវិនិយោគិនដែលវិនិយោគិនគាត់ត្រូវតែធ្វើការស្នើសុំ និងមានភ្ជាប់ឯកសារមួយចំនួនតាមលក្ខខណ្ឌដែល ន.ម.ក. បានតម្រូវ និងរង់ចាំការអនុម័តពី ន.ម.ក. ឬវិនិយោគិន អាចធ្វើការស្នើសុំលេខ

អត្តសញ្ញាណវិនិយោគិន តាមរយៈក្រុមហ៊ុនមូលបត្រដែលអ្នកស្រឡាញ់ និងជឿទុកចិត្ត។ បន្ទាប់មកវិនិយោគិនអាចធ្វើការជួញដូរមូលបត្របានដោយអាចទិញ-លក់មូលបត្រដោយខ្លួនឯង ឬប្រគល់ឲ្យក្រុមហ៊ុនមូលបត្រដែលអ្នកទុកចិត្ត។ ក្រៅពីនេះវិនិយោគិនគ្រប់រូប គួរណាស់តែសិក្សាស្វែងយល់បន្ថែមពីប្រតិបត្តិការទីផ្សារ ពេលវេលាជួញដូរ ឯកតាគម្លាតថ្លៃ ប្រភេទបញ្ជា វិធានផាត់ទាត់ និងទូទាត់ វិធានរក្សាមូលបត្ររបស់ផ.ម.ក. ដើម្បីជួយសម្រួលដល់ការជួញដូរមូលបត្ររបស់លោកអ្នក ក៏ដូចជាជៀសវាងរាល់កំហុសឆ្គងដែលនាំឲ្យមានការរំខានទៅការជួញដូរមូលបត្ររបស់លោកអ្នក។

សរុបសេចក្តីមក ដំណើរការនៅក្នុងវិស័យមូលបត្រ ក៏ដូចជាផ្សារមូលបត្រ គឺពិតជាមានលក្ខណៈស្មុគស្មាញ និងស៊ាំញ៉ាំមិនថាប្រទេសកម្ពុជា ឬប្រទេសដទៃ តែវិស័យមូលបត្រនៅកម្ពុជា កាន់តែមានការអភិវឌ្ឍន៍ និងមានការចាប់អារម្មណ៍ពីវិនិយោគិនគ្រប់ជាន់ថ្នាក់ ដែលជាកត្តាជម្រុញឲ្យវិស័យហិរញ្ញវត្ថុ និងវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការរីកចម្រើន។

## ២. អនុសាសន៍

ក្រោយពីបានសិក្សាស្វែងយល់នូវប្រធានបទខាងលើរួចមក ក្រុមយើងខ្ញុំមានការយល់ឃើញថា វិស័យមូលបត្រដែលពិសេសនោះគឺភាគហ៊ុន ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់មហាជននាពេលបច្ចុប្បន្ន។ មួយវិញទៀត ការជួញដូរភាគហ៊ុន ក៏ទទួលបានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែទន្ទឹមនឹងការរីកចម្រើននេះ ក្រុមយើងខ្ញុំគិតថាការរីកចម្រើន នៅមានកម្រិតនៅឡើយ។ ហេតុដូចនេះយើងខ្ញុំសូមការអនុញ្ញាតិធ្វើការផ្តល់ជាមតិយោបល់ដែលយើងខ្ញុំគិតថាជាចំណុចខ្វះខាតមួយចំនួនមានដូចខាងក្រោម៖

- និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និងផ្សារមូលបត្រកម្ពុជា(ផ.ម.ក.) គួរតែបន្តលើកទឹកចិត្ត បន្តជម្រុញ និងបណ្តុះបណ្តាលបន្ថែមទៅដល់គ្រឹះស្ថានសាធារណៈ និងបណ្តាក្រុមហ៊ុនឯកជនឲ្យចាប់អារម្មណ៍លើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិឲ្យកាន់តែច្រើនជាងនេះ។
- បន្តការផ្សព្វផ្សាយឲ្យបានច្រើន តាមរយៈការចុះផ្សព្វផ្សាយផ្ទាល់ក៏ដូចជាតាមរយៈបណ្តាញសង្គម ដែលមានដូចជា Facebook, Instagram, Twitter ជាដើម ដើម្បីឲ្យមហាជនកាន់តែស្វែងយល់ច្បាស់ពីការជួញដូរភាគហ៊ុននៅក្នុងប្រទេសកម្ពុជា។
- គួរតែបញ្ជ្រៀបនូវចំណេះដឹងអំពីវិស័យមូលបត្រចូលទៅក្នុងប្រព័ន្ធអប់រំ ដើម្បីឲ្យសិស្សានុសិស្សជំនាន់ក្រោយដែលជាទំពាំងស្នងឫស្សីបានជ្រួតជ្រាបពីវិស័យនេះទុកជាទុននាពេលអនាគត។
- និយ័តករមូលបត្រកម្ពុជា(ន.ម.ក.) និងផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) គួរតែបង្កើតនូវកម្មវិធីសិក្ខាសាលាវេទិកានានាជូនដល់មហាជនក៏ដូចជាក្រុមហ៊ុន ដែលមានគម្រោងចង់ប្រឡូកក្នុងវិស័យមួយនេះ ដើម្បីទទួលបានចំណេះដឹងពីវិស័យនេះកាន់តែស៊ីជម្រៅ។

- ផ្សារមូលបត្រកម្ពុជា(ផ.ម.ក.) បានបង្កើតនូវកម្មវិធី (Application) នៅលើទូរស័ព្ទដៃ ដែលជួយសម្រួលដល់វិនិយោគិន អាចធ្វើការជួញដូរមូលបត្របានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ក៏ប៉ុន្តែផ.ម.ក. ត្រូវតែតាមដានយ៉ាងយកចិត្តទុកដាក់ទៅលើការធ្វើកំណែទម្រង់ឲ្យទាន់សម័យកាល (Update) ដើម្បីជៀសវាងនូវភាពរអាក់រអួលផ្សេងៗ៕

# ឯកសារយោង

# ឯកសារយោង

- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ លេខ នស/ រកម/ ០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១
- អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដាក្នុងវិស័យមូលបត្រ លេខ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ចែកុម្ភៈ ឆ្នាំ ២០២២
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ លេខ ០០២/២០គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់ លេខ ០១៨/១៧ គ.ម.ក./ ប្រ.ក. ចុះ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧
- ប្រកាស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ លេខ ០១៩/១៧ គ.ម.ក./ ប្រ.ក. ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តនូវវិធានប្រតិបត្តិការរក្សាទុកមូលបត្រ លេខ ០០៤/២០ គ.ម.ក./ ប្រ.ក ចុះថ្ងៃ ទី១០ ខែកុម្ភៈ ឆ្នាំ២០២០
- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ០០៥/១៥គ.ម.ក/ប្រ.ក ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥
- ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ លេខ ០០៩ គ.ម.ក. ចុះថ្ងៃ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩
- គោលការណ៍ណែនាំលេខ០០១ គ.ម.ក./គ.ណ.ន. ស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ចុះថ្ងៃ ទី០៦ ខែកុម្ភៈ ឆ្នាំ២០១២
- គោលការណ៍ណែនាំលេខ ០០២/២០ គ.ម.ក./គ.ណ.ន. ស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន តាមអនឡាញ ចុះថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ២០២០
- និយ័តករមូលបត្រកម្ពុជា ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១ ត្រីមាសទី២ ត្រីមាស ទី៣ និងត្រីមាសទី៤ ឆ្នាំ២០២២
- គណៈកម្មការមូលបត្រកម្ពុជា ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយលេខ២ ខែមករា ឆ្នាំ២០១៧

- សួន ចំរើន(២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ហេង ច័ន្ទបូលីន (២០២១) ទីផ្សារមូលបត្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ទីផ្សារមូលបត្រ (http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1)
- ប្រវត្តិនៃទីផ្សារមូលបត្រ (https://economy.ams.com.kh/history-of-stock-market/)
- ប្រភេទនៃមូលបត្រ (http://csx.com.kh/kh/product/equities.jsp?MNCD=4020)
- តួនាទីទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ (https://www.serc.gov.kh/khmer/faq.php?pn=2)
- គុណសម្បត្តិនៃទីផ្សារមូលបត្រ (http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1)
- គុណសម្បត្តិនៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ (http://www.csx.com.kh/news/faq/listPosts.do?lang=kh&MNCD=7060&postId=6)
- គុណវិបត្តិនៃទីផ្សារមូលបត្រ (https://khemsaritheducation.wordpress.com/)
- និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) (https://www.serc.gov.kh/khmer/faq.php?pn=2)
- ប្រវត្តិសង្ខេបរបស់និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m10.php?pn=1)
- ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m19.php?pn=1)
- ចក្ខុវិស័យ និងបេសកកម្ម (https://www.serc.gov.kh/khmer/m11.php?pn=1)
- មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា (https://www.serc.gov.kh/khmer/m17.php?pn=1)
- គោលដៅ និងគោលបំណងទូទៅនៃនិយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/faq.php?pn=2)
- រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m14.php?pn=1)
- ថ្នាក់ដឹកនាំបច្ចេកទេសរបស់និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m14.php?pn=1)
- នាយកដ្ឋានរបស់និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m14.php?pn=1)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) (http://csx.com.kh/kh/about/profile.jsp?MNCD=10301)

- ទីតាំងរបស់ផ្សារមូលបត្រកម្ពុជា (http://csx.com.kh/kh/about/contact.jsp?MNCD=10703)
- ក្រុមប្រឹក្សាភិបាល (http://csx.com.kh/kh/about/director.jsp?MNCD=10303)
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA) (http://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=84)
- កំពង់ផែស្វយ័តភ្នំពេញ (PPAP) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000040001)
- ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធើណេសិនណល (ខេមបូឌា) ភី អិលស៊ី (GTI) (http://csx.com.kh/data/lstcom/listPosts.do?MNCD=50101)
- ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000050000)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PASP) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000060009)
- ធនាគារអេស៊ីលីដា ភីអិលស៊ី (ABC) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000100003)
- ក្រុមហ៊ុន ផេកចិក (ខេមបូឌា) ម.ក. (PEPC) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000140009)
- ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក. (DBD) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000150008)
- ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី (JSL) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000160007)

- តួអង្គចូលរួមដទៃទៀត (https://www.serc.gov.kh/khmer/m59.php?pn=6)
- ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង (http://csx.com.kh/kh/product/mainboard.jsp?MNCD=30102)
- លក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅ ទីផ្សារមូលបត្រ (http://csx.com.kh/kh/product/mainboard.jsp?MNCD=30102)
- ការបើកគណនីជួញដូរមូលបត្រ គណនីសាច់ប្រាក់ និងគណនីមូលបត្រ (https://www.serc.gov.kh/khmer/m45.php?pn=5)
- ប្រតិបត្តិការទីផ្សារ (http://csx.com.kh/operation/market/listPosts.do?MNCD=30201)
- ប្រភេទបញ្ជា (http://csx.com.kh/operation/market/listPosts.do?MNCD=30201)
- ការដាក់បញ្ជាទិញ និងលក់ (http://csx.com.kh/operation/stock/listPosts.do?MNCD=30202)
- ឯកតាបញ្ជា និង ឯកតាគម្លាតថ្លៃ (http://csx.com.kh/operation/stock/listPosts.do?MNCD=30202)
- ថ្លៃមូលដ្ឋាន (http://csx.com.kh/operation/stock/listPosts.do?MNCD=30202)
- ថ្លៃពិសេស (http://csx.com.kh/operation/stock/listPosts.do?MNCD=30202)
- វិធីសាស្រ្តជួញដូរភាគហ៊ុន (http://csx.com.kh/operation/market/listPosts.do?MNCD=30201)
- ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ (http://csx.com.kh/operation/market/listPosts.do?MNCD=30201)
- ប្រតិបត្តិការជាត់ទាត់ និងទូទាត់ (http://csx.com.kh/operation/clearing/listPosts.do?MNCD=3030)
- ដំណើរការនៃប្រព័ន្ធជាត់ទាត់ និងទូទាត់សាច់ប្រាក់ (http://csx.com.kh/operation/depository/listPosts.do?MNCD=3040)
- ទិដ្ឋភាពទូទៅនៃការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH 1000160007)

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ

ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ

ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តការកែប្រែវិធានប្រតិបត្តិការទីផ្សារ

ឧបសម្ព័ន្ធទី៤៖ ប្រកាសស្តីពីការអនុវត្តវិធានការប្រតិបត្តិការរក្សាទុកមូលបត្រ

ឧបសម្ព័ន្ធទី៥៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ

ឧបសម្ព័ន្ធទី៦៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគប្រចាំត្រីមាស១ដល់៤ ឆ្នាំ២០២២

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០០៧/២០ គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៧ ថ្មី នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៧ នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃច័ន្ទ ៣ កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច លោកជំទាវ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ..០០៧/២០..ស/ប្រក.

ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០

ស្តីពី

ការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ

របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

**ប្រការ១៧ ថ្មី.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ**

ដែនកំណត់ថ្លៃប្រចាំថ្ងៃ សម្រាប់មូលបត្រកម្មសិទ្ធិ ត្រូវស្មើនឹងថ្លៃមូលដ្ឋាន ±១០% (បូកឬដកដប់ភាគរយ) ដោយតម្លៃ១០% នៃថ្លៃមូលដ្ឋានត្រូវបង្គត់ចុះតាមឯកតាគម្លាតថ្លៃមុននឹងយកទៅបូកឬដកនឹងថ្លៃមូលដ្ឋាន។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ១០០ (មួយរយ) រៀល ដែនកំណត់ថ្លៃប្រចាំថ្ងៃគឺស្មើនឹង ១០ (ដប់) រៀល។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណត់ទេចំពោះមូលបត្រកម្មសិទ្ធិដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ (Delisting) ហើយត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងអំឡុងពេលមួយកំណត់ នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើ បន្ទាប់ពីមានការឯកភាពពីអគ្គនាយកនៃ គ.ម.ក. ផ.ម.ក. អាចកំណត់យកដែនកំណត់ថ្លៃប្រចាំថ្ងៃផ្សេងពីនេះក្នុងករណីដូចខាងក្រោម÷

១- ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ។

២- ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមជួញដូរឡើងវិញ បន្ទាប់ពីត្រូវបានព្យួរអស់មួយរយៈពេលវែង។

៣- ករណីផ្សេងទៀតមានការលំបាកខ្លាំងក្នុងការអនុវត្តដែនកំណត់ថ្លៃប្រចាំថ្ងៃ។

* * *

ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ ០៩៤/១៧......គ.ម.ក./ប្រ.ក.

**ប្រកាស**
**ស្តីពី**
**ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ**

*****

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
- យោងសំណើសុំវិសោធនកម្មប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

**សម្រេច**

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ និងប្រការ ២ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
"ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០១៤/១៧.........
ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧

ស្តីពី

# វិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

គោលបំណងនៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រនេះ គឺដើម្បីកំណត់នូវគោលការណ៍នានាដែលចាំបាច់សម្រាប់ការផាត់ទាត់និងទូទាត់មូលបត្រ នៅក្នុងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ច្បាប់ស្តីពីមូលបត្ររដ្ឋ និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ បុគ្គលបោះផ្សាយលក់មូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

-**ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** សំដៅដល់ធនាគារពាណិជ្ជដែលបានការទទួលស្គាល់ពី **គ.ម.ក.** ដូចមានចែងក្នុងប្រកាសស្តីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

### ប្រការ៣.- ប្រតិបត្តិការផាត់ទាត់និងទូទាត់

ការជួញដូរមូលបត្រចុះបញ្ជី ត្រូវតែប្រតិបត្តិតាមការទូទាត់ធម្មតា។ ការទូទាត់ធម្មតា គឺជាការទូទាត់ដែលត្រូវធ្វើឡើងពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+2)។

## ជំពូកទី២

## ការទូទាត់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសមាជិក ឬអ្នកចូលរួម

### ប្រការ ៤.- ភារកិច្ចទូទាត់របស់សមាជិក ឬអ្នកចូលរួម

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវធ្វើការទូទាត់លើប្រតិបត្តិការដែលបានជួញដូរឱ្យបាននៅកាលបរិច្ឆេទទូទាត់។

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. មិនអាចប្រគល់ភារកិច្ចទូទាត់ប្រតិបត្តិការរបស់ខ្លួនទៅឱ្យសមាជិក ឬអ្នកចូលរួមដទៃទៀតឡើយ។

### ប្រការ ៥.- កាលបរិច្ឆេទផាត់ទាត់និងទូទាត់របស់សមាជិក ឬអ្នកចូលរួម

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ គ.ម.ក. ការទូទាត់ត្រូវធ្វើឡើងពីរថ្ងៃនៃថ្ងៃជួញដូរបន្ទាប់ពីថ្ងៃដែលមូលបត្រនោះត្រូវបានជួញដូរ (T+2)។ ថ្ងៃបិទទីផ្សារមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនថ្ងៃអាជីវកម្មទេ។

### ប្រការ ៦.- ការជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

សមាជិក ឬអ្នកចូលរួមត្រូវជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. សម្រាប់បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

### ប្រការ ៧.- ការបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវបើកគណនីសាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចមានចែងក្នុងប្រការ ៦ នៃវិធាននេះ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិក ឬអ្នកចូលរួមត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនី ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. យ៉ាងហោចណាស់ ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមការជួញដូរ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក.។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិក ឬអ្នកចូលរួមដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

**ប្រការ ៨.-ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវបើកគណនីមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ នៃប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវបើកគណនីទូទាត់មូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ការទូទាត់មូលបត្រត្រូវធ្វើឡើង តាមរយៈការផ្ទេរក្នុងបញ្ជី (Book-EntryTransfer) ពីគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក.។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលបានការទូទាត់មូលបត្រ។

**ប្រការ ៩.-ការតម្កល់ធានាការជួញដូរ**

មុនអនុវត្តបញ្ជាសម្រាប់គណនីអតិថិជន ឬសម្រាប់គណនីផ្ទាល់ខ្លួន សមាជិកត្រូវពិនិត្យការតម្កល់ធានាការជួញដូរមូលបត្រឱ្យបានត្រឹមត្រូវ ដូចតទៅ÷

១-សម្រាប់បញ្ជាទិញមូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាសាច់ប្រាក់។ ចំពោះបញ្ជាទិញមូលបត្រកម្មសិទ្ធិ សាច់ប្រាក់តម្កល់ធានាការជួញដូរនេះ អាចគិតបញ្ចូលផងដែរនូវសាច់ប្រាក់ត្រូវទទួលបានពីបញ្ជាលក់ដែលបានផ្គូផ្គងដោយជោគជ័យ។

២-សម្រាប់បញ្ជាលក់មូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាមូលបត្រដែលត្រូវដាក់លក់នោះ។ ចំពោះបញ្ជាលក់មូលបត្រកម្មសិទ្ធិ មូលបត្រតម្កល់ធានាការជួញដូរអាចគិតបញ្ចូលផងដែរនូវមូលបត្រដូចគ្នាត្រូវទទួលបានពីបញ្ជាទិញដែលបានផ្គូផ្គងដោយជោគជ័យ។

សមាជិកត្រូវធានាឱ្យបានថា ការតម្កល់ធានាការជួញដូរត្រូវបានរក្សាទុក ឬបង្កកសម្រាប់ការទូទាត់ ឬរហូតដល់បញ្ជានោះអស់សុពលភាព។

**ប្រការ ១០.-នីតិវិធីនៃប្រតិបត្តិការផាត់ទាត់និងទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ឬអ្នកចូលរួម ដោយធ្វើការបន្សុទ្ធ ឬកាត់កង (Netting) ចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នា របស់សមាជិក ឬអ្នកចូលរួម នីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវជូនដំណឹងអំពីព័ត៌មានដូចខាងក្រោមដល់សមាជិក ឬអ្នកចូលរួម នៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់៖

១-កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២-បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬអ្នកចូលរួម ឬក្នុងនាមអតិថិជន។

៣-ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិក ឬអ្នកចូលរួមផ្ទាល់ ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗដូចខាងក្រោម៖

១-ចំពោះមូលបត្រ៖ ត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិក ឬអ្នកចូលរួម ដែលពាក់ព័ន្ធ។

២-ចំពោះសាច់ប្រាក់៖ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុប សម្រាប់សមាជិក ឬអ្នកចូលរួម នីមួយៗដែលពាក់ព័ន្ធ។

សមាជិក ឬអ្នកចូលរួម ត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. នៅមុនម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់ (Settlement Date) ហើយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវធ្វើការទូទាត់មូលបត្រនិងសាច់ប្រាក់បន្តទៅឱ្យសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ ព្រឹក នៅថ្ងៃដដែលនៅកាលបរិច្ឆេទទូទាត់។

**ប្រការ ១១.-ការប្រគល់ឯកសារទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវផ្តល់នូវឯកសារបង្កាប់ទូទាត់ ដែលរួមមានព័ត៌មានលម្អិតលើមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ជូនដល់សមាជិក ឬអ្នកចូលរួម ក្រោយការបិទទីផ្សារ តាមរយៈប្រព័ន្ធកុំព្យូទ័រ។

សមាជិក ឬអ្នកចូលរួម ត្រូវពិនិត្យអំពីមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ នៅលើឯកសារបង្កាប់ទូទាត់ និងត្រូវធ្វើការទូទាត់ទៅតាមពេលវេលាកំណត់។

សមាជិក ឬអ្នកចូលរួម ត្រូវប្រគល់ឯកសារទូទាត់ ដែលមានព័ត៌មានលម្អិត និងពេលវេលានៃការទូទាត់ជាដើម ជូនដល់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ក្រោយពីការទូទាត់។

**ប្រការ ១២.-វិធានការវិន័យចំពោះការបរាជ័យនៃការទូទាត់**

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមណាមួយគ្មានលទ្ធភាពធ្វើការទូទាត់ការជួញដូររបស់ខ្លួន ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចលុបចោលនូវការជួញដូរដែលបានប្រតិបត្តិហើយទាំងស្រុង ឬមួយផ្នែកនៅក្នុងប្រតិបត្តិករទីផ្សារនៃ ផ.ម.ក. ឬ/និងព្យួរការជួញដូររបស់សមាជិក ឬអ្នកចូលរួមនោះក្នុងរយៈពេលកំណត់មួយ។

ក្នុងករណីដែលមានកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីធានាការទូទាត់ លើកលែងតែមានការកំណត់ផ្សេងទៀត។

ក្នុងករណីដែលមានកង្វះខាតមូលបត្រសម្រាប់ទូទាត់ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវធ្វើការទូទាត់ ដោយសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពីសមាជិក ឬអ្នកចូលរួមផ្សេងទៀត។ ប្រសិនបើការសុំខ្ចី និងការឱ្យខ្ចីមិនអាចធ្វើទៅបាន ការទូទាត់នឹងត្រូវលុបចោល។

ប្រសិនបើ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. មិនអាចរកមធ្យោបាយដើម្បីធ្វើការទូទាត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. អាចចាត់វិធានការ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ១៣.- អ្នកតំណាងទូទាត់**

សមាជិក ឬអ្នកចូលរួមនីមួយៗ ត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងទូទាត់យ៉ាងហោចណាស់ ១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពីប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. និងដែលមានសិទ្ធិធ្វើប្រតិបត្តិការទូទាត់ឱ្យសមាជិក ឬអ្នកចូលរួមនោះ ជាមួយប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក.។

អ្នកតំណាងទូទាត់របស់សមាជិកនោះ អាចជាអ្នកតំណាងទីផ្សារដែលត្រូវបានតែងតាំងដោយសមាជិកស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ ផ.ម.ក.។

## ជំពូកទី ៣
## ថ្លៃសេវាជាត់ទាត់និងទូទាត់

**ប្រការ ១៤.-ថ្លៃសេវាជាត់ទាត់និងទូទាត់មូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាជាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ប្រាក់សេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ២,៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ និង ១,២៥/១០.០០០ (មួយក្បៀសម្ភៃប្រាំភាគមួយម៉ឺន) ឬ ០,០១២៥% (សូន្យក្បៀសសូន្យមួយរយម្ភៃប្រាំភាគរយ) ចំពោះមូលបត្របំណុល។

២-អ្នកបង់ថ្លៃសេវា គឺសមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក.។

៣-ពេលវេលានៃការបង់ថ្លៃសេវា គឺនៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

* * *



ឧបសម្ព័ន្ធទី៣

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ...០០៣.../...១៩....គ.ម.ក./ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩។

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៤ ថ្មី និងប្រការ១៨ ថ្មី នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៤ និងប្រការ១៨ នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០២... ខែ..[illegible].. ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ០០៣.១៩/គ.ម.ក.
ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០១៩

## ស្តីពី

## ការកែប្រែវិធានប្រតិបត្តិការផ្សារមូលបត្រ
## របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ប្រការ១៤ ថ្មី.- ថ្ងៃ និងម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការងារ។

ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៨:០០នាទី ព្រឹក រហូតដល់ម៉ោង ១៥:០០នាទី រសៀល ដែលបែងចែកជាបីវគ្គដោយឈរលើមូលដ្ឋាននៃវិធីសាស្រ្តនៃការដេញថ្លៃ ដូចខាងក្រោម÷

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងអនុវត្តការជួញដូរ | វិធីសាស្រ្ត |
|---|---|---|---|
| វគ្គបើក | ៨:០០ ព្រឹក - ៩:០០ ព្រឹក | ៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ ព្រឹក - ១៤:៥០ រសៀល | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១៤:៥០ រសៀល - ១៥:០០ រសៀល | ១៥:០០ រសៀល | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនមិនមានការផ្គូផ្គងបញ្ជានៅម៉ោង ៩:០០នាទី ព្រឹក វគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

ចំពោះវិធីសាស្រ្តជួញដូរតាមការចរចា÷ ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៩:០០នាទី ព្រឹក ដល់ម៉ោង ១៥:០០នាទី រសៀល។

### ប្រការ១៨ ថ្មី.- ការកែតម្រូវលើកំហុសប្រតិបត្តិការជួញដូរ

ក្នុងករណីដែល **ផ.ម.ក.** មានកំហុសឆ្គងក្នុងដំណើរការធ្វើអន្តរការីកម្មនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬក្នុងករណីដែលសមាជិកណាមួយមានកំហុសឆ្គងក្នុងដំណើរការដាក់បញ្ជាដែនកំណត់ ឬបញ្ជាទីផ្សារពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ ព័ត៌មានលម្អិតអំពីការជួញដូរនេះអាចកែតម្រូវបាន។

កំហុសប្រតិបត្តិការត្រូវបានចាត់ថ្នាក់ជា÷ កំហុសរបស់ **ផ.ម.ក.** ឬកំហុសរបស់សមាជិក។

**ផ.ម.ក.** ត្រូវកែតម្រូវលើកំហុសប្រតិបត្តិការតាមវិធីសាស្ត្រដូចខាងក្រោម÷

១-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់ **ផ.ម.ក.**÷ ក្នុងករណីនេះ **ផ.ម.ក.** ត្រូវកែតម្រូវដោយយោងតាមព័ត៌មានដើមនៃបញ្ជា ហើយតម្រូវឱ្យសមាជិកដែលបានបញ្ជូនបញ្ជានោះទទួលយកការជួញដូរមូលបត្រដែលពាក់ព័ន្ធសម្រាប់គណនីផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមានការខាតបង់បណ្តាលមកពីការកែតម្រូវនេះ **ផ.ម.ក.** ត្រូវធ្វើការប៉ះប៉ូវឱ្យសមាជិកនោះវិញ។

២-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់សមាជិក÷ កំហុសឆ្គងត្រូវកែតម្រូវ បន្ទាប់ពីសមាជិកនោះទទួលយកការជួញដូរដែលមានកំហុសជាប្រតិបត្តិការផ្ទាល់របស់ខ្លួន។ ក្នុងករណីនេះ សមាជិកដែលពាក់ព័ន្ធត្រូវដាក់ពាក្យស្នើសុំកែតម្រូវលើកំហុសប្រតិបត្តិការ និងភ្ជាប់មកជាមួយនូវសេចក្តីថ្លែងដែលបញ្ជាក់ពីមូលហេតុ ឬឯកសារភស្តុតាង ផ្ញើជូន **ផ.ម.ក.** ឱ្យបានមុនម៉ោង ១៥:៣០នាទីរសៀលនៃថ្ងៃជួញដូរបន្ទាប់។

* * *

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ: ០០៣៧/១៧......គ.ម.ក. /ប្រ.ក.

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំវិសោធនកម្មប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

**សម្រេច**

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ, ប្រកាសលេខ ០០១/១៣ គ.ម.ក.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រកាសលេខ ០០៥/១៤ គ.ម.ក.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងប្រការ១ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៨ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០១៥/១៧......គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្ដីពី
## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹតលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០២/១១ គ.ម.ក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- យោងតាមសំណើសុំវិសោធនកម្មប្រកាសលេខ ០០២/១១ គ.ម.ក. ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០២/១១ គ.ម.ក./ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ និងប្រការ៣ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារ

មូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ [illegible] ខែ[illegible] ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣

"ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.....០០៤/៦០.....គ.ម.ក. ១៥-៥.

## ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
## របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
### និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០១៩/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- យោងតាមសំណើសុំអនុម័តលើការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៣ ថ្មី នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៣ នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៩/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្ដេច លោកជំទាវ ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- ដូចប្រការ ២

"ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករមូលបត្រកម្ពុជា

# ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ

## INVESTORS AND INVESTING BULLETIN










ប្រចាំត្រីមាសទី១ ឆ្នាំ២០២២

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

ចេញផ្សាយលេខទី៩

# ផ្នែកទី២. ទិន្នន័យទីផ្សារមូលបត្រ

## ២.១. និន្នាការទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ

| និន្នាការទូទៅនៃទីផ្សារ | ត្រីមាសទី១ ២០២២ | ត្រីមាសទី៤ ២០២១ | បម្រែបម្រួលត្រី.១ ២០២២ ធៀបនឹង | |
|---|---|---|---|---|
| | | | ត្រី.៤ ២០២១ | ត្រី.១ ២០២១ |
| ថ្ងៃជួញដូរ | 62 | 58 | 6.90% | 1.64% |
| ចំនួនភាគហ៊ុនចុះបញ្ជីសរុប (លានភាគហ៊ុន) | 845.58 | 819.87 | 3.14% | 3.95% |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 8,647,005 | 7,194,730 | 20.19% | -10.83% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 2,135.06 | 1,766.01 | | |
| បរិមាណបញ្ជាទិញ (លានភាគហ៊ុន) | 28.67 | 42.08 | -31.85% | 39.54% |
| បរិមាណបញ្ជាលក់ (លានភាគហ៊ុន) | 35.03 | 48.13 | -27.22% | 93.68% |
| ទំហំជួញដូរ (លានភាគហ៊ុន) | 13.40 | 36.22 | -62.99% | 142.17% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 216,162 | 624,424 | -65.38% | 138.26% |
| តម្លៃជួញដូរ (លានរៀល) | 112,098.90 | 97,936.73 | 14.46% | 221.79% |
| តម្លៃជួញដូរ (លានដុល្លារអាមេរិក) | 27.68 | 24.04 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 1808.05 | 1688.56 | 7.08% | 216.60% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 446,431 | 414,473 | | |
| ចំនួនវិនិយោគិន (នាក់) | 5,786 | 4,538 | 27.50% | 195.20% |

*តារាង 1 និន្នាការទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិក្នុងត្រីមាសទី១ ឆ្នាំ២០២២*

នៅចុងត្រីមាសទី១ ឆ្នាំ២០២២ ទំហំមូលធនូបនីយកម្មទីផ្សារសរុបនៃទីផ្សារមូលបត្រកម្មសិទ្ធិមានតម្លៃប្រហែល ៨,៦៥ ទ្រីលានរៀល(ប្រហែល ២,១៤ ប៊ីលានដុល្លារអាមេរិក) និងទំហំជួញដូរភាគហ៊ុនសរុប មានចំនួន ១៣.៤០២.០៦០ ភាគហ៊ុន ដែលទំហំជួញដូរនៅក្នុងទីផ្សារគោលមានប្រហែល៨២% និងទីផ្សារកំណើនមានចំនួនប្រហែល ១២% នៃទំហំជួញដូរសរុប។ ដោយឡែក ចំពោះទីផ្សារមូលបត្របំណុល ពុំមានការជួញដូរលើសញ្ញាបណ្ណសាជីវកម្មណាមួយឡើយ។

គួរបញ្ជាក់ផងដែរថា កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ មានការចុះបញ្ជីថ្មីបន្ថែមមួយក្រុមហ៊ុនទៀត (ក្រុមហ៊ុនទី២) នៅក្នុងទីផ្សារកំណើន គឺក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ដែលមាននិមិត្តសញ្ញាសម្គាល់ថា “JSL” ដែលមានថ្លៃ IPO ១.៩០០ រៀល ហើយថ្លៃជួញដូរលើកដំបូង គឺ ២.២២០ រៀល និងបិទទីផ្សារ នៅថ្លៃ ២.៤៤០ រៀល។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករមូលបត្រកម្ពុជា

# ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ

## INVESTORS AND INVESTING BULLETIN



ប្រចាំត្រីមាសទី២ ឆ្នាំ២០២២

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

ចេញផ្សាយលេខទី ១០

# ផ្នែកទី២. ទិន្នន័យទីផ្សារមូលបត្រ

## ២.១. និន្នាការទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ

| និន្នាការទូទៅនៃទីផ្សារ | ត្រីមាសទី២ ២០២២ | ត្រីមាសទី១ ២០២២ | បម្រែបម្រួលត្រី.១ ២០២២ ធៀបនឹង | |
|---|---|---|---|---|
| | | | ត្រី.១ ២០២២ | ត្រី.២ ២០២១ |
| ថ្ងៃជួញដូរ | 61 | 62 | -1.61% | 5.17% |
| ចំនួនភាគហ៊ុនចុះបញ្ជីសរុប (លានភាគហ៊ុន) | 845.58 | 845.58 | 0.00% | 3.95% |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 7,585,799.00 | 8,647,005.00 | -12.27% | -9.75% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 1,863.83 | 2,135.06 | | |
| បរិមាណបញ្ជាទិញ (លានភាគហ៊ុន) | 44.01 | 28.67 | 53.48% | 144.33% |
| បរិមាណបញ្ជាលក់ (លានភាគហ៊ុន) | 43.51 | 35.03 | 24.21% | 120.47% |
| ទំហំជួញដូរ (លានភាគហ៊ុន) | 30.19 | 13.40 | 125.30% | 292.65% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 494,988 | 216,162 | 128.99% | 273.34% |
| តម្លៃជួញដូរ (លានរៀល) | 317,431.57 | 112,098.90 | 183.17% | 421.16% |
| តម្លៃជួញដូរ (លានដុល្លារអាមេរិក) | 77.99 | 27.68 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 5,203.80 | 1,808.05 | 187.81% | 395.53% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 1,278,574.02 | 446,431.29 | | |
| ចំនួនវិនិយោគិន (នាក់) | 7,187 | 5,786 | 24.21% | 40.45% |

*តារាង 1 និន្នាការទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិក្នុងត្រីមាសទី២ ឆ្នាំ២០២២*

នាពេលបច្ចុប្បន្នក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផមក**) មានផលិតផលចំនួនពីរប្រភេទ គឺមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) និងមូលបត្របំណុលដែលកំពុងត្រូវបានជួញដូរនៅលើទីផ្សារ។ ចំពោះទីផ្សារមូលបត្រកម្មសិទ្ធិ មានក្រុមហ៊ុនចុះបញ្ជីសរុបចំនួន ៩ ក្រុមហ៊ុន ដែលនៅក្នុងនោះមានក្រុមហ៊ុនចំនួន ៧ បានចុះបញ្ជីនៅទីផ្សារគោល និងក្រុមហ៊ុនចំនួន ២ បានចុះបញ្ជីនៅទីផ្សារកំណើន។ រីឯទីផ្សារមូលបត្របំណុលមានក្រុមហ៊ុនចំនួន ៧ បានបោះផ្សាយលក់មូលបត្របំណុល (ក្នុងនោះមូលបត្របំណុលដែលកំពុងចុះបញ្ជីមានចំនួន ៦ ហើយមានមូលបត្របំណុលចំនួន ៣ បានដល់ឥណប្រតិទាន)។

នៅចុងត្រីមាសទី២ ឆ្នាំ២០២២ ទំហំមូលធនូបនីយកម្មទីផ្សារសរុបនៃទីផ្សារមូលបត្រកម្មសិទ្ធិមានតម្លៃប្រហែល ៧,៥៩ ទ្រីលានរៀល(ប្រហែល ១,៨៦ ប៊ីលានដុល្លារអាមេរិក) និងទំហំជួញដូរភាគហ៊ុនសរុប មានចំនួន ៣០.១៩៤.២៥១ ភាគហ៊ុន ដែលទំហំជួញដូរនៅក្នុងទីផ្សារគោលមានប្រហែល ៩៦,១១% និងទីផ្សារកំណើនមានចំនួនប្រហែល ៣,៨៩% នៃទំហំជួញដូរសរុប។ ដោយឡែក ចំពោះទីផ្សារមូលបត្របំណុល ពុំមានការជួញដូរលើសញ្ញាបណ្ណសាជីវកម្មណាមួយទេ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករមូលបត្រកម្ពុជា

# ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ

# INVESTORS AND INVESTING BULLETIN




ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

ចេញផ្សាយលេខទី ១១

# ផ្នែកទី២. ទិន្នន័យទីផ្សារមូលបត្រ

## ២.១. និដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ

| និដ្ឋភាពទូទៅនៃទីផ្សារ | ត្រីមាសទី៣ ២០២២ | ត្រីមាសទី២ ២០២២ | បម្រែបម្រួលត្រី.៣ ២០២២ ធៀបនឹង | |
|---|---|---|---|---|
| | | | ត្រី.២ ២០២២ | ត្រី.៣ ២០២១ |
| ថ្ងៃជួញដូរ | 65 | 61 | 6.56% | 0.00% |
| ចំនួនភាគហ៊ុនចុះបញ្ជីសរុប (លានភាគហ៊ុន) | 845.58 | 845.58 | 0.00% | 3.14% |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 7,192,736.00 | 7,585,799.00 | -5.18% | -3.43% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 1,746.23 | 1,863.83 | | |
| បរិមាណបញ្ជាទិញ (លានភាគហ៊ុន) | 23.30 | 44.01 | -47.06% | 29.90% |
| បរិមាណបញ្ជាលក់ (លានភាគហ៊ុន) | 22.74 | 43.51 | -47.74% | -4.94% |
| ទំហំជួញដូរ (លានភាគហ៊ុន) | 6.47 | 30.19 | -78.59% | -11.90% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 99,478 | 494,988 | -79.90% | -11.90% |
| តម្លៃជួញដូរ (លានរៀល) | 63,819.67 | 317,431.57 | -79.89% | -4.57% |
| តម្លៃជួញដូរ (លានដុល្លារអាមេរិក) | 15.49 | 77.99 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 981.84 | 5,203.80 | -81.13% | -4.57% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 238,368.81 | 1,278,574.02 | | |
| ចំនួនវិនិយោគិន (នាក់) | 5,755 | 7,187 | -19.92% | -6.36% |

*តារាង 1 ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិក្នុងត្រីមាសទី៣ ឆ្នាំ២០២២*

នាពេលបច្ចុប្បន្ន ផ្សារមូលបត្រកម្ពុជា (**ផមក**) មានផលិតផលចំនួនពីរប្រភេទ គឺមូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) និងមូលបត្របំណុល (សញ្ញាបណ្ណ) ដែលកំពុងត្រូវបានជួញដូរនៅលើទីផ្សារ។ ចំពោះទីផ្សារមូលបត្រកម្មសិទ្ធិមានក្រុមហ៊ុនចុះបញ្ជីសរុបចំនួន ៩ ក្រុមហ៊ុន ដែលនៅក្នុងនោះមានក្រុមហ៊ុនចំនួន ៧ បានចុះបញ្ជីនៅទីផ្សារគោល និងក្រុមហ៊ុនចំនួន ២ បានចុះបញ្ជីនៅទីផ្សារកំណើន។ រីឯទីផ្សារមូលបត្របំណុលមានក្រុមហ៊ុនចំនួន ៧ បានបោះផ្សាយលក់មូលបត្របំណុល (មូលបត្របំណុលដែលកំពុងចុះបញ្ជីមានចំនួន ៥ ហើយមានមូលបត្របំណុលចំនួន ៤ បានដល់ឥណប្រតិទាន)។

នៅចុងត្រីមាសទី៣ ឆ្នាំ២០២២ ទំហំមូលធនូបនីយកម្មទីផ្សារសរុបនៃទីផ្សារមូលបត្រកម្មសិទ្ធិមានតម្លៃប្រហែល ៧,១៩ ទ្រីលានរៀល (ប្រហែល ១,៧៥ ប៊ីលានដុល្លារអាមេរិក) និងទំហំជួញដូរភាគហ៊ុនសរុបមានចំនួន ៦.៤៦៦.០៨០ ភាគហ៊ុន ដែលទំហំជួញដូរនៅក្នុងទីផ្សារគោលមានប្រហែល ៩៥,៧២% និង ទីផ្សារកំណើនមានចំនួនប្រហែល ៤,២៨% នៃទំហំជួញដូរសរុប។ ដោយឡែក ចំពោះទីផ្សារមូលបត្របំណុល ពុំមានការជួញដូរលើសញ្ញាបណ្ណសាជីវកម្មណាមួយទេ។

# ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ
# BULLETIN ON INVESTORS AND INVESTING




ចេញផ្សាយលេខទី ១២

Issued number 12

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

Securities Market Supervision Department

ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២

The Fourth quarter of 2022

# ផ្នែកទី ២. ទិន្នន័យទីផ្សារមូលបត្រ/ Equity Market

## ២.១. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ/ Overview of Equity Market

| ទិដ្ឋភាពទូទៅនៃទីផ្សារ / Market Overview | | | បម្រែបម្រួលត្រី.៤ ធៀបនឹង ត្រី.៣ Change in Q4 to Q3 | |
|---|---|---|---|---|
| | Q4 2022 | Q3 2022 | Q4 2021 | Q3 2022 |
| ថ្ងៃជួញដូរ / Number of Trading Days | 62 | 65 | 6.90% | -4.62% |
| ចំនួនភាគហ៊ុនចុះបញ្ជីសរុប ( លានភាគហ៊ុន)/ Number of Listed Shares (Mil. Shares) | 845.58 | 845.58 | 3.14% | 0.00% |
| មូលធនូបនីយកម្មទីផ្សារ ( លានរៀល) / Market Capitalization (Mil. KHR) | 7,479,228.00 | 7,192,736.00 | 3.95% | 3.98% |
| មូលធនូបនីយកម្មទីផ្សារ ( លានដុល្លារអាមេរិក)/ Market Capitalization (Mil. USD) | 1,816.67 | 1,746.23 | | |
| បរិមាណបញ្ជាទិញ ( លានភាគហ៊ុន)/ Buy Order Quantity (Mil. Shares) | 22.77 | 23.30 | -45.89% | -2.27% |
| បរិមាណបញ្ជាលក់ ( លានភាគហ៊ុន)/ Sell Order Quantity (Mil. Shares) | 22.68 | 22.74 | -52.88% | -0.25% |
| ទំហំជួញដូរ ( លានភាគហ៊ុន)/ Trading Volume (Mil. Shares) | 5.92 | 6.47 | -83.66% | -8.46% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន)/ Average Daily Trading Volume (Shares) | 95,467 | 99,478 | -84.71% | -4.03% |
| តម្លៃជួញដូរ ( លានរៀល)/ Trading Value (Mil. KHR) | 51,706.33 | 63,819.67 | -47.20% | -18.98% |
| តម្លៃជួញដូរ ( លានដុល្លារអាមេរិក)/ Trading Value (Mil. USD) | 12.56 | 15.49 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ ( លានរៀល)/ Average Daily Trading Value (Mil. KHR) | 833.97 | 981.84 | -50.61% | -15.06% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ ( ដុល្លារអាមេរិក)/Average Daily Trading Value (USD) | 202,568.15 | 238,368.81 | | |
| ចំនួនវិនិយោគិន ( នាក់)/Number of Investors (Persons) | 5,142 | 5,755 | 13.31% | -10.65% |

*តារាង 1. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិក្នុងត្រីមាសទី៤ ឆ្នាំ២០២២/*

*Table 1. Overview of equity trading in the 4th quarter of 2022*